ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ការស្វែងយល់អំពី

# នីតិវិធីនៃការបង្កើតច្បាប់

ស្រាវជ្រាវដោយ៖ និស្សិតក្រុមជី៣ (*RULE*)


**Shared by page: Mr. That Chantha**
**https://www.facebook.com/thatchantha/**

# អារម្ភកថា

តាមរយៈកិច្ចព្រមព្រៀងទីក្រុងប៉ារីស នាថ្ងៃទី ២៣ តុលា ឆ្នាំ ១៩៩១ បានកំនត់ឲ្យមានការបោះឆ្នោត ដើម្បីកសាងនីតិរដ្ឋ និង បង្កើតស្ថាប័នគ្រប់គ្រងប្រទេស។ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រលើកទី ១ បានប្រព្រឹត្តទៅនៅថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ១៩៩៣ ដែលមានគណបក្សចំនួន ១៩ បានចូលរួមប្រកួតប្រជែងសំរាប់មណ្ឌល ២១ ដើម្បីជ្រើសរើសសភាធម្មនុញ្ញ និងតាក់តែងរដ្ឋធម្មនុញ្ញមួយដែលត្រូវប្រកាសអោយប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។ ក្នុងពេលជាមួយគ្នា នោះសភាធម្មនុញ្ញក៏បានក្លាយទៅជារដ្ឋសភាជាតិសំរាប់អាណត្តិទី១មានរយៈពេល ៥ ឆ្នាំ (ឆ្នាំ ១៩៩៣-១៩៩៨)។ បន្ទាប់មកទៀតការបោះឆ្នោតជ្រើសរើស តំណាងរាស្ត្រអាណត្តិទី ២ បានប្រព្រឹត្តទៅនៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៨ ដោយមានគណបក្សចំនួន ៣៩ ចូលរួមប្រកួតប្រជែងសំរាប់ ១២២ អសនៈ និង សំរាប់ ២២ មណ្ឌល។ បន្ទាប់ពីមានវិបត្តិនយោបាយស្ថាប័នកំពូលមួយរយៈពេលខ្លីមកក៏មានការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញនាឆ្នាំ១៩៩៩ ដើម្បីបង្កើតស្ថាប័នកំពូលមួយទៀតគឺស្ថាប័នព្រឹទ្ធសភា ដែលមានតួនាទីជាអង្គការនីតិបញ្ញត្តិផង និងជាអង្គការសំរាប់សម្របសម្រួល ការងាររវាងរដ្ឋសភា និង រាជរដ្ឋាភិបាលផង។ វិសោធនកម្មរដ្ឋធម្មនុញ្ញត្រូវបានអនុម័តដោយរដ្ឋសភាអាណត្តិទី២ នាថ្ងៃទី ៤ ខែ មិនា ឆ្នាំ ១៩៩៩ ហើយព្រឹទ្ធសភាបានចាប់ដំណើរការនៅថ្ងៃទី ២៥ ខែ មិនា ឆ្នាំ ១៩៩៩ ដោយមានសមាជិក ចំនួន ៦១ រួចជ្រើសតាំងដោយព្រះមហាក្សត្រ តាមសំណើររបស់ប្រធានគណបក្សដែលមានអសនៈនៅក្នុងរដ្ឋសភា។ ក្នុងន័យនេះអំណាចនីតិបញ្ញត្តិបានត្រូវបែងចែងរវាងអង្គការពីរ គឺ រដ្ឋសភា និង ព្រឹទ្ធសភា ។

ដូច្នេះចាប់តាំងពីឆ្នាំ១៩៩៩ រហូតមកដល់ពេលបច្ចុប្បន្នព្រះរាជាណាចក្រកម្ពុជាយើងបានប្រកាន់យករបបសភាពីរជាន់ គឺ រដ្ឋសភា និង ព្រឹទ្ធសភាដែលមានអំណាចខាងនីតិបញ្ញត្តិ ហើយមានភារកិច្ចតាក់តែង ពិនិត្យ និង អនុម័តសេចក្តីព្រាងច្បាប់ឬ សេចក្តីស្នើរច្បាប់ និងតាមដានត្រួតពិនិត្យ ការអនុវត្តច្បាប់របស់រាជរដ្ឋាភិបាល។

# មាតិកា

## ជំពូកទី១
## នីតិវិធីតាក់តែងវិធានច្បាប់

១.១ ទិដ្ឋភាព ........ ១
១.១.១ សាសនា ........ ១
១.១.២ ទំនៀមទំលាប់ ........ ២
១.១.៣ សីលធម៌ ........ ២
១.២សិទ្ធិនៃការផ្តួចផ្តើមធ្វើច្បាប់ ........ ៤
២.១.១ ទម្រង់នៃសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់ ........ ៤
២.១.១.១ ការផ្តួចផ្តើមធ្វើច្បាប់ដោយ រាជរដ្ឋាភិបាល ........ ៤
២.១.១.២ ការផ្តួចផ្តើមធ្វើច្បាប់ដោយ សភាទាំងពីរ ........ ៤
២.១.២ បែបបទនៃការអនុវត្តសិទ្ធិផ្តើមធ្វើច្បាប់ ........ ៥

## ជំពូកទី២
## នីតិវិធី ពិនិត្យ និង អនុម័តវិធានច្បាប់

២.១រាជរដ្ឋាភិបាល ........ ៧
២.១.១ ក្រសួងពាក់ព័ន្ធ ........ ៧
២.១.២ ទីស្តីការគណៈរដ្ឋមន្ត្រី ........ ១០
២.១.២.១ អន្តរក្រសួង ........ ១០
២.១.២.២ ប្រជុំពេញអង្គ ........ ១១
២.១.២.៣ ត្រួតពិនិត្យស្រាវជ្រាវ ........ ១២
២.២ រដ្ឋសភា ........ ១៣
២.២.១ ការដាក់ជូនសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់ទៅគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ........ ១៣
២.២.១.១ ការចុះក្នុងរបៀបវារៈ ........ ១៤
២.២.២ ការពិភាក្សាក្នុងគណៈកម្មការជំនាញ ........ ១៦
២.២. ២.១ ដំណាក់កាលនៃការពិនិត្យខ្លឹមសារទាំងមូល ........ ១៦
២.២.២.២ ដំណាក់កាលនៃការពិនិត្យលំអិត ........ ១៧
២.២.៣ ការពិភាក្សា និងការអនុម័តក្នុងសម័យប្រជុំពេញអង្គ ........ ២០
២.៣ ព្រឹទ្ធសភា ........ ២១

២.៣.១ ការដាក់ជូនសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់ទៅគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ២១
២.៣.១.១ ការចុះក្នុងរបៀបវារៈ ........ ២៣
២.៣.២ ការពិភាក្សាក្នុងគណៈកម្មការជំនាញ ........ ២៤
២.៣. ២.១ ដំណាក់កាលនៃការពិនិត្យខ្លឹមសារទាំងមូល ........ ២៥
២.៣.២.២ ដំណាក់កាលនៃការពិនិត្យលំអិត ........ ២៧
២.៣.៣ ការពិភាក្សា និងការអនុម័តក្នុងសម័យប្រជុំពេញអង្គ ........ ៣០
២.៤ ការបង្វិលទៅបង្វិលមករវាងសភាទាំងពីរ........ ៣៣
២.៤.១ សំណើរកែសម្រួលរបស់ព្រឹទ្ធសភា ........ ៣៤
២.៤.២ ការពិនិត្យជាលើកពីររបស់រដ្ឋសភា ........ ៣៥
២.៥ ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ ........ ៣៦
២.៥.១. ការត្រួតពិនិត្យជាអាទិកាល ........ ៣៧
២.៥.២ ការត្រួតពិនិត្យជាបច្ឆាកាល ........ ៣៧

**សេចក្តីសន្និដ្ឋាន និង អនុសាសន៍**

**ឧបសម្ព័ន្ធ**

**ឯកសារយោង**

# សេចក្ដីផ្ដើម

នៅក្នុងគ្រួសារមួយ សង្គមមួយ រដ្ឋមួយ ប្រទេសមួយ និងលើសកលលោកនេះ សុទ្ធតែមានច្បាប់សំរាប់គ្រប់គ្រង និង អនុវត្តដើម្បីធ្វើឲ្យប្រទេសជាតិមានសណ្ដាប់ធ្នាប់ របៀបរៀបរយនិងសុវត្ថិភាព។ ប្រសិនបើប្រទេសមួយគ្មានច្បាប់ នោះនឹងនាំឲ្យមានភាពច្របូកច្របល់ អសន្តិសុខនៅក្នុងសង្គមជាក់ជាមិនខាន។ ដូច្នេះប្រទេសនីមួយៗ ត្រូវមានគំនិតផ្ដួចផ្ដើមក្នុងការបង្កើតច្បាប់ក្នុងគោលបំណងបម្រើដល់ប្រយោជន៍ប្រជាពលរដ្ឋគ្រប់រូប និងសង្គមជាតិទាំងមូល។

តើយើងតាក់តែងវិធានច្បាប់នោះដោយរបៀបណា?

មុននឹងឈានចូលដល់ការ

ច្បាប់ គឺជាវិធានគតិយុត្តទាំងឡាយណាដែលបានអនុម័តដោយសភា ហើយដែលមានអត្ថន័យទូទៅ និងមានលក្ខណៈអចិន្ត្រៃយ៍ ពោលគឺច្បាប់ដែលត្រូវអុនម័តហើយ គឺបម្រើផលប្រយោជន៍ទូទៅមិនចំពោះ ជាពិសេសគឺដើម្បីរៀបចំរបៀបរៀបរយសណ្ដាប់ធ្នាប់សន្តិសុខសង្គម ហើយច្បាប់ទាំងនោះត្រូវគេអនុវត្តជារៀងរហូត លុះត្រាតែមានច្បាប់ថ្មីមកជំនួស (និរាករណ៍)។

នៅក្នុងប្រព័ន្ធគតិយុត្តនៃប្រទេសមួយចំនួននៅលើពិភពលោកយើងនេះ ច្បាប់ទាំងអស់ត្រូវបានអនុម័តដោយសភាតែមួយ។ ឧទាហរណ៍ ៖ ប្រទេសាំងហ្គាពូរ មានសភាតែមួយ ប៉ុន្តែដើម្បីអោយច្បាប់ទាំងឡាយណាដែលបានអនុម័តចេញមកឲ្យកាន់តែសុក្រឹតថែមទៀត នោះប្រទេសខ្លះបានប្រកាន់យករបបសភាពីរជាន់។ ឧទាហរណ៍ ៖ ប្រទេសថៃ ប្រទេសបារាំង សហរដ្ឋអាមេរិក......។ល។

យ៉ាងណាមិញ ព្រះរាជាណាចក្រកម្ពុជាក្រោយពីបានធ្វើការបោះឆ្នោតសភាអណិត្តទី២ (ឆ្នាំ ១៩៩៨) រួចមកក៏បានកាន់យករបបសភាពីរជាន់ គឺ រដ្ឋសភា និងព្រឹទ្ធសភា។ ការជ្រើសរើសយករបបសភាទ្វិកភាពនេះ ធ្វើឡើងក្នុងន័យសម្របសម្រួលបញ្ហានយោបាយ និងពង្រឹងប្រសិទ្ធិភាពក្នុងការអនុវត្តច្បាប់ ដើម្បីឲ្យព្រះរាជាណាចក្រកម្ពុជាអាចក្លាយជានីតិរដ្ឋ។ ជាពិសេសទៅទៀតបន្ទាប់ពីមានវិបត្តិនយោបាយមួយរយៈពេលខ្លីមក សភាក៏មានការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញដើម្បីបង្កើតស្ថាប័នព្រឹទ្ធសភាមួយដែលមានតួនាទីជាអង្គការនីតិបញ្ញត្តិផង និងជាអង្គការសម្របសម្រួលការងាររដ្ឋសភា និង រដ្ឋាភិបាលផង ក្នុងន័យនេះអំណាចនីតិបញ្ញត្តិបានត្រូវបែងចែងរវាងអង្គការពីរ គឺ រដ្ឋសភា និងព្រឹទ្ធសភា។

នៅក្នុងមុខងារនីតិបញ្ញត្តិរដ្ឋសភា និងជាព្រឹទ្ធសភាមានភារកិច្ចពិនិត្យអនុម័តសេចក្ដីព្រាងច្បាប់ ឬ សេចក្ដីស្នើច្បាប់ និង តាមដានត្រួតពិនិត្យការអនុវត្តច្បាប់។ ក្នុងដំណើរការអនុវត្តន៍ភារកិច្ច

នេះ ស្ថាប័នទាំងពីរនេះត្រូវតែគោរពតាមរដ្ឋធម្មនុញ្ញ នីតិវិធី និង បញ្ញត្តិទាំងឡាយ ដែលទាក់ទងនឹងការរៀបចំ និង ការប្រព្រឹត្តទៅរបស់ស្ថាប័ននីមួយៗ។

រីឯនីតិវិធីនៃការតាក់តែងអនុម័នច្បាប់វិញ គឺពុំសូវមានលក្ខណៈខុសគ្នាពីប្រទេសមួយទៅប្រទេសមួយទៀតប៉ុន្មានទេ ជាអាទ៍សិទ្ធិក្នុងការផ្តួចផ្តើមធ្វើច្បាប់ ការពិនិត្យ ការជជែកពីភាក្យា ការអនុម័ត រហូតដល់ការប្រកាសឲ្យប្រើជាធរមាន។

# ជំពូកទី១

# នីតិវិធីតាក់តែងវិធានច្បាប់

សង្គមមនុស្សត្រូវតែមានច្បាប់សំរាប់គ្រប់គ្រង ហើយច្បាប់នោះ ត្រូវធ្វើទៅតាមនីតិវិធីឲ្យបាន ត្រឹមត្រូវ ដើម្បីឲ្យច្បាប់នោះមានលក្ខណៈសុក្រឹត ក្នុងគោលបំណងបម្រើដល់ប្រយោជន៍របស់ប្រជាពលរដ្ឋ។ ហើយចំពោះការតាក់តែងច្បាប់នៅព្រះរាជាណាចក្រកម្ពុជា មានដូចតទៅៈ

- សេចក្តីព្រាងច្បាប់ ៖ ការផ្តួចផ្តើមតាក់តែងសេចក្តីព្រាងច្បាប់នេះ ធ្វើឡើងដោយរាជរដ្ឋាភិបាល ហើយត្រូវបញ្ជូនទៅរដ្ឋសភា។ សេចក្តីព្រាងច្បាប់នេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ចែកជាជំពូក និងមាត្រា ហើយត្រូវមានសេចក្តីថ្លែងហេតុមកជាមួយផង ដូចមានចែងក្នុងប្រការ២១ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា។
- សេចក្តីស្នើច្បាប់ ៖ ការផ្តួចផ្តើមតាក់តែងសេចក្តីព្រាងច្បាប់នេះ ធ្វើឡើងដោយតំណាងរាស្ត្រ ឬដោយសមាជិកព្រឹទ្ធសភា ហើយបញ្ជូនមករដ្ឋសភា។ សេចក្តីស្នើច្បាប់នេះត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ចែកជាជំពូក និងមាត្រា ហើយត្រូវមានសេចក្តីថ្លែងហេតុ ដូចមានចែងក្នុងប្រការ២២ នៃបញ្ញាផ្ទៃក្នុងរដ្ឋសភា។

ដូច្នេះទំរង់នៃការផ្តួចផ្តើមតាក់តែងច្បាប់ទាំងពីរខាងលើ ត្រូវបានគេបែងចែករវាង រដ្ឋាភិបាល និងសភាទាំងពីរ ប៉ុន្តែការផ្តួចផ្តើមដែលចេញពីសភា ត្រូវស្ថិតនៅក្រោមកំហិតដែលកំនត់ទុក ដោយរដ្ឋធម្មនុញ្ញ។

ម៉្យាងវិញទៀត នីតិវិធីនៃការតាក់តែងច្បាប់ មានប្រភពចេញមកពីសិទ្ធិផ្តួចផ្តើមធ្វើច្បាប់ដែលមានបែបបទខុសៗគ្នាជាច្រើនដូចជាៈ

- សិទ្ធិនៃការធ្វើច្បាប់(ន័យត្រង់)ដែលធ្វើឡើងតាមរូបភាពជាសេចក្តីព្រាង ឬសេចក្តីស្នើច្បាប់
- សិទ្ធិធ្វើវិសោធនកម្មលើសេចក្តីព្រាង ឬសេចក្តីស្នើច្បាប់ ។

## ១.១ និជ្ជភាព

### ១.១.១ សាសនា

ច្បាប់ជាក់ស្តែងអាចទទួលបានឥទ្ធិពលតិច ឬច្រើនពីសាសនា ក៏ប៉ុន្តែច្បាប់រដ្ឋ និងច្បាប់សាសនា មិនមានលក្ខណៈដូចគ្នាសុទ្ធសាធនោះទេ លើកលែងតែក្នុងករណីខ្លះតែប៉ុណ្ណោះ ។

ច្បាប់សាសនាច្រើនដូចច្បាប់សីលធម៌ជាង ពីព្រោះកើតចេញមកពីបញ្ញាញាណរបស់ព្រះ ពុំមែនចេញមកពីរដ្ឋអំណាចនោះទេ ហើយមានគោលដៅអប់រំមនុស្សឲ្យម្នាក់ៗបានល្អ ដើម្បីបានឡើងឋានសួគ៌ ឬក៏ឲ្យបានទៅកាន់សុខតិភព។ ពោលម្នាក់ៗត្រូវគោរពប្រតិបត្តិតាមវិន័យសាសនា បើពុំនោះទេត្រូវទទួលខុសត្រូវចំពោះព្រះ ពុំមែនចំពោះរដ្ឋអំណាចទេ។ នៅក្នុងបណ្តាប្រទេសជឿនលឿន គេទុកច្បាប់រដ្ឋឲ្យនៅដាច់ដោយឡែកពីច្បាប់សីលធម៌ ក៏ដូចជាច្បាប់សាសនាក៏មិននៅលាយឡំគ្នាឡើយ។ នៅក្នុងបណ្តាប្រទេសខ្លះផ្សេងទៀតដែលដោគជាំទៅដោយសាសនា (អ៊ីស្លាម)

ច្បាប់សាសនាគឺជាច្បាប់រដ្ឋ។ ទណ្ឌកម្មបស់ព្រះ ជាទណ្ឌកម្មរបស់រដ្ឋអំណាច។ ក្នុងករណីនេះ គេពុំអាចឃើញអ្វីប្លែកពីគ្នាប៉ុន្មានទេ រវាងច្បាប់រដ្ឋ ច្បាប់សាសនា និងច្បាប់សីលធម៌។ ចំពោះព្រះរាជាណាចក្រកម្ពុជាយើងវិញ ទោះបីរដ្ឋធម្មនុញ្ញបានចែងថា ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ[1] ក៏ដោយ ក៏ច្បាប់នៅតែដាច់ដោយឡែកពីសាសនា។ ពោលគឺច្បាប់រដ្ឋជាច្បាប់អាណាចក្រ រីឯច្បាប់សាសនា ជាច្បាប់ពុទ្ធចក្រ សម្រាប់គ្រប់គ្រងផ្លូវចិត្តរបស់អ្នកកាន់ពុទ្ធសាសនា ។



### ១.១.២ ទំនៀមទំលាប់

- **ច្បាប់ព្រៃ**

**ច្បាប់ព្រៃ** គឺមានន័យថា ការយកកម្លាំងបាយ និងអំពើចិត្តមកប្រើជាមធ្យោបាយ (ច្បាប់) សម្រាប់ការរស់នៅ។

មនុស្សខ្លះដែលរស់នៅក្នុងសង្គមមួយ ហើយមិនព្រមយល់ពីរបៀបនៃការគ្រប់គ្រងការរស់នៅ និងដោយមិនព្រមទទួលស្គាល់នូវបច្ច័យរវាងហេតុ និងផលនៅក្នុងការដោះស្រាយទំនាស់ ហើយយល់តែអ្វីដែលជាជាតិកំណើតពីធម្មជាតិរបស់ខ្លួនតែប៉ុណ្ណោះ។

យ៉ាងណាមិញ នៅក្នុងព្រៃព្រឹក្សាដែលគ្មានមនុស្សរស់នៅសោះ មានសត្វតូច និងធំ ជាច្រើនរស់នៅជាមួយគ្នាគ្រប់ទិសទី គេសង្កេតឃើញថា មានសត្វដែលតូច ហើយខ្សោយ ត្រូវបានសត្វធំ ហើយខ្លាំង ចាប់ធ្វើជាអាហារប្រចាំថ្ងៃតាមតែអំពើចិត្ត និងតាមការស្រេកឃ្លានរបស់វា ។ ប្រការបែបនេះហៅថា **ច្បាប់ព្រៃ** ។

- **ច្បាប់ធម្មជាតិ**

ដោយហេតុថា ច្បាប់ជាបាតុភូតសង្គមដែលត្រូវតែវិវត្តជាដរាប ទៅតាមការរីកចម្រើនខាងចំណេះដឹង និងខាងវិទ្យាសាស្ត្ររបស់មនុស្ស ដែលរស់នៅក្នុងសង្គមពីសម័យមួយទៅសម័យមួយជាលំដាប់។ រីឯឫសកែវជាមូលដ្ឋាននៃច្បាប់ក៏ប្រែប្រួលដែរ ស្របទៅតាមលក្ខណៈនេះ។ ឫសកែវជាមូលដ្ឋាននៃច្បាប់ ច្រើនតែចេញមកពីលក្ខណៈល្អៗដែលគេហៅថា តម្លៃរបស់មនុស្ស ហើយដែលមានក្នុងធម្មជាតិ។ អ្នកទស្សនវិទូ និងអ្នកនីតិសាស្ត្រ គេឲ្យឈ្មោះថា **ច្បាប់ធម្មជាតិ**។

នៅក្នុងប្រវត្តិនីតិសាស្ត្រ គេអាចកត់សម្គាល់បាន នូវការវិវត្តនៃខ្លឹមសាររបស់ច្បាប់ធម្មជាតិគឺនៅក្នុងសម័យបុរាណមុនគ្រឹស្តសករាជ មកដល់ឆ្នាំ៩៧៦ និងទី១៨ គេហៅថា **ច្បាប់ធម្មជាតិទំនើប**។

ច្បាប់ធម្មជាតិទាំងនេះ ជាច្បាប់តាមន័យនីតិសាស្ត្រ ព្រោះជាឫសកែវនៃច្បាប់ជាក់ស្តែង។ និយាយម៉្យាងទៀត គឺច្បាប់ជាក់ស្តែង ដែលយើងបានបង្កើតឡើង តែងតែយោងទៅលើច្បាប់ធម្មជាតិ ដែលពឹងផ្អែកជានិច្ចទៅលើគតិយុត្តិធម៌ និងគតិបណ្ឌិត។

### ១.១.៣ សីលធម៌

យើងចង់និយាយអំពីច្បាប់ជាក់ស្តែង ដែលរដ្ឋអំណាចតាក់តែងឡើង។ រវាងច្បាប់នេះ និងសីលធម៌ច្រើនមានចំនងទាក់ទងគ្នាយ៉ាងជិតស្និទ្ធ។ ពីព្រោះគេរមែងសង្កេតឃើញថា វិធានច្បាប់ជា

[1] មាត្រា ៤៣ នៃរដ្ឋធម្មនុញ្ញ ១៩៩៣

ច្រើនបានស្រង់ចេញមកអំពីសីលធម៌។ រីឯច្បាប់វិញក៏មានឥទ្ធិពលទៅលើសីលធម៌ដែរ ពីព្រោះច្បាប់ជួនកាលដាក់កំហិត លើទម្លាប់ចិត្តគំនិតនៃការរស់នៅក្នុងសង្គម ធ្វើអោយមនុស្សនាំគ្នាកែលំអទំលាប់ចិត្តគំនិតខ្លួនបានដែរ ហាក់បីដូចជាមានបង្កើតច្បាប់សីលធម៌អញ្ចឹងដែរ។

ការវិភាគលើចំនងនេះ នាំអោយយើងអាចបញ្ជាក់លក្ខណៈសំរាប់សំគាល់ថា ច្បាប់ខុសពីសីលធម៌នូវចំនុចណា? យើងលើកយកលក្ខណៈបីយ៉ាង ៖

- **ប្រភព**

វិធាន ឬវិន័យទាំងឡាយរបស់សីលធម៌កើតអំពីបញ្ញាញាណរបស់ព្រះ អំពីសតិសម្បជញ្ញៈយើងម្នាក់ៗ ឬទាំងអស់គ្នា។ ចំណែកវិធាននៃច្បាប់វិញ គឺចេញមកពី ឆន្ទៈរបស់រាស្ត្រ និងអំណាចរដ្ឋ។ នេះជាការខុសគ្នារវាងច្បាប់ និងសីលធម៌ ប៉ុន្តែបើគិតឲ្យជ្រៅមែនទែន វាខុសគ្នាតែសំបកខាងក្រៅប៉ុណ្ណោះ គឺត្រង់របៀបតាក់តែងសរសេរច្បាប់ មិនដូចនឹងក្បួនសីលធម៌ដែលឥតសរសេរ ដូចជាទំនៀមទម្លាប់ និងយុត្តិសាស្ត្រ។ ច្បាប់ឥតសរសេរ មិនមែនមានន័យថា គ្មាននរណាសរសេរអំពីច្បាប់ឥតសរសេរនោះទេ គឺមានន័យថា ច្បាប់នោះពុំដែលមានអ្នកតាក់តែង និងប្រកាសឲ្យប្រើប្រាស់តាម របៀបដែលគេតម្រូវសម្រាប់ធ្វើច្បាប់និងគ្មានការអនុម័តពីអង្គការ ស្ថាប័នមានសមត្ថកិច្ចទេ។

- **ខ្លឹមសារ**

**កម្មវត្ថុ** វិស័យសីលធម៌ និងវិស័យច្បាប់មិនជាន់គ្នាទេ។ វិស័យសីលធម៌គិត អំពីករណីយកិច្ចរបស់យើង មិនត្រឹមតែចំពោះអ្នកដទៃប៉ុណ្ណោះទេ តែថែមទាំងចំពោះខ្លួនឯងផងដែរ ហើយរហូតចំពោះព្រះផងក៏សឹងតែថាបានទៀត។ ក្នុងន័យនេះឃើញថា វិស័យសីលធម៌ ហាក់ដូចជាទូលំទូលាយជាងវិស័យច្បាប់។ ប៉ុន្តែផ្ទុយទៅវិញ ជួនកាលវិស័យច្បាប់ក៏អាចហៀរជ្រុលហួសទៅលើវិស័យសីលធម៌ផងដែរ។

ឧទាហរណ៍ ៖ ឧក្រិដ្ឋជន ក្លាយទៅជាគ្មានទោសក្រោយពីផុតអាជ្ញាយុកាល។

**គោលដៅ៖** សីលធម៌ច្រើនទាមទារអោយខ្លួនយើងម្នាក់ៗ ឈានទៅរកអ្វីដែលល្អប្រសើរបំផុតដូចជាឲ្យយើងមានចិត្តល្អ ចេះធ្វើទាន ចេះលះបង់គំនិតអាត្មានិយមជាដើម។ រីឯច្បាប់ គេធ្វើឡើងក្នុងគោលដៅធ្វើឲ្យមានសណ្តាប់ធ្នាប់ល្អនៅក្នុងសង្គម ដោយគេពុំសូវគិតពីរឿង ធ្វើឲ្យមនុស្សល្អប្រសើរបំផុតនោះទេ។

- **ទណ្ឌកម្ម**

អ្នកប្រព្រឹត្តខុសនឹងសីលធម៌ ច្រើនទទួលបានទណ្ឌកម្មតាមផ្លូវចិត្តដោយខ្លួនឯង(មនសិការ)។ ចំណែកអ្នកប្រព្រឹត្តខុសច្បាប់វិញ ត្រូវទទួលទណ្ឌកម្មពីអំណាចរដ្ឋ គឺជាប្រភេទទណ្ឌកម្មមួយមកពីខាងក្រៅនៃជនល្មើសនោះ។ ប៉ុន្តែបើតាមការសង្កេត ឃើញថា មានខ្សែទំនាក់ទំនងគ្នារវាងទណ្ឌ_កម្មនៃសីលធម៌ និងទណ្ឌកម្មនៃច្បាប់។ ពីព្រោះអ្នកដែលប្រព្រឹត្តខុសនឹងសីលធម៌ ជួនកាលត្រូវ អ្នកជិតខាង ឬសង្គមគេឈប់រាប់រក ដែលនេះក៏ជាទណ្ឌកម្មមួយដែរ ព្រោះយើងម្នាក់ៗ ពុំអាចរស់នៅម្នាក់ឯងក្នុងសង្គមបានទេ។ ជួនកាលអ្នកប្រព្រឹត្តខុសច្បាប់ ហើយទទួលទោសជាប់ពន្ធនាគារក៏មានវិប្បដិសារី ឬមនសិការផ្តន្ទាទោសតាមផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរដែរ។ ដូច្នេះទណ្ឌកម្មពីខាងក្នុង និងពី

ខាងក្រៅ អាចមានឥទ្ធិពលលើគ្នាទៅវិញទៅមកតាមរបៀបច្រើនយ៉ាង នាំអោយយើងមិនអាចថាមានភាពដាច់គ្នាស្រឡះបានឡើយ។

## ១.២សិទ្ធិនៃការផ្តួចផ្តើមធ្វើច្បាប់

### ២.១.១ ទម្រង់នៃសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់

ការតាក់តែងសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់ ត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយដាក់ចំណងជើង ទម្រង់អត្ថបទ របៀបបែងចែកជាជំពូក របៀបដាក់លេខលំដាប់មាត្រា ហើយត្រូវមានសេចក្តីថ្លែងហេតុនៅខាងដើម ដោយភ្ជាប់ជាមួយសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ រួចហើយបញ្ជូនមកគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាជាដំបូង[២] ដោយពន្យល់ពីគោលបំណងនៃសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ព្រមទាំងមូលហេតុនៃការតម្រូវឲ្យអនុម័តច្បាប់នេះ។

អ្នកមានសិទ្ធិរៀបចំ និងតាក់តែងសេចក្តីព្រាងច្បាប់ និងសេចក្តីស្នើច្បាប់ គឺសមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា និងនាយករដ្ឋមន្ត្រី[៣] ដែលទម្រង់នៃការផ្តួចផ្តើមធ្វើច្បាប់ទាំងពីរនេះត្រូវបានបែងចែកដូចខាងក្រោម ៖

#### ២.១.១.១ ការផ្តួចផ្តើមធ្វើច្បាប់ដោយ រាជរដ្ឋាភិបាល

- **ការផ្តួចផ្តើមធ្វើច្បាប់ដោយរាជរដ្ឋាភិបាល**

រាល់សេចក្តីព្រាងច្បាប់ គឺផ្តួចផ្តើម និងតាក់តែងឡើងដោយរដ្ឋាភិបាល រួចបញ្ជូនមកគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាដោយអនុវត្តតាម[៤] ។

#### ២.១.១.២ ការផ្តួចផ្តើមធ្វើច្បាប់ដោយ សភាទាំងពីរ

- **ការផ្តួចផ្តើមធ្វើច្បាប់ដោយសភាទាំងពីរ**

រាល់សេចក្តីស្នើច្បាប់ គឺផ្តួចផ្តើម និងតាក់តែងឡើងដោយតំណាងរាស្ត្រ ឬសមាជិកព្រឹទ្ធសភា ហើយត្រូវបញ្ជូនមកគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា។ ដោយសេចក្តីស្នើច្បាប់នោះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ចែកចេញជាជំពូក និងមាត្រា និងភ្ជាប់នូវសេចក្តីថ្លែងហេតុជាមួយផង[៥] ។

ទន្ទឹមនឹងមានសិទ្ធិនៅក្នុងការផ្តួចផ្តើមធ្វើច្បាប់ រាជរដ្ឋាភិបាល តំណាងរាស្ត្រ និងសមាជិកព្រឹទ្ធសភា មានសិទ្ធិក្នុងការដកនូវអត្ថបទផ្តួចផ្តើមច្បាប់របស់ខ្លួនវិញ។ បែបបទនានានៃការអនុវត្តសិទ្ធិបានកំណត់ ដោយប្រការ២៥ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងប្រការ២៧ នៃបទបញ្ជា ផ្ទៃក្នុងព្រឹទ្ធសភា។ រាជរដ្ឋាភិបាល អាចដកសេចក្តីព្រាងច្បាប់របស់ខ្លួនបានគ្រប់ពេល រហូតដល់ការអនុម័តជាស្ថាបពរដោយសភា។ ការដកចេញអាចធ្វើឡើងក្រោមរូបភាពជាអនុក្រឹត្យ។ ប៉ុន្តែជាញឹកញាប់ ការដកចេញនេះធ្វើឡើងដោយជូនកាលរាជរដ្ឋាភិបាលគ្រាន់តែដកចេញនូវសេចក្តីព្រាងណា

---

[២] ប្រការ២១បទបញ្ជាផ្ទៃក្នុងរដ្ឋសភា

[៣] មាត្រា៩១ ថ្មី វាក្យខណ្ឌទី១ រដ្ឋធម្មនុញ្ញនៃព្រះរាជា ណាចក្រកម្ពុជា

[៤] ប្រការ២១ បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា

[៥] ប្រការ២២ បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា

មួយពីរបៀបវារៈ ដែលមានលក្ខណៈជាអាទិភាព ហើយមិនបញ្ជូនវាទៅវិញ ជូនកាលរាជរដ្ឋាភិបាលសម្រេចថា មិនបញ្ជូនទៅសភានូវសេចក្ដីព្រាងណាមួយ ដែលសភាមួយទៀតបានពិនិត្យរួចហើយ។

### ២.១.២ បែបបទនៃការអនុវត្តសិទ្ធិផ្ដើមធ្វើច្បាប់

សេចក្ដីព្រាងច្បាប់ និងសេចក្ដីស្នើច្បាប់មានលក្ខណៈដូចគ្នា ខាងផ្នែកទម្រង់ និងអត្ថន័យនៃអង្គសេចក្ដីខាងក្នុងការឧទ្ទេស ជាលក្ខណៈទម្រង់នៃសេចក្ដីព្រាងច្បាប់ និងសេចក្ដីស្នើច្បាប់ទាំងពីរនេះ ចែកចេញជាពីរផ្នែកធំៗ **សេចក្ដីថ្លែងហេតុ** បង្ហាញអំពីអំណះអំណាងនានារបស់អ្នកតាក់តែងសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ ដោយផ្អែកលើការកែប្រែបញ្ញត្តិថ្មី ដែលអ្នកតាក់តែងសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ស្នើឡើង។ ផ្នែកបទដ្ឋានត្រូវសរសេរឡើងក្រោមរូបភាពជាមាត្រា[៦] ។

ចំណែកអត្ថន័យនៃសេចក្ដីព្រាងច្បាប់ និងសេចក្ដីស្នើច្បាប់វិញ គឺផ្ដោតទៅលើវិស័យនីតិបញ្ញត្តិបានន័យថា វានឹងជាដែនគតិយុត្តដែលតម្រូវឲ្យមានបទអន្តរាគមន៍របស់ច្បាប់។ ម៉្យាងវិញទៀត លក្ខណៈនានា នៃការប្រតិបត្តិសិទ្ធិក្នុងការផ្ដួចផ្ដើមធ្វើច្បាប់ បង្ហាញឲ្យយើងឃើញនូវភាពខុសគ្នារវាងការផ្ដួចផ្ដើមដោយរាជរដ្ឋាភិបាល និងអង្គការនីតិបញ្ញត្តិ។ នីតិវិធីក្នុងការតាក់តែងនេះបានស្ដែងឲ្យឃើញជាដំបូងនូវភាពខុសគ្នា បើតាមមាត្រា៩១ ថ្មីនៃរដ្ឋធម្មនុញ្ញចែងថា នាយករដ្ឋមន្ត្រីមានសិទ្ធិផ្ដួចផ្ដើមធ្វើច្បាប់។ តែតាមការអនុវត្តជាក់ស្ដែង ក្រោយពីបានយោបល់របស់នាយករដ្ឋមន្ត្រីរួចមក រដ្ឋមន្ត្រីទទួលបន្ទុកក្រសួងពាក់ព័ន្ធជាអ្នករៀបចំចងក្រង និងធ្វើសេចក្ដីព្រាងច្បាប់នោះ។ បន្ទាប់មករដ្ឋមន្ត្រីទទួលបន្ទុកក្រសួងពាក់ព័ន្ធ ត្រូវបានបញ្ជូនសេចក្ដីព្រាងច្បាប់នេះទៅក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្ដីការគណៈរដ្ឋមន្ត្រីពិនិត្យ និងកែសម្រួលជាមុនសិន ទើបដាក់ជូនគណៈរដ្ឋមន្ត្រីធ្វើការពិភាក្សា និងអុនម័ត។ គួរកត់សម្គាល់ថា នៅក្នុងដំណើរការកសាងសេចក្ដីព្រាងច្បាប់នេះឡើងរដ្ឋមន្ត្រីអាចស្នើឲ្យមានការផ្ដល់យោបល់ពីសំណាក់អ្នកជំនាញការបរទេសផងដែរ។

ការដែលសេចក្ដីព្រាងច្បាប់ត្រូវស្ថិតនៅក្រោមរបស់នាយករដ្ឋមន្ត្រី គឺដើម្បីធានានូវឯកភាពចំពោះការផ្ដួចផ្ដើមច្បាប់ចេញពីរាជរដ្ឋាភិបាល។

ការសេចក្ដីព្រាងច្បាប់ដោយធ្វើឡើងក្រោមរូបភាពជាអនុក្រឹត្យរបស់ប្រមុខរាជរដ្ឋាភិបាល និងត្រូវបានចុះហត្ថលេខាអមដោយរដ្ឋមន្ត្រី ជូនកាលមានចំនួនច្រើនដោយទទួលបន្ទុកក្នុងការពារការជជែកវែកញែកទៅលើសេចក្ដីព្រាង។

ផ្ទុយទៅវិញ ការផ្ដួចផ្ដើមធ្វើច្បាប់ដែលចេញពីសភា ជាបុព្វសិទ្ធិមួយដែលត្រូវបានអនុវត្តន៍ដែលមានលក្ខណៈដាច់ៗពីគ្នានៅក្នុងសភារបស់ខ្លួន ដោយសមាជិករដ្ឋសភា និងដោយសមាជិកព្រឹទ្ធសភាម្នាក់ៗ។ ប៉ុន្តែគ្មានអ្វីដែលហាមឃាត់ចំពោះការដាក់សេចក្ដីស្នើច្បាប់មួយ ដែលធ្វើឡើងដោយសមាជិកតំណាងរាស្ត្រជាច្រើនរួមគ្នា ឬជាងនេះទៅទៀត ដោយសារសមាជិកទាំងមូលនៃក្រុមមួយ ឬសមាជិកទាំងមូលនៃក្រុមជាច្រើនរួមគ្នា ប៉ុន្តែជាញឹកញាប់កម្មវត្ថុតែមួយនៃបញ្ញត្តិច្បាប់នឹងត្រូវបានគេធ្វើការពិនិត្យពិភាក្សាវែកញែក ដោយចែកចេញជាសេចក្ដីស្នើច្បាប់ផ្សេងពីគ្នា។

---

[៦] ប្រការ២៤ នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា និងប្រការ២២ នៃបទបញ្ជាផ្ទៃក្នុង នៃព្រឹទ្ធសភា

នីតិវិធីប្រហាក់ប្រហែលនេះ អាចត្រូវបានប្រើសម្រាប់ភ្ជាប់កាពិភាក្សា ដែលធ្វើឡើងស្របគ្នារវាងសមាជិករដ្ឋសភា និងសមាជិកព្រឹទ្ធសភាលើសេចក្តីស្នើច្បាប់ដែលមានកម្មវត្ថុប្រហាក់ប្រហែលគ្នា។ ចំពោះការដាក់ជូន ដល់ការសិក្សាជាសាធារណៈវិញ សេចក្តីព្រាងច្បាប់ត្រូវបានធ្វើទៅតាមលក្ខខណ្ឌខុសៗគ្នា។ ទន្ទឹមនឹងមានសិទ្ធិផ្តួចផ្តើមធ្វើសេចក្តីព្រាងច្បាប់ រាជរដ្ឋាភិបាលក៏មានលទ្ធភាពក្នុងការស្នើការកែប្រែលើសេចក្តីព្រាច្បាប់របស់ខ្លួនដែរ ដែលធ្វើឡើងតាមរយៈលិខិតដែលចេញដោយនាយករដ្ឋមន្ត្រី ហើយដែលធ្វើការកែតម្រូវដោយផ្ទាល់លើអត្ថន័យខាងក្នុង នៃសេចក្តីព្រាងច្បាប់ដែលបានដាក់ជូនរដ្ឋសភាពីមុន។ នីតិវិធីធ្វើឲ្យមានការកែប្រែឡើងវិញនូវអត្ថបទដែលជាមូលដ្ឋានគ្រឹះនៃការពិភាក្សានៅក្នុងរដ្ឋសភា។ ដូច្នេះលិខិតកែតម្រូវ មិនមែនជាការធ្វើវិសោធនកម្មដែលចេញពីរដ្ឋាភិបាលទេ តែជាការប្រើប្រាស់អំណាចផ្តួចផ្តើមធ្វើច្បាប់ ដែលនាយករដ្ឋមន្ត្រីមានប៉ុណ្ណោះ[៧] ។

ការពិភាក្សាលើបទប្បញ្ញត្តិ នៃសំបុត្រកែតម្រូវមួយ ប្រព្រឹត្តទៅក្រោមលក្ខណៈតែមួយដូចគ្នានឹងការពិនិត្យលើសេចក្តីព្រាងច្បាប់ដោយមានន័យថា បទប្បញ្ញត្តិនេះក៏អាចធ្វើជាកម្មវត្ថុ នៃការធ្វើវិសោធនកម្មដែរ។

[៧] មាត្រា៩១ វាក្យខណ្ឌ១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

# ជំពូកទី២

# នីតិវិធី ពិនិត្យ និង អនុម័តវិធានច្បាប់

## ២.១.រាជរដ្ឋាភិបាល

### ២.១.១ ក្រសួងពាក់ព័ន្ធ

ការចុះឈ្មោះសុំនិយាយលំដាប់គ្នា និងអំពីការកំណត់រយៈពេលនិយាយនេះ ប្រើប្រាស់សំរាប់តែតំណាងរាស្ត្រក្នុងក្រុម មិនត្រូវប្រើសម្រាប់សមាជិក និងតំណាងរាជរដ្ឋាភិបាលទេ[៨] ។ បទប្បញ្ញត្តិនេះមានន័យថា តំណាងរាជរដ្ឋាភិបាលអាចនិយាយគ្មានពេលវេលាកំណត់។ នៅក្នុងករណីនេះ ដើម្បីឲ្យតំណាងរាជរដ្ឋាភិបាលមានពេលវេលាវែង សម្រាប់បកស្រាយដើម្បីបំភ្លឺទៅនឹងការឆ្ងល់ ឬមិនយល់ពីខ្លឹមសារក្នុងមាត្រា ឬជំពូកណាមួយនៃអត្ថបទសេចក្តីព្រាងច្បាប់ ដែលសមាជិករដ្ឋសភាបានចោទសួរដើម្បីឲ្យបំភ្លឺ។ គេពុំឃើញមានបទប្បញ្ញត្តិណាមួយដែលហាមឃាត់រដ្ឋាភិបាលនៅក្នុងការអនុវត្តបុព្វសិទ្ធិរបស់ខ្លួនឡើយ ហើយជាទូទៅបុព្វសិទ្ធិនេះ តែងតែត្រូវបានអនុវត្តន៍ បន្ទាប់ពីបទអន្តរាគមន៍របស់ប្រធានគណៈកម្មការជំនាញ ឬបន្ទាប់ពីក្រោយការចោទសួរពីសំណាក់សមាជិករដ្ឋសភាជាច្រើនសំនួរ។ ចំពោះការប្រជុំជជែកពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់នៅរដ្ឋសភា ជាគោលការណ៍តម្រូវឲ្យមានរដ្ឋមន្ត្រី ឬរដ្ឋលេខាធិការជាតំណាង ក្រសួងជំនាញមកការពារសេចក្តីព្រាងច្បាប់នៅរដ្ឋសភា ជាគោលការណ៍តម្រូវឲ្យមានរដ្ឋមន្ត្រី ឬរដ្ឋលេខាធិការជាតំណាងក្រសួងជំនាញ មកការពារសេចក្តីព្រាងច្បាប់របស់ខ្លួន។ ប៉ុន្តែសមាជិកដទៃទៀតនៃរដ្ឋាភិបាលក៏មានសិទ្ធិចូលរួម ក្នុងការជជែកពិភាក្សានេះដែរ កាលបើអត្ថបទដែលកំពុងជជែកពិភាក្សានោះ ចែងពីបញ្ហាដែលពាក់ព័ន្ធដល់ស្ថាប័ន ឬក្រសួងរបស់ខ្លួនទទួលបន្ទុក។

- **អំពីប្រធានគណៈកម្មការជំនាញ**

ប្រធានគណៈកម្មការជំនាញ ត្រូវឡើងរាយការណ៍អំពីយោបល់របស់គណៈកម្មការរបស់ខ្លួនដែលបានធ្វើការពិនិត្យ និងពិភាក្សាយ៉ាងហ្មត់ចត់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ជូនអង្គសភា ដើម្បីធ្វើការជជែកពិភាក្សាលើអត្ថបទសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នេះ។ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា បញ្ជូនសេចក្តីព្រាងច្បាប់ ឬស្នើច្បាប់នោះទៅគណៈកម្មការតាមមុខជំនាញឲ្យពិនិត្យ។ កាលបើពិនិត្យរួចហើយ ប្រធានគណៈកម្មការនោះ ត្រូវនាំយកយោបល់របស់គណៈកម្មការមក ជម្រាបជូនរដ្ឋសភា[៩] ។

ប្រធានគណៈកម្មការ ជាអ្នកកំណត់នូវរយៈពេលដ៏សមស្របសម្រាប់ឡើងរាយការណ៍ដែលរួមមានការជម្រាបជូន នូវយោបល់សម្រេចរបស់គណៈកម្មការ។ តួនាទីរបស់ប្រធានគណៈកម្មការមិនមែនចប់ត្រឹមការធ្វើបទអន្តរាគមន៍ខាងលើនេះទេ ថែមទាំងជាអ្នកបកស្រាយនូវយោបល់របស់

[៨] ប្រការ ៦០ថ្មី បទបញ្ជាផ្ទៃក្នុងរដ្ឋសភា

[៩] ប្រការ ២១ បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា

គណៈកម្មការ និងមានសិទ្ធិសម្រេចឯកភាព ឬក៏បដិសេធនូវសំណើររបស់តំណាងរាជរដ្ឋាភិបាល ដែលបានស្នើទៅប្រធានគណៈកម្មការ អំពីការសុំកែសម្រួលខ្លឹមសារក្នុងមាត្រា ឬជំពូកខ្លះៗពីសំណាក់សមាជិករដ្ឋសភា។ ក៏ប៉ុន្តែសិទ្ធិសម្រេចនេះ ក៏ត្រូវមានការឯកភាពពីសំណាក់តំណាងរាជរដ្ឋាភិបាលដែរ។ ក្រោយពីការរាយការណ៍របស់ប្រធានគណៈកម្មការជំនាញចប់សព្វគ្រប់ ការជជែកពិភាក្សា និងអនុម័តតាមលំដាប់លំដោយក៏ចាប់ផ្តើមឡើង។



- **អំពីសមាជិករដ្ឋសភា**

សមាជិករដ្ឋសភា ដែលមានបំណងបញ្ចេញយោបល់ធ្វើបទអន្តរាគមន៍ទៅលើអត្ថបទសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ត្រូវគោរពទៅតាមលក្ខខណ្ឌដែលមានចែងក្នុងប្រការ៥៥ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា សមាជិកទាំងឡាយនៃរដ្ឋសភាត្រូវសុំ ហើយទទួលសេចក្តីអនុញ្ញាតពីប្រធានជាមុនសិនទើបនិយាយបាន។

តាមគោលការណ៍រយៈពេលនិយាយ សម្រាប់សមាជិករដ្ឋសភាម្នាក់ៗ ត្រូវមានកំណត់ដែលមានន័យថា សមាជិករដ្ឋសភា ដែលចុះឈ្មោះសុំនិយាយមានរយៈពេល២០នាទីយ៉ាងយូរ តាមធម្មតាអ្នកតំណាងរាស្ត្រក្នុងក្រុមដែលបានចុះឈ្មោះសុំនិយាយ គឺនិយាយបាន២០នាទីយ៉ាងយូរ។ អ្នកតំណាងរាស្ត្រក្នុងក្រុម ដែលគ្រាន់តែសុំឆ្លើយតបនិយាយបានតែ៥នាទីទេ។ បើប្រធានយល់ឃើញថា ជាការចាំបាច់ ឬមានប្រយោជន៍ក្នុងការពិភាក្សានោះ ប្រធានអាចអនុញ្ញាតបន្ថែមពេលឲ្យនិយាយ១០នាទីបាន។ ការបន្ថែមនេះអាចអនុញ្ញាតឲ្យបន្តពីរដង ក្នុងប្រធានបទដដែល។ អ្នកតំណាងរាស្ត្រឯទៀតក្នុងក្រុមជាមួយ មានសិទ្ធិសុំបញ្ចេញមតិន្ថែមក្នុងប្រធានបទដដែល និងក្នុងរយៈពេលដូចកំណត់ខាងលើ[១០]។ អ្នកតំណាងរាស្ត្រដែលបានអនុញ្ញាតឱ្យនិយាយ ត្រូវនិយាយតែពីរឿងដែលកំពុងពិភាក្សា[១១] ។ គួរកត់សំគាល់ផងដែរថា ក្នុងការជជែកពិភាក្សាវាគ្មិនត្រូវ និយាយឆ្លាស់គ្នា អ្នកគាំទ្រនិយាយម្តង រួចអ្នកជំទាស់និយាយម្តង[១២] ។

នៅពេលដែលអ្នកតំណាងរាស្ត្រ ដែលសុំនិយាយបាននិយាយចប់ តំណាងរដ្ឋាភិបាលជាអ្នកធ្វើបទអន្តរាគមន៍ ដើម្បីឆ្លើយតបទៅនឹងបញ្ហាទាំងអស់ ដែលត្រូវបានអ្នកតំណាងរាស្ត្របានចោទសួរ ឬមានការមិនយល់នូវខ្លឹមសារខ្លះៗក្នុងជំពូកណាមួយនៃអត្ថបទសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់។ ជួនកាលប្រធានគណៈកម្មការជំនាញអាចឡើងបកស្រាយទៅនឹងសំនួររបស់តំណាងរាស្ត្រដែលធ្វើការចោទសួរ ឬមានការស្រពិចស្រពិល។

ក្នុងដំណាក់កាលនៃការពិនិត្យខ្លឹមសារទាំងមូល អាចត្រូវបានបន្ថែមដោយការជជែកពិភាក្សាលើញត្តិ ជាយថាហេតុញត្តិនេះអាចនាំឱ្យមានការបដិសេធលើអង្គសេចក្តីនៃសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬនាំឱ្យមានការព្យួរការក្សាមុនពេលដែលការជជែកពិភាក្សា និងក្នុងការពិនិត្យលម្អិតចាប់ផ្តើម។

---

[១០] ប្រការ៥៩ ថ្មីបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា

[១១] ប្រការ ៥៨ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា

[១២] ប្រការ ៥៧ បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា

នៅក្នុងដំណាក់កាលពិនិត្យលើខ្លឹមសារទាំងមូល ជាដំណាក់កាលរាជរដ្ឋាភិបាលឡើងរាយការណ៍ និងសមាជិករដ្ឋសភាបញ្ចេញយោបល់របស់ខ្លួនចំពោះអត្ថបទសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់។ ឥរិយាបថរបស់រដ្ឋសភាអាចស្តែងឡើង តាមរយៈញត្តិនៃនិតិវិធីដែលមានការពិនិត្យពិចារណាទៅលើបញ្ហាទម្រង់កាលានុវត្តភាពនៃសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ និងទៅលើញត្តិបញ្ជូនទៅគណៈកម្មការជំនាញផងដែរ។

ញត្តិដែលមានលក្ខណៈជាបឋមសំណួរ ៖ សំដៅដល់ការពិនិត្យជាបឋមលើទម្រង់នូវសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដើម្បីឱ្យដឹងថា សេចក្តីព្រាងច្បាប់ ឬស្នើច្បាប់នោះត្រូវបានគេធ្វើឡើងដោយគោរពទៅតាមបែបបទនានាដូចមានចែងក្នុងប្រការ២២ ថ្មីនៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា ឬយ៉ាងណាដែលជាអាទ័រូមមានចែងជាជំពូក និងជាមាត្រាជាដើម។

ញត្តិបញ្ជូនទៅគណៈកម្មការ ៖ ញត្តិនេះមានកម្មវត្ថុពិនិត្យលើភាពខ្វះខាតការងាររបស់គណៈកម្មការ ពោលគឺអង្គសភាស្នើសុំឱ្យគណៈកម្មការជំនាញពាក់ព័ន្ធធ្វើការពិនិត្យបន្ថែមទៀត ប្រសិនបើរដ្ឋសភាយល់ឃើញថាជាការចាំបាច់សម្រាប់បំភ្លឺលើបញ្ហាស្មុគស្មាញ ឬមិនច្បាស់លាស់ ឬមានចំណុចណាមួយនៃសេចក្តីព្រាងច្បាប់ ឬស្នើច្បាប់នោះដែលអង្គសភាសម្រេចមិនបាន។

ការពិភាក្សាលើបឋមសំណួរ ជាធម្មតាត្រូវធ្វើ បន្ទាប់ពីការស្តាប់សេចក្តីរាយការណ៍របស់ប្រធានគណៈកម្មការជំនាញ មុននឹងការពិភាក្សាលើខ្លឹមសារទាំងមូល។ ចំនែកការពិភាក្សាញត្តិបញ្ជូនទៅគណៈកម្មការ ត្រូវចាប់ផ្តើមក្រោមការបិទពិភាក្សាលើខ្លឹមសារទាំងមូល។ ប្រសិនបើបញ្ហាញត្តិដែលមានលក្ខណៈបឋមសំនួរ ត្រូវបានអង្គសភាបដិសេធ នោះការពិភាក្សាលើខ្លឹមសារទាំងមូលត្រូវដំណើរការជាធម្មតា។ ហើយបើមានការបដិសេធញត្តិ បញ្ជូនទៅគណៈកម្មការនោះមានន័យថា ជាការបើកផ្លូវនៃការពិភាក្សាជាលក្ខណៈលម្អិត។

ការអនុម័តញត្តិដែលមានលក្ខណៈជាបឋមសំណួរ ធ្វើឱ្យមានការបដិសេធនូវសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលមានបឋមសំណួរនោះ។ ការអនុម័តញត្តិ ដែលមានលក្ខណៈជាបឋមសំណួរមានន័យថា អង្គសភាទាំងមូលអនុម័តយល់ព្រមថាសេចក្តីព្រាងច្បាប់ ឬស្នើច្បាប់ដែលដាក់ជូនអង្គសភា ពុំបានបំពេញនិតិវិធីនៃការបញ្ជូន ឬពុំបានបែងចែកជាជំពូកជាមាត្រាដែលមានចែងក្នុងប្រការ២២ថ្មី នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា។

ដូច្នេះការអនុម័តនេះនាំទៅដល់ការបញ្ចប់មុនពេលកំណត់នៃការពិភាក្សាដទៃទៀត ហើយវាមានអានុភាពដូចគ្នាទៅនឹងការបដិសេធសេចក្តីព្រាងច្បាប់ ឬស្នើច្បាប់ ក្រោយពីត្រូវរដ្ឋសភាធ្វើការពិនិត្យពិភាក្សាលម្អិតដែរ។

ការអនុម័តញត្តិបញ្ជូនទៅគណៈកម្មការ មានអានុភាពព្យួរការជជែកពិភាក្សាលើអត្ថបទនៃសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់រហូតដល់មានការឧទ្ទេសរបាយការណ៍ថ្មីដោយប្រធានគណៈកម្មការមានសមត្ថកិច្ច។

រីឯការពិភាក្សាលើអត្ថបទដែលចុះក្នុងរបៀបវារៈ ធម្មតាត្រូវស្របតាមបទប្បញ្ញត្តិនៃប្រការ១៩ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាជាអ្នករៀបចំរបៀបវារៈនៃពេលប្រជុំនីមួយៗ។ មុនពេលប្រជុំនីមួយៗ ប្រធានអានរបៀបវារៈសំរាប់ពេលប្រជុំបន្តទៅទៀត។

រដ្ឋសភា បើកការប្រជុំពិភាក្សាសារជាថ្មី បន្ទាប់ពីការព្យួរមួយរយៈ រដ្ឋសភាត្រូវស្ដាប់ការរាយការណ៍ជាថ្មីម្ដងទៀត រួចហើយទើបចាប់ផ្ដើមជជែកពិភាក្សាលើមាត្រាមួយម្ដងៗ ដែលមានចែងក្នុងប្រការ២៩ថ្មីចំណុច២តួច ។

[១៣]យោងតាមគោលការណ៍រយៈពេលនិយាយសម្រាប់អ្នកតំណាងរាស្ត្រក្នុងក្រុមនីមួយៗត្រូវមានកំណត់ ហើយត្រូវតែនិយាយតែពីប្រធានបទដែលកំពុងពិភាក្សា។ បើអ្នកនិយាយក្រៅប្រធានបទ ប្រធានត្រូវរំលឹកឲ្យធ្វើតាមរបៀបខាងលើនេះវិញ។ បើតំណាងរាស្ត្រក្នុងក្រុមនោះនៅចេសនិយាយក្រៅប្រធានបទដដែលប្រធានអង្គប្រជុំនោះអាចបញ្ឈប់វាគ្មិននោះកុំឲ្យនិយាយតទៅទៀត។

អ្នកតំណាងរាស្ត្រមានសិទ្ធិក្នុងការកែប្រែលើខ្លឹមសារលើផ្នែកខ្លះ ឬទាំងមូលក្នុងមាត្រាណាមួយ ឬជំពូកណាមួយដោយលើកពីបច្ចេកទេស និងមូលហេតុដែលខ្លួនសុំធ្វើការកែប្រែនោះ ដាក់ជូនអង្គសភាពិនិត្យថា តើគួរយកតាមការស្នើសុំការកែប្រែនោះ ឬក៏បដិសេធចោល ពេលនោះប្រធានអង្គប្រជុំអនុញ្ញាតឲ្យតំណាងរដ្ឋាភិបាល ឬប្រធានគណៈកម្មការជំនាញឡើងឆ្លើយតបថាគួរយកតាមការស្នើសុំកែប្រែ ឬបដិសេធចោល។ ការសំរេចយល់ព្រម ឬបដិសេធនូវចំនុចដែលតំណាងរាស្ត្រស្នើសុំកែប្រែនោះ គឺអាស្រ័យទៅតាមតំណាងរាជរដ្ឋាភិបាល និងប្រធានគណៈកម្មការជំនាញ។

## ២.១.២ទីស្តីការគណៈរដ្ឋមន្ត្រី

### ២.១.២.១ អន្តរក្រសួង

ការប្រព្រឹត្តទៅជាធម្មតានៃការជជែកពិភាក្សាក្នុងសម័យប្រជុំពេញអង្គ ជាការជជែកពិភាក្សាលំអិតត្រូវបានស្តែងឡើងនៅក្រោមលក្ខណៈពីរបែប[១៤] បានចែងថា អង្គសភាពិភាក្សា និងអនុម័តលើមាត្រាមួយម្តងៗក៏បាន ប្រធានគណៈកម្មការជំនាញធ្វើការសម្រេចថា តើគួរដាក់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះឲ្យអង្គសភាជជែកពិភាក្សា និងអនុម័តតាមនិតិវិធីណាមួយ ខាងលើដោយផ្អែកលើភាពស្មុគស្មាញ និងភាពលំបាកនៃសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះ។ ហើយការពិភាក្សាទៅលើមាត្រា ឬជំពូកមានលក្ខណៈដូចខាងក្រោមៈ

ការជជែកពិភាក្សាមួយមាត្រាម្តងៗ គឺដោយការស្នើសុំ របស់ប្រធានគណៈកម្មការជំនាញដោយមានការយល់ព្រមពីអង្គសភា ការជជែកពិភាក្សានេះ ត្រូវចាប់ផ្តើមមួយមាត្រាម្តងៗតាមលំដាប់លេខរៀងបន្តបន្ទាប់។ អ្នកតំណាងរាស្ត្រគ្រប់រូបដែលចង់ចូលរួមបញ្ចេញយោបល់ អាចធ្វើបទអន្តរាគមន៍បាន បន្ទាប់ពីបានទទួលការអនុញ្ញាតពីប្រធានអង្គប្រជុំជាមុនសិន។ បើតាមប្រការ៥៥ថ្មី នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភាចែងថា តំណាងរាស្ត្រក្នុងក្រុមនីមួយៗ ត្រូវសុំតាមរយៈតំណាងក្រុមរបស់ខ្លួន ហើយទទួលសេចក្តីអនុញ្ញាតពីប្រធានរដ្ឋសភាជាមុនសិន។

បទបញ្ជាផ្ទៃក្នុងរដ្ឋសភាកំណត់រយៈពេល និងបែបបទនៃការនិយាយចំពោះអ្នកតំណាងរាស្ត្រដែលសុំនិយាយ និងអ្នកតំណាងរាស្ត្រដែលគ្រាន់តែសុំឡើងឆ្លើយតបដូចមានចែងក្នុងប្រការ៥៩ថ្មី

[១៣] ប្រការ៨៥ថ្មី នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា

[១៤] ប្រការ២៩ថ្មី ចំណុច២ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា

បទបញ្ជាផ្ទៃក្នុងរដ្ឋសភា បានចែងថា តាមគោលការណ៍រយៈពេលនិយាយសម្រាប់តំណាងរាស្ត្រក្នុងក្រុមនីមួយៗត្រូវមានកំណត់ ហើយត្រូវនិយាយតែពីប្រធានបទដែលកំពុងពិភាក្សា។ បើនិយាយក្រៅប្រធានបទ ប្រធានត្រូវរំលឹកឲ្យធ្វើតាមរបៀបខាងលើនេះវិញ។

ដោយឡែកបើនៅក្នុងអង្គប្រជុំ ការជជែកពិភាក្សាបានក្លាយជាការជជែកដែលបណ្តាលឲ្យចលាចល ច្របូកច្របល់ ឥតសណ្តាប់ធ្នាប់ ហើយប្រធានហាមឃាត់ពុំស្តាប់ នោះប្រធានអាចផ្អាកការប្រជុំដោយក្រោកចេញពីសាលប្រជុំតែម្តង[១៥] ។

ការជជែកពិភាក្សាមួយជំពូកម្តងៗ ក្រោយពីមានការស្នើសុំពីគណៈកម្មការជំនាញជូនទៅគណៈកម្មការអចិន្ត្រៃយ៍រដ្ឋសភាឲ្យដាក់និតិវិធីនៃការពិភាក្សា និងអនុម័តមួយជំពូកម្តងៗជូនរដ្ឋសភាធ្វើការពិចារណារួចហើយ អង្គសភាទាំងមូលធ្វើការអនុម័តដោយលើកដៃយកតាមសម្លេងភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូលថា តើគួរពិភាក្សា និងអនុម័តលើសេចក្តីព្រាងច្បាប់ ឬស្នើច្បាប់តាមមួយមាត្រាម្តងៗ ឬមួយជំពូកម្តងៗ។

### ២.១.២.២ ប្រជុំពេញអង្គ

- **លក្ខខណ្ឌនៃការប្រជុំ**

រដ្ឋសភាអាចប្រជុំបាន លុះត្រាតែមានចំនួនសមាជិកយ៉ាងតិចស្មើនឹងប្រាំពីរភាគដប់នៃចំនួនសមាជិករដ្ឋសភាទាំងមូលបានចូលរួម។ ហើយការអនុម័តត្រូវធ្វើឡើងដូចខាងក្រោមៈ

**១-ចំពោះសេចក្តីព្រាងច្បាប់ ឬស្នើច្បាប់ធម្មតា** បើការអនុម័តលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ គោលការណ៍ត្រូវយកតាមសំលេងភាគច្រើនដាច់ខាត នៃចំនួនសមាជិករដ្ឋសភាទាំងមូល។

**២-ចំពោះច្បាប់ធម្មនុញ្ញ ឬបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា និងព្រឹទ្ធសភា** បើការអនុម័តលើច្បាប់រដ្ឋធម្មនុញ្ញ ឬបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា និងព្រឹទ្ធសភាត្រូវយកតាមសម្លេងពីរភាគបីនៃ សមាជិករដ្ឋសភាទាំងមូល។

ការជជែកពិភាក្សា និងអនុម័តលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ត្រូវធ្វើតាមលំដាប់លំដោយដូចខាងក្រោមៈ

- ជាបឋមត្រូវជជែកពិភាក្សា និងអនុម័តលើខ្លឹមសារទាំងមូល គឺបញ្ចេញមតិថា តើគួរទទួលការពិចារណាឬទេ?[១៦] ។
- បន្ទាប់មកជជែកពិភាក្សា និងអនុម័តមួយមាត្រាម្តងៗ ឬមួយជំពូកម្តងៗ។ បន្ទាប់ពីអង្គសភាធ្វើការពិភាក្សា និងអនុម័តលើខ្លឹមសារទាំងមូល រួចហើយអង្គសភានឹងឈានដល់ការពិភាក្សា និងអនុម័តមួយមាត្រាម្តងៗ ឬមួយជំពូកម្តងៗ អង្គសភាអាចប្រើនិតិវិធីជជែកពិភាក្សាសង្ខេបបាន ដោយពិភាក្សាតែមាត្រា ឬជំពូកណាដែលមានសំណើរធ្វើវិសោធនកម្មជាលាយលក្ខណ៍អក្សរ ដូចមានចែងក្នុងប្រការទាំងឡាយខាងលើនេះ។ នីតិវិធីប្រជុំជជែកពិភាក្សា និងអនុម័តនេះ តម្រូវឲ្យមានកូរ៉ុមប្រាំពីរភាគដប់នៃចំនួនសមាជិក

[១៥] ប្រការ៦១ បទបញ្ជាផ្ទៃក្នុងរដ្ឋសភា

[១៦] ប្រការ២៩ថ្មី ចំណុច១ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា

រដ្ឋសភាទាំងមូល[១៧] ហើយការអនុម័តត្រូវយកតាមមតិភាគច្រើនដាច់ខាត នៃសមាជិករដ្ឋសភាទាំងមូល[១៨] ។



ចំនែកការអនុម័តខាងលើ គឺធ្វើឡើងតាមការលើកដៃ។ ចំពោះការអនុម័តដោយលើកដៃលេខាអង្គប្រជុំទាំងឡាយជាអ្នករាប់ចំនួនសមាជិកដែលគាំទ្រ និងមិនគាំទ្រ រួចហើយលេខាអង្គប្រជុំនិងអង្គប្រជុំរដ្ឋសភាឲ្យបានដឹងពីលទ្ធផល។

សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ទាំងឡាយដែលរដ្ឋសភាអនុម័តរួចហើយ ត្រូវបញ្ជូនទៅព្រឹត្តសភាដើម្បីធ្វើការពិនិត្យ និងពិភាក្សាបន្ត[១៩] ។

- **ដំណាក់កាលប្រជុំជាសាធារណៈនៅព្រឹទ្ធសភា**

សេចក្តីព្រាងច្បាប់ ឬស្នើច្បាប់ដែលរដ្ឋសភាអនុម័តយល់ព្រមលើកដំបូងរួចហើយ ព្រមទាំងបញ្ហានានាដែលរដ្ឋសភាបានដាក់ឲ្យពិនិត្យ បញ្ជូនមកគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹត្តសភា[២០] ។

### ២.១.២.៣ត្រួតពិនិត្យស្រាវជ្រាវ

- **រយៈពេលពិនិត្យ និងផ្តល់យោបល់**

ព្រឹទ្ធសភាពិនិត្យហើយឲ្យយោបល់ក្នុងរយៈពេល១ខែយ៉ាងយូរលើសេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់ដែលរដ្ឋសភាបានដាក់ឲ្យពិនិត្យ។ បើជាការប្រញាប់រយៈពេលនោះ ត្រូវបន្ថយមកនៅត្រឹមតែប្រាំថ្ងៃ[២១]។ តាមខ្លឹមសារក្នុងមាត្រា១១៣ថ្មីខាងលើបញ្ជាក់ឲ្យឃើញថាសេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់ណាដែលរដ្ឋសភាប្រកាសជាការប្រញាប់ ព្រឹទ្ធសភាត្រូវជជែកពិភាក្សា និងអនុម័តលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះត្រឹមតែ៥ថ្ងៃប៉ុណ្ណោះ។ តែអ្នកស្នើសុំត្រូវជូនហេតុផលជាលាយលក្ខណ៍អក្សរ។ ប្រធានព្រឹទ្ធសភានាំសេចក្តីនោះទៅថ្លែងជម្រាបព្រឹទ្ធសភា ហើយព្រឹទ្ធសភាសម្រេចថា យល់ព្រម ឬមិនយល់ព្រមទុជាការប្រញាប់[២២]។

**១-ករណីដែលព្រឹទ្ធសភាយល់ព្រម ឬពុំបានឲ្យយោបល់** បើព្រឹទ្ធសភាបានឲ្យយោបល់ យល់ព្រម ឬពុំបានឲ្យយោបល់សោះក្នុងរយៈពេលដែលបានកំណត់ទុកហើយនោះទេ ច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមលើកទីមួយនោះ នឹងត្រូវបានយកទៅប្រកាសឲ្យប្រើ (ចូលជាធរមាន)[២៣] ។

**២-ករណីដែលព្រឹទ្ធសភាបដិសេធទាំងស្រុង** ក្នុងករណីដែលព្រឹទ្ធសភាបានបដិសេធ ចោលទាំងស្រុង រដ្ឋសភាមិនអាចលើកមកពិចារណាជាលើទី២បានមុនរយៈពេល១ខែទេ។ រយៈ ពេលនេះ ត្រូវ

---

[១៧] មាត្រា៨៨ វាក្យខណ្ឌ២ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

[១៨] មាត្រា៩០ថ្មី រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

[១៩] មាត្រា១១៣ថ្មីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

[២០] ប្រការ ២៣ វាក្យខណ្ឌ១ នៃបទបញ្ជាផ្ទៃក្នុងព្រឹត្តសភា

[២១] មាត្រា១១៣ ថ្មី វាក្យខណ្ឌ១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

[២២] ប្រការ៤៣នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា

[២៣] មាត្រា១១៣ថ្មីវាក្យខណ្ឌ២រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

បន្ថយមកត្រឹម១៥ថ្ងៃ បើពិនិត្យពីថវិកានិងហិរញ្ញវត្ថុ ហើយមកត្រឹមតែ២ថ្ងៃបើជា ការប្រញាប់។ ក្នុងការពិនិត្យជជែកពិភាក្សា និងអនុម័តនៅលើកទី២នេះរដ្ឋសភាប្រើវិធីបោះឆ្នោត ជាចំហ។

- **ការពិនិត្យជាលើកទីពីររបស់រដ្ឋសភា**

នៅពេលព្រឹទ្ធសភាបដិសេធទាំងស្រុង ឬមួយផ្នែកនៃអត្ថបទសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមលើកដំបូង ព្រឹទ្ធសភានឹងបញ្ជូនអត្ថបទច្បាប់នោះទៅឲ្យរដ្ឋសភាពិនិត្យសារជាថ្មី។ ពេលនោះរដ្ឋសភាត្រូវពិចារណាភ្លាមជាលើកទីពីរ ដោយពិនិត្យមើលតែចំណុចណាដែលព្រឹទ្ធសភាលើកសំណើរឲ្យកែសម្រួល។

**១-ករណីរដ្ឋសភាយល់ព្រមតាមសំណើររបស់ព្រឹទ្ធសភា** ក្នុងករណីនេះ បើរដ្ឋសភាយល់ព្រមតាមសំណើររបស់ព្រឹទ្ធសភាទាំងស្រុងលើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ដែលព្រឹទ្ធសភាពិនិត្យជាលើកទី២នោះ ត្រូវប្រកាសឲ្យប្រើតាមនិតិវិធីជាធរមាន។

**២-ករណីរដ្ឋសភាមិនយល់ព្រមតាមសំណើររបស់ព្រឹទ្ធសភា** បើក្នុងករណីដែលរដ្ឋសភាមិនយល់ព្រមតាមសំណើររបស់ព្រឹទ្ធសភា (ទាំងស្រុង ឬតែមួយផ្នែក) រដ្ឋសភាត្រូវបញ្ជូនសេចក្ដី ព្រាងច្បាប់ឬសេចក្ដីស្នើច្បាប់ដែលរដ្ឋសភាអនុម័តលើកដំបូងនោះត្រឡប់ទៅព្រឹទ្ធសភាវិញ។

## ២.២ រដ្ឋសភា

រដ្ឋសភា គឺជាអង្គការដែលមានអំនាចនីតិបញ្ញត្តិ និងបំពេញភារកិច្ចដូចដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ចុះថ្ងៃទី២៨ ខែ តុលា ឆ្នាំ១៩៩៣។

### ២.២.១ការដាក់ជូនសេក្ដីព្រាងច្បាប់ឬសេចក្ដីស្នើច្បាប់ទៅគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា

រាល់សេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ ត្រូវដាក់ជូនជាដំបូងមកគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ដើម្បីពិនិត្យ ហើយសម្រេចប្រគល់សេក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ នោះទៅឲ្យគណៈកម្មការជំនាញនានាក្នុងចំណោមគណៈកម្មការជំនាញទាំង៩របស់រដ្ឋសភា។ សេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ចែងជាមាត្រាហើយភ្ជាប់សេចក្ដី ថ្លែងហេតុមកជាមួយ។ គណៈកម្មាធិការអចិន្ត្រៃយ៍អាចប្រជុំបាន លុះត្រាតែសមាជិកច្រើនជាង ពាក់កណ្ដាលបានចូលរួម ឯការអនុម័តត្រូវយកតាមសំឡេងភាគច្រើនដាច់ខាត។ រដ្ឋាភិបាលមានលទ្ធភាពក្នុងការដាក់ជូននូវសេចក្ដីព្រាងច្បាប់របស់ខ្លួនមកសភា ឬព្រឹទ្ធសភា ។មានតែសេចក្ដីព្រាងច្បាប់ហិរញ្ញវត្ថុទេ ដែលត្រូវដាក់ជូនមករដ្ឋសភាមុនគេបង្អស់ជាចាំបាច់។ សេចក្ដីព្រាងច្បាប់របស់រដ្ឋាភិបាលត្រូវបញ្ជូនមកគណៈកម្មាការអចិន្ត្រៃយ៍រដ្ឋសភា។ គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភាបញ្ជូនសេចក្ដីនោះទៅគណៈកម្មការតាមមុខជំនាញឲ្យពិនិត្យ ។ កាលបើពិនិត្យរួចហើយ ប្រធាននៃគណៈកម្មាការអចិន្ត្រៃយ៍នោះត្រូវនាំយកយោបល់របស់គណៈកម្មាការមកជំរាបជូនសភា[២៤] ។ ផ្ទុយទៅវិញក្នុងករណីសេចក្ដីស្នើច្បាប់ធ្វើឡើងដោយតំណាងរាស្ត្រណាម្នាក់ គណៈកម្មាធិការត្រូវធ្វើការសន្និដ្ឋានពី

[២៤] ប្រការ២១នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា

អត្ថបទទាំងមូល។ ដូច្នេះគណៈកម្មាការអាចធ្វើការកែប្រែអត្ថបទស្នើនេះដោយផ្ទាល់ ហើយធ្វើការកែប្រែនេះទៀតសោតអាចនាំដល់ការបង្កើតជាអត្ថបទមួយថ្មីស្រឡាង។ រដ្ឋសភាធ្វើការប្រជុំអនុម័តលើអត្ថបទដែលជាលទ្ធផលការងាររបស់គណៈកម្មាការ ។ មានតែក្នុងករណីដែលគណៈកម្មាការធ្វើការសន្និដ្ឋានថា លើកចោលសេចក្តីស្នើ ឬមិនធ្វើការសន្និដ្ឋានប៉ុណ្ណោះ ដែលរដ្ឋសភាអាចធ្វើការពិភាក្សាលើសេចក្តីស្នើរបស់អ្នកតែងសេចក្តីច្បាប់នេះ។

- **គណៈកម្មាការអចិន្ត្រៃយ៍** គឺជាគណៈកម្មាធិការរបស់រដ្ឋសភាដេលរៀបចំរបៀបវារៈអង្គប្រជុំរដ្ឋសភា និងចាត់ចែងការងាររដ្ឋសភានៅចន្លោះសម័យប្រជុំ។ សមាសភាពនៃគណៈកម្មាធិការអចិន្ត្រៃយ៍មាន៖

| | |
|---|---|
| -ប្រធានរដ្ឋសភា | ជាប្រធាន |
| -អនុប្រធានទាំងពីរនៃរដ្ឋសភា | ជាសមាជិក |
| -ប្រធានគណៈកម្មការទាំង៩នៃរដ្ឋសភា | ជាសមាជិក |

ប្រធាននៃគណៈកម្មការ មានសិទ្ធិក្នុងការចូលរួមក្នុងកិច្ចការងាររបស់គណៈកម្មការ និងគណៈកម្មការមានសិទ្ធិក្នុងការការពារ វិសោធនកម្មនានារបស់គណៈកម្មការរបស់ខ្លួន។ តាមប្រការ ២៩ នៃបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា ចំពោះសេចក្តីព្រាងច្បាប់គណៈកម្មការអាចធ្វើការសន្និដ្ឋានថា អនុម័តយក ឬលើកចោល ឬធ្វើវិសោធនកម្ម។ ក្នុងករណីនេះ គណៈកម្មការគ្រាន់តែអាចចេញជាសំណើរតែប៉ុណ្ណោះ។ ប្រសិនបើគណៈកម្មការចង់ធ្វើការកែប្រែអត្ថបទនោះទាំងផ្នែកច្បាប់ និងផ្នែកទំរង់គណៈកម្មការត្រូវវាដាក់រដ្ឋសភានូវការធ្វើវិសោធនកម្មរបស់ខ្លួន។

- **ការតំកល់សេចក្តីព្រាងច្បាប់និងសេចក្តីស្នើច្បាប់**

សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ត្រូវបានចុះក្នុងបញ្ជីនៃរបៀបវារៈនៅថ្ងៃទទួល ដើម្បីកំណត់លំដាប់លេខក្នុងចំនោមឯកសាររបស់សភាដែលមានប្រភេទដូចគ្នាជាអាទិ៍ ជាមួយនឹងសំណុំឯកសាររបស់គណៈកម្មការ។ ការតំកល់តាមន័យច្បាប់មានទំរង់ជាសេចក្តីប្រកាសមួយក្នុងការប្រជុំជាសាធារណៈ ដែលជាទូទៅ ត្រូវបានគេប្រកាសជូនដំណឹងនៅចុងបញ្ចប់នៃរបាយការណ៍ទាំងមូលរបស់អង្គប្រជុំ។ អត្ថបទច្បាប់ដែលបានតំកល់ទុកត្រូវបានបញ្ជូនទៅគណៈកម្មការជំនាញនានាដើម្បីត្រួតពិនិត្យ បន្ទាប់ត្រូវបានថតចម្លង និងចុងបញ្ចប់ត្រូវបានចែកជូននៅក្នុងអង្គប្រជុំ។ នៅពេលអត្ថបទច្បាប់មួយត្រូវបានបញ្ជូនមកសភា នៅចន្លោះពេលពីនីតិកាលមួយទៅនីតិកាលមួយទៀត ការតំកល់ត្រូវធ្វើជាកម្មវត្ថុ (ដោយមិនចាំបាច់បវេសនកាលរបស់សភា) នៃការប្រកាសមួយដែលត្រូវបានចុះនៅក្នុងរាជកិច្ច។

### ២.២.១.១ការចុះក្នុងរបៀបវារៈ

សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់មួយមិនអាចដាក់ជូនអង្គប្រជុំពិភាក្សាទេ បើសិនសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះមិនបានធ្វើជាកម្មវត្ថុជាមុននៃសេចក្តីរាយការណ៍របស់គណៈកម្មការមានសមត្ថកិច្ចទៅតាមបទបញ្ញាត្តិ ដែលបានកំណត់ដោយបទបញ្ជាផ្ទៃក្នុងសភា[២៥]។ ម្យ៉ាង

[២៥] ប្រការ២១នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា

ទៀតសេចក្តីថ្លែងការណ៍ ឬថ្លែងហេតុនានារបស់គណៈកម្មការត្រូវដាក់ជូនថតចម្លង និងចែកជូនក្នុងរយៈពេលមួយដែលរដ្ឋសភាមានលទ្ធភាពក្នុងការពិភាក្សាលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ទាំងនោះ។ ដើម្បីអាចធ្វើជាកម្មវត្ថុនៃការពិភាក្សាជាសាធារណៈ សេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់ត្រូវបានគេចុះក្នុងរបៀបវារៈជាមុនសិន។ គណៈកម្មាការអចិន្ត្រៃយ៍រដ្ឋសភាជាអ្នករៀបរៀងរបៀបវារៈនៃពេលប្រជុំនីមួយៗ[២៦] ។ រីឯប្រការ២០វិញបានចែងថា របៀបវារៈមានសេចក្តីជាលំដាប់មុនក្រោយដូចតទៅ៖

- របៀបវារៈ ឬ បញ្ហាទាំងឡាយ ដែល ព្រឹទ្ធសភាបានសំរេចថាជាការប្រញាប់
-បញ្ហាទាំងឡាយណាដែល រដ្ឋសភាជូនមកព្រឹទ្ធសភា។
-បញ្ហាទាំងឡាយណាដែល រដ្ឋសភាជូនមកព្រឹទ្ធសភា។
- បញ្ហាទាំងឡាយណាដែល គណៈកម្មាការនានាជូនមកព្រឹទ្ធសភា។
- បញ្ហាទាំងឡាយណាដែល សមាជិក រដ្ឋសភា ជូនមកព្រឹទ្ធសភា។

ផ្អែកតាមបញ្ញត្តិនៃប្រការខាងលើ យើងឃើញថា របៀបវារៈមានតែពីរបែបពោលគឺ របៀបវារៈជាអាទិភាព និងរបៀបវារៈបន្ថែម ឬរបៀបវារៈធម្មតា។

**របៀបវារៈ ជាអាទិភាព**

សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ក៏ដូចជាញត្តិផ្សេងៗដែលត្រូវបានប្រកាសថា ជាការប្រញាប់ត្រូវចុះក្នុងរបៀបវារៈពិភាក្សាមុនគេ[២៧]។ បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា ទទួលស្គាល់សិទ្ធិរបស់រដ្ឋាភិបាលក្នុការស្នើសុំដាក់សេចក្តីព្រាងច្បាប់ ដែលខ្លួនចង់ឲ្យរដ្ឋសភាធ្វើការពិភាក្សា និងអនុម័តជាមួយនឹងលំដាប់លេខរៀងសម្រាប់ការពិចារណាមុន និងក្រោយផងដែរ។ តាមការអនុម័តជាក់ស្តែងការដែលស្នើឡើងដោយរដ្ឋាភិបាល ឬដោយតំណាងរាស្ត្រ ឬដោយម្ចាស់ញត្តិ ត្រូវភ្ជាប់មកជាមួយលិខិតបញ្ជាក់ហេតុផល ហើយពន្យល់បកស្រាយនូវបញ្ហានានា ដែលខ្លួនសុំឲ្យដាក់ជាការប្រញាប់។ ក្រោយពីបានទទួលពាក្យសុំដាក់អត្ថបទសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬញត្តិណាមួយជាការប្រញាប់ហើយនោះ គណៈកម្មាការអចិន្ត្រៃយ៍ត្រូវសម្រេចលើពាក្យសុំនោះភ្លាមបន្ទាប់ពីប្រធានបានអានសេចក្តីរាយការណ៍ ឬសេចក្តីថ្លែងហេតុជម្រាបជូនអង្គប្រជុំគណៈកម្មាការអចិន្ត្រៃយ៍។ការសម្រេចនេះអាចជាការយល់ព្រម ឬមិនយល់ព្រមទុកអត្ថបទនោះជាការប្រញាប់[២៨]។

- **របៀបវារៈបន្ថែម ឬ របៀបវារៈធម្មតា**

ជាទូទៅរបៀបវារៈបន្ថែមនេះ ច្រើនតែជាបញ្ហាទាំងឡាយដែលរាជរដ្ឋាភិបាលជូនមកសភា ហើយបញ្ហាទាំងនេះពុំមែនជាបញ្ហាដែលត្រូវបានរដ្ឋាភិបាលស្នើសុំជាការប្រញាប់ទេ។ ការរៀបចំរបៀបវារៈ ជាសមត្ថកិច្ចរបស់គណៈកម្មាការអចិន្ត្រៃយ៍នៃរដ្ឋសភា។ ហើយដែលតាមរយៈបទបញ្ញត្តិនៃប្រការ១៩ បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា ប្រធានអង្គប្រជុំនៃគណៈកម្មាការអចិន្ត្រៃយ៍ត្រូវអាន

---

[២៦] ប្រការ១៩ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា

[២៧] ប្រការ៥៤បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា

[២៨] ប្រការ ៥៤ និង ៥៦ បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា

របៀបវារៈ សម្រាប់ពេលប្រជុំនីមួយៗ ។ របៀបវារៈបន្ថែមនេះពុំមែនមានតែចំពោះសេចក្តីព្រាងច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែវាក៏មានសេចក្តីស្នើច្បាប់ផងដែរ។ ការកំណត់របៀបវារៈ គឺជាការបើកផ្លូវនៃការពិភាក្សាជាលើកដំបូងរបស់រដ្ឋសភា មុននឹងឈានដល់ការអនុម័តលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់។



## ២.២.២ ភាពិភាក្សាក្នុងគណៈកម្មការជំនាញ

គណៈកម្មការពិភាក្សាយ៉ាងលំអិតលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលបានទទួលពីគណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា ដោយមានការចូលរួមពីតំណាងរាជរដ្ឋាភិបាលបើជាសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ពីសមាជិករដ្ឋសភា ឬពីសមាជិកព្រឹទ្ធសភា។ តំណាងទាំងនេះមានសិទ្ធិឆ្លើយបំភ្លឺចំពោះសំនួរដែលគណៈកម្មការជំនាញសួរ។ តំណាងគណៈកម្មការដទៃទៀតរបស់រដ្ឋសភាតំណាងអង្គការក្រៅរាជរដ្ឋាភិបាល និងសង្គមស៊ីវិល អាចចូលរួមបានតាមការអញ្ជើញរបស់គណៈកម្មការ។ អ្នកតំណាងសង្គមស៊ីវិល គ្មានសិទ្ធិចូលរួមក្នុងការអនុម័តឡើយ។ ប្រធានគណៈកម្មការជំនាញ ត្រូវឡើងរាយការណ៍អំពីយោបល់របស់គណៈកម្មការជំនាញរបស់ខ្លួន ដែលបានធ្វើការពិនិត្យ និងពិភាក្សាយ៉ាងហ្មត់ចត់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ជូនរដ្ឋសភា ដើម្បីធ្វើការជជែកពិភាក្សាលើអត្ថបទសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នេះ។ សេចក្តីរាយការណ៍នេះត្រូវបង្ហាញពីឆន្ទៈរបស់គណៈកម្មការជំនាញ និងអំពីវិសោធនកម្មទាំងឡាយលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ហើយត្រូវចំលងចែកជូនសមាជិករដ្ឋសភាទាំងអស់ ឲ្យបានមុនថ្ងៃប្រជុំអនុម័តសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់នោះ ។

គណៈកម្មការជំនាញអាចប្រជុំបាន លុះត្រាតែសមាជិកច្រើនជាងពាក់កណ្តាលបានចូលរួម ឯការអនុម័តត្រូវយកតាមសំលេងភាគច្រើនដាច់ខាតនៃចំនួនគណៈកម្មការ[២៩] ។

បើយោងតាមប្រការ២៩ថ្មី នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភាចែងថា ការពិភាក្សាលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ត្រូវធ្វើដូចតទៅៈ ពិនិត្យពិចារណាលើខ្លឹមសារទាំងមូលសិនរួចទើបពិភាក្សាលើមាត្រាមួយម្តងៗ ឬមួយជំពូកម្តងៗក៏បាន វៀរលែងតែសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលទាក់ទងនឹងថវិការជាតិ ការបើកឥណទានថ្មី ការបន្ថែម ឬការបង្កើតមុខចំណូលថ្មី។

ដូច្នេះ ការពិភាក្សារបស់រដ្ឋសភាត្រូវធ្វើឡើងតាមពីរដំណាក់កាល ៖

- **ដំណាក់កាលនៃការពិនិត្យខ្លឹមសារទាំងមូល** ៖ ជាដំណាក់កាលដែលរាជរដ្ឋាភិបាល គណៈកម្មការពាក់ព័ន្ធ និង អ្នកតំណាងរាស្ត្រត្រូវបង្ហាញឥរិយាបថរបស់ខ្លួន ។
- **ដំណាក់កាលនៃការពិនិត្យលំអិត** ៖ ជាដំណាក់កាលដែលសភាពិនិត្យលើមាត្រា ឬ ជំពូកនីមួយៗមុននឹងសំរេចលើសេចក្តីព្រាងច្បាប់ ឬ សេចក្តីស្នើច្បាប់ទាំងមូល ។

### ២.២.២.១ ដំណាក់កាលនៃការពិនិត្យខ្លឹមសារទាំងមូល

នៅពេលនោះ តំណាងរាជរដ្ឋាភិបាល ប្រធានគណៈកម្មការ ឬសមាជិកគណៈកម្មការដែល

[២៩] ប្រការ ១០ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា

ពាក់ព័ន្ធ និងតំណាងរាស្ត្រត្រូវបញ្ចេញយោបល់របស់ខ្លួន។ ដំណាក់កាលនៃការពិនិត្យពិភាក្សា និងម័តលើខ្លឹមសារទាំងមូល ជាដំណាក់កាលដ៏សំខាន់បំផុត ក្នុងការផ្តល់ជាយោបល់ក្នុងការកែសម្រួល ឬបំពេញនូវការខ្វះចន្លោះនៃអត្ថបទសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ពោលគឺវាគ្មិនទាំងអស់ត្រូវបរិយាយ ដើម្បីឲ្យអង្គសភាយល់ពីហេតុផលដែលខ្លួនចង់កែសម្រួល ឬបំពេញនូវការខ្វះចន្លោះនៃអត្ថបទសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ក្នុងន័យសុំឲ្យអង្គសភាសម្រេចថា តើគួរពិចារណា ឬមិនគួរពិចារណាលើសំណើរបស់ខ្លួន។ បន្ទាប់មកប្រធានអង្គប្រជុំស្នើឲ្យអង្គសភា អនុម័តលើខ្លឹមសារទាំងមូលនៃសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់[៣០]។ ក្នុងការជជែកពិភាក្សា គឺតម្រូវឲ្យវាគ្មិនទាំងអស់ដែលបានចូលរួមមានសិទ្ធិធ្វើបទអន្តរាគមន៍ដែលអ្នកទាំងនោះរួមមាន រដ្ឋាភិបាល ប្រធានគណៈកម្មការ ឬសមាជិកគណៈកម្មការជំនាញ និងអ្នកតំណាងរាស្ត្រ។ ប៉ុន្តែត្រូវសុំទទួលសេចក្តីអនុញ្ញាតពីប្រធានជាមុនសិន ទើបនិយាយបាន[៣១]។

ដំណាក់កាលនេះ ជាដំណាក់កាលដែលរាជរដ្ឋាភិបាលឡើងរាយការណ៍ និងសមាជិករដ្ឋសភាបញ្ចេញយោបល់របស់ខ្លួនចំពោះអត្ថបទសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់។ ឥរិយាបថរបស់រដ្ឋសភា អាចស្តែងឡើងតាមរយៈញត្តិនៃនីតិវិធី ដែលមានការពិនិត្យពិចារណាទៅលើបញ្ហាទម្រង់ បញ្ហាកាលានុវត្តភាពនៃសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ និងទៅលើញត្តិបញ្ជូនទៅគណៈកម្មការជំនាញផងដែរ។

### ២.២.២.២ដំណាក់កាលនៃការពិនិត្យលំអិត

ការពិភាក្សាមួយមាត្រាម្តងៗ ឬមួយជំពូកម្តងៗដូចមានចែងក្នុងប្រការ២៩នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា។ ដំណាក់កាលភាគច្រើន ត្រូវចាប់ផ្តើមដោយការពិភាក្សាលើសំណើរកែប្រែដែលអនុវត្តតាមមធ្យោបាយនៃការធ្វើវិសោធនកម្ម។ ពាក្យសុំធ្វើវិសោធនកម្មនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរជូនទៅគណៈកម្មការជំនាញក៏បាន រឺជូនទៅរដ្ឋសភាក្នុងពេលប្រជុំពេញអង្គក៏បាន[៣២]។ ពាក្យសុំធ្វើវិសោធនកម្ម ត្រូវភ្ជាប់មកជាមួយនូវសេចក្តីថ្លែងហេតុសង្ខេបមួយច្បាប់ដែលប្រាប់ពីឆន្ទៈ និងហេតុផលរបស់អ្នកស្នើសុំ ជាពិសេសត្រូវទាក់ទងយ៉ាងច្បាស់លាស់ទៅនឹងការកែប្រែ។ ពាក្យសុំធ្វើវិសោធនកម្ម ត្រូវដាក់ជូនអង្គសភាពិនិត្យពិចារណាថា តើយល់ព្រម រឺមិនយល់ព្រមយកពាក្យសុំនោះមកពិភាក្សា[៣៣] ។

ចំពោះវិសោធនកម្មដែលមានលក្ខណៈ និងទ្រង់ទ្រាយធំជាអាទិ៍វិសោធនកម្មដែលប៉ះពាល់ដល់ខ្លឹមសារទាំងមូល រឺ អត្ថន័យជាសារវន្តរបស់សេចក្តីព្រាងរឺស្នើច្បាប់ ប្រធានរដ្ឋសភារឺប្រធានអង្គប្រជុំប្រកាសចាត់តាំងគណៈកម្មាការពិសេស [៣៤]។

---

[៣០] ប្រការ២៩ថ្មី បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា

[៣១] ប្រការ ៥៥ បទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា

[៣២] ប្រការ ២៦នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា

[៣៣] ប្រការ ២៧ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា

[៣៤] ប្រការ ១១ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា

ថ្វីត្បិតតែរដ្ឋសភាទទួលពាក្យសុំធ្វើវិសោធនកម្មក្នុងសម័យប្រជុំពេញអង្គក៏ដោយ ក៏អង្គសភាមិនអាចធ្វើការអនុម័តលើវិសោធនកម្មក្នុងថ្ងៃដែលទទួលពាក្យសុំនោះបានដែរ លើកលែងតែជាការប្រញាប់[៣៥] តែតាមការអនុវត្តជាក់ស្តែងត្រូវបានដាក់តំកល់ទុកក្នុងរយៈពេលមួយដែលប្រែប្រួលទៅតាមការងាររបស់គណៈកម្មការជំនាញ បានន័យថា វាយូរ រឺឆាប់អាស្រ័យលើរយៈពេលនៃការពិនិត្យរបស់គណៈកម្មការ ។

ការពិភាក្សាលំអិត ត្រូវបានស្តែងឡើងក្រោមលក្ខណៈពីរបែបនេះ បើផ្អែកតាមប្រការ២៩ ពោលគឺការអនុម័តមួយជំពូកម្តងៗ រឺ មួយមាត្រាម្តងៗ ។

ការពិភាក្សាមួយមាត្រាម្តងៗ ត្រូវចូលរួមដោយបទអន្តរាគមន៍របស់គណៈកម្មការជំនាញដែលត្រូវបានប្តឹងដល់អង្គសេចក្តី រឺដោយបទអន្តរាគមន៍ដែលមានលក្ខណៈជាយោបល់ និងព្រមជាមួយគ្នានេះដែរ ការពិភាក្សានេះត្រូវចាប់ផ្តើមម្តងមួយមាត្រាៗ តាមលំដាប់លេខរៀងជាបន្តបន្ទាប់ (ដូចបានរៀបរាប់ក្នុងបទអន្តរាគមន៍)។ ប៉ុន្តែបើក្នុងការប្រជុំការពិភាក្សាបានក្លាយជាការជជែកមួយដែលបង្កឲ្យចលាចល ច្របូកច្របល់ បាត់សណ្តាប់ធ្នាប់ ហើយប្រធានហាមឃាត់ពុំស្តាប់នោះ ប្រធានអាចផ្អាកការប្រជុំដោយក្រោកដើរចេញពីសាលប្រជុំតែម្តង[៣៦] ។

ការពិភាក្សាមួយជំពូកម្តងៗ ក្រោយពីមានការស្នើសុំរបស់គណៈកម្មការជំនាញ ជូនទៅគណៈកម្មការអចិន្ត្រៃយ៍រដ្ឋសភាអោយដាក់នីតិវិធីនៃការពិភាក្សាអនុម័តមួយជំពូកម្តងៗ ជូនរដ្ឋសភាធ្វើការពិចារណា អង្គសភាទាំងមូលធ្វើការអនុម័តដោយសំលេងភាគច្រើននៃសមាជិករដ្ឋសភាទាំងមូលថា តើគួរអនុម័តសេចក្តីព្រាងច្បាប់ រឺសេចក្តីស្នើច្បាប់តាមមួយមាត្រាម្តងៗ រឺមួយជំពូកម្តងៗ។ នីតិវិធីនេះប្រើបានចំពោះតែសេចក្តីណាដែលមានលក្ខណៈងាយយល់តែប៉ុណ្ណោះ ផ្ទុយទៅវិញបើសេចក្តីស្នើ រឺសេចក្តីព្រាងណាដែលមានភាពស្មុគស្មាញជាអាទិ៍ដូចជាច្បាប់ថវិកា អង្គសភាត្រូវធ្វើការពិភាក្សាមួយជំពូកម្តងៗ ដោយពិនិត្យលើគ្រប់មាត្រាទាំងអស់បានន័យថា គេត្រូវអនុវត្ត នីតិវិធីនៃការអនុម័តមួយមាត្រាម្តងៗ ។ ការពិភាក្សាម្តងមួយជំពូក រឺមួយមាត្រាម្តងៗ ជានិច្ចកាល តែងត្រូវបានចាប់ផ្តើមដោយការពិនិត្យលើវិសោធនកម្ម ដែលអនុម័តត្រូវធ្វើតាមនីតិវិធីធម្មតា និងដោយមតិភាគច្រើនរបស់សមាជិករដ្ឋសភា[៣៧] ។

**វិសោធនកម្ម៖** ការលើកយកវិសោធនកម្មមកពិនិត្យមានសារប្រយោជន៍ចាំបាច់ណាស់សំរាប់ដំណើរការនៃការជជែកពិភាក្សា ព្រោះថាការអនុម័តសំណើរសុំធ្វើវិសោធនកម្មទាំងឡាយ៖

- បណ្តាលឲ្យមានការលុបចោលដោយស្វ័យប្រវត្តិ នូវពាក្យសុំធ្វើវិសោធនកម្មដទៃទៀតដែលមានលក្ខណៈស្រដៀងគ្នានោះ បានន័យថា អង្គសភាពុំលើកយកពាក្យសុំធ្វើវិសោធនកម្មផ្សេងទៀត ដែលនិយាយពីបញ្ហាតែមួយជាមួយនឹងវិសោធនកម្មដែលរដ្ឋសភាបានអនុម័តរួចហើយ។ គោលការណ៍ជាមូលដ្ឋាន នៃការដាក់បញ្ចូលវិសោធនកម្មច្រើនទៅក្នុងមាត្រាតែមួយ តំរូវឲ្យអង្គសភាធ្វើការពិចារណា ទៅលើវិសោធនកម្មដែលមានលក្ខណៈ

[៣៥] ប្រការ ២៨ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា
[៣៦] ប្រការ ៦១នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា
[៣៧] ប្រការ ៤១ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា

ទូទៅជាមុនសិន រួចទើបពិចារណាលើករណីដោយឡែកណាមួយជាអាទិ៍ការលុបចោលមាត្រាណាមួយ ត្រូវយកមកពិភាក្សាមុនការលុបវាក្យខណ្ឌ ហើយការលុបវាក្យខណ្ឌនេះត្រូវធ្វើការលុបឃ្លានៅក្នុងវាក្យខណ្ឌនោះ។ ក្នុងការអនុវត្តជាក់ស្តែងវិសោធនកម្មតែទៅលើមាត្រាមួយ ដែលស្នើឡើងដោយអ្នកតំណាងរាស្ត្រច្រើនរូប អាចនឹងត្រូវដាក់អោយជជែកពិភាក្សាក្នុងពេលតែមួយបាន ហើយដែលក្នុងពេលនោះអ្នកសុំវិសោធនកម្មអាចលើកយកទឡ្ហីករណ៍ផ្សេងៗមកពន្យល់បកស្រាយសំដៅការពារសំណើររបស់ខ្លួនបាន ។

- **ការកែប្រែ រឺ ការកែតំរូវវិសោធនកម្ម ៖** ការកែប្រែលើវិសោធនកម្មលើសេចក្តីព្រាង រឺសេចក្តីស្នើច្បាប់ពុំប្លែកពីការសុំធ្វើវិសោធនកម្មទេ ប៉ុន្តែការកែប្រែនេះ ធ្វើឲ្យនីតិវិធី ក្នុងការ ពិនិត្យ និងអនុម័តកាន់តែសាំញ៉ាំ ស្មុគស្មាញខ្លាំងឡើងមួយកំរិតទៀត ព្រោះវាតំរូវឲ្យ វិសោធនកម្មលើសេចក្តីព្រាង រឺ សេចក្តីស្នើច្បាប់ ត្រូវបានអង្គសភាយកមកពិភាក្សាជាមុន រួចហើយយកសំណើរសុំកែប្រែ រឺកែតំរូវលើវិសោធនកម្មមកពិចារណាជាបន្ទាប់ នៅក្នុង លក្ខខ័ណ្ឌដដែលដូចគ្នាចំពោះវិសោធនកម្មដែរ។ ក្នុងករណីនេះតំរូវឲ្យអ្នកសុំកែប្រែចង្អុលបង្ហាញឲ្យច្បាស់ថា តើខ្លួនចង់ឲ្យសភាអនុម័តលើផ្នែកណា រឺចំនុចណាមួយនៃវិសោធនកម្មនោះ ពោលគឺវាអាចជាវាក្យខ័ណ្ឌ ទីមួយអាចជាឃ្លា រឺជាពាក្យមួយ រឺពីរម៉ាត់ ។ ក្នុងការអនុវត្តលិខិតកែតំរូវច្រើនត្រូវបានអនុវត្តដោយរាជរដ្ឋាភិបាល ហើយដែលលិខិតនោះត្រូវបានដាក់ជូនគណៈកម្មធិការអចិន្ត្រៃយ៍រដ្ឋសភា រឺ គណៈកម្មការជំនាញរឺការកែតំរូវ លើចំនុចតូចៗដូចជាពាក្យ រឺផ្លាស់ប្រយោគភាគច្រើន ច្រើនតែអ្នកតំណាងរាស្ត្រជាអ្នកធ្វើដោយផ្ទាល់មាត់ ។

មាត្រាបន្ថែម ក្រៅពីការសុំធ្វើវិសោធនកម្មលើសេចក្តីព្រាង រឺសេចក្តីស្នើច្បាប់គេសង្កេតឃើញមានការសុំបញ្ចូលមាត្រាថ្មីបន្ថែមលើសេចក្តីនោះ។ មាត្រាបន្ថែមមានន័យផ្សេងពីវិសោធនកម្មដោយហេតុថា វាពុំមានកម្មវត្ថុកែប្រែសេចក្តីព្រាង រឺ សេចក្តីស្នើច្បាប់ទេ តែវាត្រូវបានគេស្នើឡើងក្នុងគោលបំណងបំពេញបន្ថែមនូវភាពខ្វះចន្លោះ នៃសេចក្តីទាំងពីរសំដៅធ្វើឲ្យអត្ថបទទាំងនេះមានលក្ខណៈពេញលេញ។ ការស្នើសុំដាក់បន្ថែមនូវមាត្រាថ្មីៗ បានផ្តល់ឲ្យអ្នកសុំនូវសិទ្ធិក្នុងការបញ្ចេញយោបល់ដូចគ្នានឹងសិទ្ធិរបស់អ្នកធ្វើសេចក្តីព្រាង រឺសេចក្តីស្នើច្បាប់ដែរ។ ក្រោយពីការពិនិត្យ និងអនុម័តចប់សព្វគ្រប់លើមាត្រានីមួយៗ រឺលើជំពូកនីមួយៗ ព្រមទាំងវិសោធនកម្មក៏ដូចជាលើមាត្រាបន្ថែមរួចមក អង្គសភាទាំងមូលអាចពិនិត្យកែប្រែចំណងជើង រឺ ឈ្មោះមាតិកានៃអត្ថបទច្បាប់បានបើសិនការអនុម័តលើវិសោធនកម្មនានាធ្វើឲ្យប៉ះពាល់ដល់ចំនងជើងនៃអត្ថបទនោះ ។

- **ដំណាក់កាលជជែកពិភាក្សាលំអិត**

ដំណាក់កាលជជែកពិភាក្សាលំអិត ជាដំណាក់កាលមួយឈានដល់ការជជែកពិភាក្សាមួយមាត្រាម្តងៗ រឺមួយជំពូកម្តងៗដូចដែលមានចែងក្នុង[៣៨] គឺជាការចាប់ផ្តើមនៃដំណាក់កាលមួយដែលក្នុងពេលនោះ រដ្ឋសភាធ្វើការជជែក និងពិនិត្យដោយហ្មត់ចត់បំផុត ទៅលើអត្ថបទនៃសេចក្តីព្រាង

[៣៨] ប្រការ២៩ថ្មីនៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា

ច្បាប់ រឺសេចក្តីស្នើច្បាប់ដែលគណៈកម្មការអចិន្ត្រៃយ៍នៃរដ្ឋសភាបានដាក់ជូន ក្នុងខណៈពេលនោះការជជែកពិភាក្សាដែលធ្វើឡើងដោយមានយោបល់ច្រើនផ្សេងៗគ្នា ទៅជាការដោះដូរទឡ្ហីករណ៍ដែលមានលក្ខណៈបច្ចេកទេសផង និងប្រកបដោយសុក្រិតភាពផង។ ក្នុងការជជែកពិភាក្សាវាគ្មិនត្រូវនិយាយឆ្លាស់គ្នា អ្នកគាំទ្រនិយាយម្តង រួចអ្នកជំទាស់និយាយម្តង[៣៩] ហើយវាគ្មិនដែលបានការអនុញ្ញាតពីប្រធាន ដើម្បីឡើងបញ្ចេញមតិរបស់ខ្លួន ដោយគ្រាន់តែឡើងនៅនឹងអសនៈរបស់ខ្លួនផ្ទាល់ ដោយពុំចាំបាច់ឡើងលើវេទិកាទេ ។

### ២.២.៣ការពិភាក្សា និងការអនុម័តក្នុងសម័យប្រជុំពេញអង្គ

ការប្រព្រឹត្តទៅជាធម្មតានៃការជជែកពិភាក្សាក្នុងសម័យប្រជុំពេញអង្គ ជាការជជែកពិភាក្សាលម្អិតត្រូវបានស្តែងឡើងនៅក្រោមលក្ខណៈពីរបែបដោយយោងតាម[៤០]បានចែងថា អង្គសភាពិភាក្សានឹងអនុម័តលើមាត្រាមួយម្តងៗក៏បាន ប្រធានគណកម្មការជំនាញធ្វើការសម្រេចថា តើគួរដាក់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះ។ ហើយការជជែកពិភាក្សាទៅលើមាត្រា ឬជំពូកមានលក្ខណៈដូចខាងក្រោម៖

- ការជជែកពិភាក្សាមួយមាត្រាម្តងៗ ការពិភាក្សាបែបនេះ គឺដោយការស្នើសុំរបស់ប្រធានគណៈកម្មការជំនាញ ដោយមានការយល់ព្រមពីអង្គសភា ការជជែកពិភាក្សានេះត្រូវចាប់ផ្តើមមួយមាត្រាម្តងៗតាមលំដាប់លេខរៀងបន្តបន្ទាប់។

អ្នកតំណាងរាស្ត្រគ្រប់រូបដែលចង់ចូលរួមបញ្ចេញយោបល់អាចធ្វើបទអន្តរាគមន៍បាន បន្ទាប់ពីបានទទួលការអនុញ្ញាតពីប្រធានអង្គប្រជុំជាមុនសិន។ បើតាមប្រការ៥៥ថ្មី នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភាចែងថា តំណាងរាស្ត្រក្នុងក្រុមនីមួយៗត្រូវសុំតាមរយៈតំណាងក្រុមរបស់ខ្លួន ហើយទទួលសេចក្តីអនុញ្ញាតពីប្រធានរដ្ឋសភាជាមុនសិនទើបអាចនិយាយបាន។ ហើយដែលការសុំនិយាយនេះអាចធ្វើបានរហូតដល់វិនាទីចុងក្រោយនៃការប្រជុំ។

- ❖ **លក្ខខណ្ឌនៃការប្រជុំ**

រដ្ឋសភាអាចប្រជុំបាន លុះត្រាតែមានសមាជិកចំនួនយ៉ាងតិចស្មើនឹងប្រាំពីរភាគដប់នៃចំនួនសមាជិករដ្ឋសភាទាំងមូលបានចូលរួម។ ហើយការអនុម័តត្រូវធ្វើឡើងតាមលក្ខខណ្ឌដូចខាងក្រោម៖

១-ចំពោះសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ធម្មតា បើការអនុម័តលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់គោលការណ៍ ត្រូវយកតាមសម្លេងភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល។

២-ចំពោះច្បាប់ធម្មនុញ្ញ ឬបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា និងព្រឹទ្ធសភា ត្រូវយកតាមសម្លេងពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល។

ការជជែកពិភាក្សា និងអនុម័តលើសេចក្តីព្រាងច្បាប់ ឬស្នើច្បាប់ត្រូវធ្វើតាមលំដាប់លំដោយដូចតទៅ៖

---

[៣៩] ប្រការ៥៧នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា

[៤០] ប្រការ២៩ថ្មី ចំណុច២ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា

▪ ជាបឋមត្រូវជជែកពិភាក្សា និងអនុម័តលើខ្លឹមសារទាំងមូល គឺបញ្ចេញមតិថា តើគួរទទួលពិចារណាវឺទេ?[៤១]។ តាមប្រការនេះសរបញ្ជាក់អោយឃើញថា រាល់ការពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ ឬស្នើច្បាប់អង្គសភាត្រូវពិភាក្សា និងអនុម័តលើខ្លឹមសារទាំងមូលនៃសេចក្តីព្រាងច្បាប់ ឬស្នើច្បាប់នោះជាមុនសិន ទើបឈានដល់ការជជែកពិភាក្សា និងអនុម័តលើមាត្រាមួយម្តងៗ ឬលើជំពូកមួយម្តងៗក៏បាន។

▪ បន្ទាប់មកជជែកពិភាក្សា និងអនុម័តមួយមាត្រាម្តងៗ ឬមួយជំពូកម្តងៗ បន្ទាប់ពីអង្គសភាធ្វើការជជែកពិភាក្សា និងអនុម័តលើខ្លឹមសារទាំងមូលរួចហើយ អង្គសភានឹងឈានដល់ការពិភាក្សាសង្ខេបបានដោយពិភាក្សាតែមាត្រា ឬជំពូកណាដែលមានសំណើរធ្វើវិសោធនកម្មជាលាយលក្ខណ៍អក្សរ ដូចមានចែងក្នុងប្រការទាំងឡាយខាងលើនេះ។ ក្នុងករណីដែលនឹងត្រូវប្រើនីតិវិធីណាមួយខាងលើនេះ គណៈកម្មាធិការអចិន្ត្រៃយ៍ត្រូវជូនព័ត៌មានដល់អ្នកតំណាងរាស្ត្រជាមុន[៤២]។ យោងតាមប្រការនេះបញ្ជាក់ឲ្យឃើញថា ការពិភាក្សា និងអនុម័តមួយមាត្រាម្តងៗ ឬមួយជំពូកម្តងៗ គឺអាស្រ័យទៅដោយគណៈកម្មាធិការអចិន្ត្រៃយ៍ជូនព័ត៌មានដល់សមាជិកសភាជាមុន។ ដូច្នេះនៅពេលដែលជជែកពិភាក្សា និងអនុម័តលើខ្លឹមសារទាំងមូលរួចហើយប្រធានអង្គប្រជុំអនុញ្ញាតឲ្យប្រធានគណៈកម្មការជំនាញឡើងអានខ្លឹមសារនៃអត្ថបទសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ជូនអង្គសភាជ្រាបជាមុន ដើម្បីដាក់អត្ថបទនេះឲ្យអង្គប្រជុំធ្វើការជជែកពិភាក្សា និងអនុម័តរហូតដល់អស់មាត្រា ឬជំពូកនៃសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់។ នីតិវិធីប្រជុំជជែកពិភាក្សា និងអនុម័តនេះតម្រូវឲ្យមានកូរ៉ុមប្រាំពីរភាគដប់នៃចំនួនសមាជិករដ្ឋសភាទាំងមូល[៤៣] ហើយការអនុម័តត្រូវយកតាមមតិភាគច្រើនដាច់ខាតនៃសមាជិករដ្ឋសភាទាំងមូល[៤៤]។

ចំណែកការអនុម័តខាងលើ គឺធ្វើឡើងតាមការលើកដៃ។ ចំពោះការអនុម័តដោយលើកដៃ លេខាអង្គប្រជុំទាំងឡាយជាអ្នករាប់ចំនួនសមាជិកដែលគាំទ្រ និងមិនគាំទ្ររួចហើយលេខាអង្គប្រជុំឡើងជម្រាបជូនប្រធានអង្គប្រជុំនិងអង្គប្រជុំរដ្ឋសភាឲ្យបានដឹងពីលទ្ធផល។

## ២.៣ ព្រឹទ្ធសភា

### ២.៣.១ការដាក់ជូនសេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់ទៅគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

រាល់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលរដ្ឋសភាបានអនុម័តយល់ព្រមលើកដំបូងរួចហើយនោះ ព្រមទាំងបញ្ហានានាដែលរដ្ឋសភាបានដាក់ឲ្យពិនិត្យ ត្រូវបញ្ជូនមកគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាដើម្បីពិនិត្យ ហើយសម្រេចប្រគល់សេក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះទៅ

[៤១] ប្រការ២៩ថ្មី ចំណុច១ នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា

[៤២] ប្រការ២៩ថ្មី បទបញ្ជាផ្ទៃក្នុងរដ្ឋសភា

[៤៣] មាត្រា៨៨វាក្យខណ្ឌ២នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

[៤៤] មាត្រា៩០ថ្មីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

ឲ្យគណៈកម្មការជំនាញនានា ក្នុងចំណោមគណៈកម្មការជំនាញទាំង៩របស់ព្រឹទ្ធសភា។ សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះត្រូវធ្វើជាលាយលក្ខណ៍អក្សរ ហើយចែកជូនសមាជិកព្រឹទ្ធសភាទាំងអស់ដោយភ្ជាប់សេចក្តីថ្លែងហេតុមកជាមួយ។ សេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់ច្បាប់នោះត្រូវបញ្ជូនមកគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា។ គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាបញ្ជូនសេចក្តីនោះ ទៅគណៈកម្មការតាមមុខជំនាញឲ្យពិនិត្យ។ កាលបើពិនិត្យរួចហើយប្រធាននៃគណៈកម្មាធិការអចិន្ត្រៃយ៍នោះត្រូវនាំយកយោបល់របស់គណៈកម្មាការមកជំរាបជូនសភា[៩៥]។ ម្យ៉ាងទៀតដើម្បីឲ្យការប្រជុំរបស់ព្រឹទ្ធសភាអាច ដំណើរការទៅបាន លុះត្រាតែមានកូរ៉ុមប្រាំពីរភាគដប់នៃសមាជិកព្រឹទ្ធសភាទាំងមូល[៩៦] ឯការអនុម័តត្រូវយកតាមសំឡេងភាគច្រើនដាច់ខាត លើកលែងតែច្បាប់ធម្មនុញ្ញ បទបញ្ញាផ្ទៃក្នុងរដ្ឋសភា និងបទបញ្ញាផ្ទៃក្នុងព្រឹទ្ធសភា ដែលត្រូវយកតាមសំលេងពីរភាគបី។

រដ្ឋាភិបាលមានលទ្ធភាពក្នុងការដាក់ជូន នូវសេចក្តីព្រាងច្បាប់របស់ខ្លួនមកសភា ឬព្រឹទ្ធសភា។ មានតែសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុទេដែលត្រូវដាក់ជូនមក ព្រឹទ្ធសភាមុនគេបង្អស់ជាចាំបាច់។ ផ្ទុយទៅវិញ ក្នុងករណីសេចក្តីស្នើច្បាប់ធ្វើឡើងដោយតំណាងរាស្ត្រណាម្នាក់ គណៈកម្មាធិការត្រូវធ្វើការសន្និដ្ឋានពីអត្ថបទទាំងមូល។ ដូច្នេះ គណៈកម្មាការអាចធ្វើការកែប្រែអត្ថបទស្នើនេះដោយផ្ទាល់ ហើយធ្វើការកែប្រែនេះទៀតសោតអាចនាំដល់ការបង្កើតជាអត្ថបទមួយថ្មីស្រឡាង។ ព្រឹទ្ធសភាធ្វើការប្រជុំអនុម័តលើអត្ថបទ ដែលជាលទ្ធផលការងាររបស់គណៈកម្មាការ។ មានតែក្នុងករណីដែលគណៈកម្មាការធ្វើការសន្និដ្ឋានថា៖ លើកចោលសេចក្តីស្នើឬមិនធ្វើការសន្និដ្ឋានប៉ុណ្ណោះ ដែលព្រឹទ្ធសភាអាចធ្វើការពិភាក្សាលើ សេចក្តីស្នើរបស់អ្នកតែងសេចក្តីច្បាប់នេះ។ ហើយអត្ថបទនេះ (សេក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់) ត្រូវបញ្ជូនមកព្រឹទ្ធសភា។

- **គណៈកម្មាការអចិន្ត្រៃយ៍**

គឺជាគណៈកម្មាធិការរបស់ព្រឹទ្ធសភា ដែលរៀបចំរបៀបវារៈអង្គប្រជុំព្រឹទ្ធសភា និងចាត់ចែងការងារព្រឹទ្ធសភានៅចន្លោះសម័យប្រជុំ[៩៧]។

សមាសភាពនៃគណៈកម្មាធិការអចិន្ត្រៃយ៍មាន[៩៨] ៖

| | |
|---|---|
| -ប្រធានព្រឹទ្ធសភា | ជាប្រធាន |
| -អនុប្រធានទាំងពីរនៃរដ្ឋសភា | ជាសមាជិក |
| -ប្រធានគណៈកម្មការទាំង៩នៃព្រឹទ្ធសភា | ជាសមាជិក |

ប្រធាននៃគណៈកម្មការ មានសិទ្ធិក្នុងការចូលរួមក្នុងកិច្ចការងាររបស់គណៈកម្មការ និងមានសិទ្ធិក្នុងការការពារវិសោធនកម្មនានារបស់គណៈកម្មការរបស់ខ្លួន។ ចំពោះសេចក្តីព្រាងច្បាប់ដែល

---

[៩៥] ប្រការ២៣ វាក្យខណ្ឌ ១ នៃបទបញ្ញាផ្ទៃក្នុង ព្រឹទ្ធសភា

[៩៦] ប្រការ ៥៤នៃបទបញ្ញាផ្ទៃក្នុង ព្រឹទ្ធសភា

[៩៧] ប្រការ ៥៣ថ្មីនៃបទបញ្ញាផ្ទៃក្នុង ព្រឹទ្ធសភា

[៩៨] ប្រការ ២២ថ្មីនៃបទបញ្ញាផ្ទៃក្នុង ព្រឹទ្ធសភា

ព្រឹទ្ធសភាបានអនុម័តលើកដំបូង ឬបញ្ហានានា គណៈកម្មការដែលទទួលពិនិត្យអាចធ្វើសុំឲ្យ ព្រឹទ្ធសភា លើកចោលកុំពិចារណា ឬបញ្ចេញមតិជាមុនថា តើគួរពិចារណាឬមិនគួរ ឬទទួលពិចារណា ហើយនឹងទុកជាការប្រញាប់ផងក៏បាន[៤៩] ។ ក្នុងករណីគណៈកម្មការចង់ធ្វើការកែប្រែលើអត្ថបទ គណៈកម្មការគ្រាន់តែអាចចេញជាសំណើរតែប៉ុណ្ណោះ ហើយគណៈកម្មការត្រូវបញ្ជូនមករដ្ឋសភាវិញនូវការធ្វើវិសោធនកម្មរបស់ខ្លួន។



- **ការតំកល់សេចក្តីព្រាងច្បាប់ និង សេចក្តីស្នើច្បាប់**

សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះត្រូវបានចុះក្នុងបញ្ជីនៃរបៀបវារៈនៅថ្ងៃទទួល ដើម្បីកំណត់លំដាប់លេខក្នុងចំនោមឯកសាររបស់សភាដែលមានប្រភេទដូចគ្នាជាអាទិ៍ ជាមួយនឹងសំណុំឯកសាររបស់គណៈកម្មការ។ ការតំកល់តាមន័យច្បាប់ មានទំរង់ជាសេចក្តីប្រកាសមួយក្នុងការប្រជុំជាសាធារណៈ ដែលជាទូទៅ ត្រូវបានគេប្រកាសជូនដំណឹងនៅចុងបញ្ចប់នៃរបាយការណ៍ទាំងមូលរបស់អង្គប្រជុំ អត្ថបទច្បាប់ដែលបានតំកល់ទុកនោះ ត្រូវបានបញ្ជូនទៅគណៈកម្មការជំនាញនានា ដើម្បីត្រួតពិនិត្យ បន្ទាប់ត្រូវបានថតចម្លង និងចុងបញ្ចប់ត្រូវបានចែកជូននៅក្នុងអង្គប្រជុំ។ នៅពេលអត្ថបទច្បាប់មួយត្រូវបានបញ្ជូនមកសភា នៅចន្លោះពេលពីនីតិកាលមួយទៅនីតិកាលមួយទៀតការតំកល់ត្រូវធ្វើជាកម្មវត្ថុ (ដោយមិនចាំបាច់បវេសនកាលរបស់សភា) នៃការប្រកាសមួយដែលត្រូវបានចុះនៅក្នុងរាជកិច្ច។

### ២.៣.១.១ការចុះក្នុងរបៀបវារៈ

សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់មួយ មិនអាចដាក់ជូនអង្គប្រជុំពិភាក្សាបានទេបើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះមិនបានធ្វើជាកម្មវត្ថុជាមុន នៃសេចក្តីរាយការណ៍របស់គណៈកម្មការមានសមត្ថកិច្ចទៅតាមបទបញ្ញត្តិ ម្យ៉ាងទៀតសេចក្តីថ្លែងការណ៍ ឬថ្លែងហេតុនានារបស់គណៈកម្មការត្រូវដាក់ជូនថតចម្លង និងចែកជូនក្នុងរយៈពេលមួយ ដែលព្រឹទ្ធសភាមានលទ្ធភាពក្នុងការពិភាក្សាលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ទាំងនោះ ។ ដើម្បីអាចធ្វើជាកម្មវត្ថុនៃការពិភាក្សាជាសាធារណៈ សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ត្រូវបានគេចុះក្នុងរបៀបវារៈជាមុនសិន។

គណៈកម្មាការអចិន្ត្រៃយ៍ព្រឹទ្ធសភាជាអ្នករៀបរៀងរបៀបវារៈនៃពេលប្រជុំនីមួយៗ ហើយនៅពេលបញ្ចប់នៃពេលប្រជុំប្រធានត្រូវអានរបៀបវារៈសម្រាប់ប្រជុំបន្ត[៥០]។ របៀបវារៈមានសេចក្តីជាលំដាប់មុនក្រោយដូចតទៅ[៥១]៖

- របៀបវារៈ ឬ បញ្ហាទាំងឡាយ ដែល ព្រឹទ្ធសភាបានសំរេចថាជាការប្រញាប់

-បញ្ហាទាំងឡាយណាដែលព្រឹទ្ធសភាជូនមករដ្ឋសភា។

-បញ្ហាទាំងឡាយណាដែលព្រឹទ្ធសភាជូនមករដ្ឋសភា។

---

[៤៩] ប្រការ ៤៩ថ្មីនៃបទបញ្ជាផ្ទៃក្នុង ព្រឹទ្ធសភា

[៥០] ប្រការ៥៣ថ្មី នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា (បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាឆ្នាំ២០០៦ដោយអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា)

[៥១] ប្រការ៥៤ថ្មី នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា (បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាឆ្នាំ២០០៦ដោយអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា)

- បញ្ហាទាំងឡាយណាដែល គណៈកម្មាការនានាជូនមកព្រឹទ្ធសភា។
- បញ្ហាទាំងឡាយណាដែល សមាជិក ព្រឹទ្ធសភា ជូនមករដ្ឋសភា។

ផ្អែកតាមបញ្ញាត្តិនៃប្រការខាងលើ យើងឃើញថា របៀបវារៈមានតែពីរបែបពោលគឺៈរបៀបវារៈជាអាទិភាព និងរបៀបវារៈបន្ថែម ឬរបៀបវារៈធម្មតា។

**របៀបវារៈ ជាអាទិភាព**

សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ក៏ដូចជាញត្តិផ្សេងៗ ដែលត្រូវបានប្រកាសថា ជាការប្រញាប់ត្រូវចុះក្នុងរបៀបវារៈពិភាក្សាមុនគេ[៥២]។ បទបញ្ជាផ្ទៃក្នុងរបស់ព្រឹទ្ធសភា ទទួលស្គាល់សិទ្ធិរបស់រដ្ឋាភិបាលក្នុងការស្នើសុំដាក់សេចក្តីព្រាងច្បាប់ ដែលខ្លួនចង់ឲ្យរដ្ឋសភាធ្វើការពិភាក្សា និងអនុម័ត ជាមួយនឹងលំដាប់លេខរៀងសម្រាប់ការពិចារណាមុនក្រោយផងដែរ។ តាមការអនុម័តជាក់ស្តែងការដែលស្នើឡើងដោយរដ្ឋាភិបាល ឬដោយតំណាងរាស្ត្រឬដោយម្ចាស់ញត្តិ ត្រូវភ្ជាប់មកជាមួយលិខិតបញ្ជាក់ហេតុផល ហើយពន្យល់បកស្រាយនូវបញ្ហានានា ដែលខ្លួនសុំឲ្យដាក់ជាការប្រញាប់[៥៥៤]។ ក្រោយពីបានទទួលពាក្យសុំដាក់អត្ថបទសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ឬញត្តិណាមួយជាការប្រញាប់ហើយនោះ គណៈកម្មាការអចិន្ត្រៃយ៍ត្រូវសម្រេចលើពាក្យសុំនោះភ្លាមបន្ទាប់ពីប្រធានបានអានសេចក្តីរាយការណ៍ ឬសេចក្តីថ្លែងហេតុជម្រាបជូនអង្គប្រជុំគណៈកម្មាការអចិន្ត្រៃយ៍ ។ ការសម្រេចនេះអាចជាការយល់ព្រម ឬ មិនយល់ព្រមទុកអត្ថបទនោះជាការប្រញាប់។

**របៀបវារៈបន្ថែម ឬ របៀបវារៈធម្មតា**

ជាទូទៅ របៀបវារៈបន្ថែមនេះច្រើនតែជាបញ្ហាទាំងឡាយណាដែលព្រឹទ្ធសភាជូនមករដ្ឋសភា ហើយបញ្ហាទាំងនេះពុំមែនជាបញ្ហាដែលត្រូវបានព្រឹទ្ធសភាស្នើសុំជាការប្រញាប់ទេ។ ការរៀបចំរបៀបវារៈ ជាសមត្ថកិច្ចរបស់គណៈកម្មាការ អចិន្ត្រៃយ៍នៃព្រឹទ្ធសភា។ ប្រធានអង្គប្រជុំនៃគណៈកម្មការអចិន្ត្រៃយ៍ត្រូវអានរបៀបវារៈ សម្រាប់ពេលប្រជុំនីមួយៗ។ របៀបវារៈបន្ថែមនេះពុំមែនមានតែចំពោះសេចក្តីព្រាងច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែវាក៏មានសេចក្តីស្នើច្បាប់ផងដែរ ។ ការកំណត់របៀបវារៈគឺជាការបើកផ្លូវនៃការពិភាក្សារបស់ព្រឹទ្ធសភា មុននឹងឈានដល់ការអនុម័តលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់។

## ២.៣.២ ការពិភាក្សាក្នុងគណៈកម្មការជំនាញ

គណៈកម្មការពិភាក្សាយ៉ាងលំអិតលើសេចក្តីព្រាងច្បាប់ រឺសេចក្តីស្នើច្បាប់ ដែលបានទទួលពីគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដោយមានការចូលរួមពីតំណាងរាជរដ្ឋាភិបាល បើជាសេចក្តីព្រាងច្បាប់ រឺពីសមាជិករដ្ឋសភា រឺពីសមាជិកព្រឹទ្ធសភា បើជាសេចក្តីស្នើច្បាប់ ។ តំណាងទាំងនេះមានសិទ្ធិឆ្លើយបំភ្លឺចំពោះសំនួរដែលគណៈកម្មការជំនាញសួរ។ តំណាងគណៈកម្មការដទៃទៀតរបស់ព្រឹទ្ធសភា តំណាងអង្គការក្រៅរាជរដ្ឋាភិបាល និងសង្គមស៊ីវិល អាចចូលរួមបានតាមការអញ្ជើញរបស់គណៈកម្មការ។ អ្នកតំណាងសង្គមស៊ីវិលគ្មានសិទ្ធិចូលរួមក្នុងការអនុម័តឡើយ ។

[៥២] ប្រការ៤៩ថ្មី នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា (បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាឆ្នាំ២០០៦ដោយអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា)

ប្រធានគណៈកម្មការជំនាញ ត្រូវឡើងរាយការណ៍អំពីយោបល់របស់គណៈកម្មកាជំនាញរបស់ខ្លួនដែលបានធ្វើការពិនិត្យនិងពិភាក្សាយ៉ាងហ្មត់ចត់លើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ជូនព្រឹទ្ធសភាដើម្បីធ្វើការជជែកពិភាក្សាលើអត្ថបទសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នេះ។ សេចក្តីរាយការណ៍នេះត្រូវបង្ហាញពីឆន្ទៈរបស់គណៈកម្មការជំនាញ និងអំពីវិសោធនកម្មទាំងឡាយលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ហើយត្រូវចំលងចែកជូនសមាជិកព្រឹទ្ធសភាទាំងអស់ឲ្យបានមុនថ្ងៃប្រជុំអនុម័តសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះ។ គណៈកម្មការជំនាញអាចប្រជុំបានលុះត្រាតែសមាជិកច្រើនជាងពាក់កណ្តាលបានចូលរួម ឯការអនុម័តត្រូវយកតាមសំលេងភាគច្រើនដាច់ខាតនៃចំនួនគណៈកម្មការ[៥៥]។ បើយោងតាមប្រការ៣១ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាចែងថា ការពិភាក្សាលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ត្រូវធ្វើដូចតទៅ៖ ពិនិត្យពិចារណាលើខ្លឹមសារទាំងមូលសិន រួចទើបពិភាក្សាលើមាត្រាមួយម្តងៗក៏បាន ឬមួយជំពូកម្តងៗក៏បាន វៀរលែងតែសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលទាក់ទងនឹងថវិការជាតិ ការបើកឥណទានថ្មី ការបន្ថែម ឬការបង្កើតមុខចំណូលថ្មី។

ដូច្នេះការពិភាក្សារបស់ព្រឹទ្ធសភាត្រូវធ្វើឡើងតាមពីរដំណាក់កាល ៖

**ដំណាក់កាលនៃការពិនិត្យខ្លឹមសារទាំងមូល** ៖ ជាដំណាក់កាលដែលរាជរដ្ឋាភិបាលគណៈកម្មការពាក់ព័ន្ធ និងអ្នកតំណាងរាស្ត្រត្រូវបង្ហាញឥរិយាបថរបស់ខ្លួន ។

**ដំណាក់កាលនៃការពិនិត្យលំអិត** ៖ ជាដំណាក់កាលដែលព្រឹទ្ធសភាពិនិត្យលើមាត្រា ឬ ជំពូកនីមួយៗមុននឹងសំរេចលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ទាំងមូល ។

### ២.៣.២.១ ដំណាក់កាលនៃការពិនិត្យខ្លឹមសារទាំងមូល

នៅពេលនោះតំណាងរាជរដ្ឋាភិបាល ប្រធានគណៈកម្មការ ឬសមាជិកគណៈកម្មការដែលពាក់ព័ន្ធ និងតំណាងរាស្ត្រត្រូវបញ្ចេញយោបល់របស់ខ្លួន។ ដំណាក់កាលនៃការពិនិត្យពិភាក្សា និងអនុម័តលើខ្លឹមសារទាំងមូល ជាដំណាក់កាលដ៏សំខាន់បំផុត ក្នុងការផ្តល់ជាយោបល់ក្នុងការកែសម្រួល ឬបំពេញនូវការខ្វះចន្លោះនៃអត្ថបទសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ពោលគឺវាគ្មិនទាំងអស់ត្រូវបរិយាយ ដើម្បីឲ្យព្រឹទ្ធសភាយល់ពីហេតុផលដែលខ្លួនចង់កែសម្រួល ឬបំពេញនូវការខ្វះចន្លោះនៃអត្ថបទសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ក្នុងន័យសុំឲ្យរដ្ឋសភាសម្រេចថា តើគួរពិចារណា ឬមិនគួរពិចារណាលើសំណើរបស់ខ្លួន។ បន្ទាប់មកប្រធានអង្គប្រជុំស្នើឲ្យរដ្ឋសភាអនុម័តលើខ្លឹមសារទាំងមូលនៃសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់[៥៦] ក្នុងការជជែកពិភាក្សា គឺតម្រូវឲ្យវាគ្មិនទាំងអស់ ដែលបានចូលរួមមានសិទ្ធិធ្វើបទអន្តរាគមន៍ ដែលអ្នកទាំងនោះរួមមានរដ្ឋាភិបាល ប្រធានគណៈកម្មការ ឬសមាជិកគណៈកម្មការជំនាញ និងអ្នកតំណាងរាស្ត្រ។ ប៉ុន្តែត្រូវសុំ ហើយទទួលសេចក្តីអនុញ្ញាតពីប្រធានជាមុនសិនទើបនិយាយបាន[៥៧]។

---

[៥៥] ប្រការ ១០ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា

[៥៦] ប្រការ៣១ បទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភា

[៥៧] ប្រការ ៥២ បទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភា

ដំណាក់កាលនេះ ជាដំណាក់កាលដែលរាជរដ្ឋាភិបាលឡើងរាយការណ៍ និងសមាជិកព្រឹទ្ធសភាបញ្ចេញយោបល់របស់ខ្លួន ចំពោះអត្ថបទសេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់។ ឥរិយាបថរបស់ព្រឹទ្ធសភា អាចស្តែងឡើងតាមរយៈញត្តិនៃនីតិវិធីដែលមានការពិនិត្យពិចារណា ទៅលើបញ្ហាទម្រង់បញ្ហាកាលានុវត្តភាពនៃសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ និងទៅលើញត្តិបញ្ជូនទៅគណៈកម្មការជំនាញផងដែរ។

- **ញត្តិដែលមានលក្ខណៈជាបឋមសំនួរ ៖** សំដៅដល់ការពិនិត្យជាបឋមលើទម្រង់នៅសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដើម្បីឲ្យដឹងថាសេចក្តីព្រាងច្បាប់ ឬស្នើច្បាប់ នោះត្រូវបានគេធ្វើឡើងដោយគោរពទៅតាមបែបបទនានា ដូចមានចែងក្នុងប្រការ២៤នៃ បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាឬយ៉ាងណា ដែលជាអាទ័រួមមានចែងជាជំពូក និងជាមាត្រា ជាដើម។ ជាមួយគ្នានេះដែរ ព្រឹទ្ធសភាក៏ត្រូវពិនិត្យផងដែរថា តើសេចក្តីព្រាងច្បាប់នោះ ត្រូវបញ្ជូន ដោយត្រឹមត្រូវតាមនីតិវិធីដែលស្របតាមប្រការ២៣ នៃបទបញ្ជាផ្ទៃក្នុង ព្រឹទ្ធសភាដែរឬទេ? ក្នុងបឋមសំណួរនេះដែរ ព្រឹទ្ធសភាត្រូវពិចារណាលើគោលការណ៍ សំខាន់ៗនៃសេចក្តីព្រាងច្បាប់ ឬស្នើច្បាប់ ពោលគឺពិនិត្យលើអត្ថប្រយោជន៍ និងភាពចាំបាច់ នៃសេចក្តីព្រាងច្បាប់ ឬស្នើច្បាប់នោះ។ ការពិចារណាលើបឋមសំណួរអាចត្រូវបានគេ និយាយថា ជាការពិចារណាលើកាលានុវត្តភាពនៃសេចក្តីព្រាងច្បាប់ ឬស្នើច្បាប់ឬក៏ត្រូវធ្វើ ឡើងទៅលើភាពចាំបាច់របស់វាទៅនឹងតម្រូវការជាក់ស្តែងរបស់សង្គម។
- **ញត្តិបញ្ជូនទៅគណៈកម្មការ ៖** ញត្តិនេះមានកម្មវត្ថុពិនិត្យលើភាពខ្វះខាតនៃការងាររបស់គណៈកម្មការ ពោលគឺព្រឹទ្ធសភាស្នើសុំឲ្យគណៈកម្មការជំនាញពាក់ព័ន្ធ ធ្វើការពិនិត្យបន្ថែមទៀត ប្រសិនបើព្រឹទ្ធសភាយល់ឃើញថា ជាការចាំបាច់សម្រាប់បំភ្លឺលើបញ្ហា ស្មុគស្មាញ ឬមិនច្បាស់លាស់ ឬមានចំណុចណាមួយនៃសេចក្តីព្រាងច្បាប់ ឬស្នើច្បាប់នោះ ដែលព្រឹទ្ធសភាសម្រេចមិនបាន។ ការផ្តើមគំនិតឲ្យមានការតម្កល់នេះ ជាសិទ្ធិរបស់អ្នក តំណាងរាស្ត្រ ដែលអនុវត្តន៍ក្នុងលក្ខណៈបុគ្គលក៏បាន លក្ខណៈរួមគ្នាក៏បាន។ ក្នុងការ អនុវត្តជាក់ស្តែងអ្នកតំណាងរាស្ត្រជាអ្នកលើកឡើងនូវបញ្ហាញត្តិនៃនីតិវិធីនេះ ព្រមជាមួយ នឹងការពន្យល់បកស្រាយដោយទាញយកហេតុផលផ្សេងៗ លើកលែងតែហេតុផលដែល ស្តីអំពីអធម្មនុញ្ញភាពនៃអត្ថបទដែលកំពុងពិភាក្សានោះ មកបញ្ជាក់ជូនព្រឹទ្ធសភាទាំងមូល ស្តាប់ពិចារណា និងសម្រេច។ ការពិភាក្សាលើបឋមសំណួរ ជាធម្មតាត្រូវធ្វើបន្ទាប់ ពីការស្តាប់សេចក្តីរាយការណ៍របស់ប្រធានគណៈកម្មការ មុននឹងការពិភាក្សាលើខ្លឹមសារ ទាំងមូល។ ចំណែកការពិភាក្សាញត្តិបញ្ជូនទៅគណៈកម្មការ ត្រូវចាប់ផ្តើមក្រោយការបិទពិភាក្សាលើខ្លឹមសារទាំងមូល។ ប្រសិនបើបញ្ហាបញ្ញត្តិដែលមានលក្ខណៈបឋមសំណួរត្រូវបានព្រឹទ្ធសភាបដិសេធនោះ ការពិភាក្សាលើខ្លឹមសារទាំងមូលត្រូវដំណើរការជាធម្មតា។ ហើយបើមានការបដិសេធញត្តិបញ្ជូនទៅគណៈកម្មការនោះ មានន័យថា ជាការបើក ផ្លូវនៃការពិភាក្សាជាលក្ខណៈលម្អិត។

- **ការអនុម័តញ្ញត្តិដែលមានលក្ខណៈជាបឋមសំណួរ ៖** ធ្វើឲ្យមានការ បដិសេធនូវ សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលមានបឋមសំណួរនោះ។ ការអនុម័តញ្ញត្តិដែលមានលក្ខណៈជាបឋមសំណួរមានន័យថា ព្រឹទ្ធសភាទាំងមូលអនុម័ត យល់ព្រមថាសេចក្តី ព្រាងច្បាប់ ឬស្នើច្បាប់ដែលដាក់ជូនព្រឹទ្ធសភានោះ ពុំបានបំពេញនិតីវិធីនៃការបញ្ជូន ឬពុំបានបែងចែកជាជំពូក ជាមាត្រាដែលមានចែងក្នុងប្រការ២៤ នៃបទបញ្ជាផ្ទៃក្នុង ព្រឹទ្ធសភា។

ដូច្នេះការអនុម័តនេះនាំទៅដល់ការបញ្ចប់មុនពេលកំណត់នៃការពិភាក្សាដទៃទៀត ហើយវាមានអានុភាពដូចគ្នាទៅនឹងការបដិសេធសេចក្តីព្រាងច្បាប់ ឬស្នើច្បាប់ ក្រោយពីត្រូវព្រឹទ្ធសភាធ្វើការពិនិត្យពិភាក្សាលម្អិតដែរ។ បើតាមការអនុវត្តជាក់ស្តែងការអនុម័តលើញ្ញត្តិ ដែលមានលក្ខណៈជាបឋមសំណួរនេះពុំសូវមានទេ តែផ្ទុយទៅវិញ ព្រឹទ្ធសភាតែងតែអនុម័តយល់ព្រមលើកយកសេចក្តីព្រាងច្បាប់ ឬស្នើច្បាប់ទាំងនោះមកជជែកពិភាក្សា។

- មានអានុភាពព្យួរការជជែកពិភាក្សាលើអត្ថបទនៃសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់

**ការអនុម័តញ្ញត្តិបញ្ជូនទៅគណៈកម្មការ ៖** រហូតដល់មានការឧទ្ទេសរបាយការណ៍ថ្មីដោយប្រធានគណៈកម្មការមានសមត្ថកិច្ច។ ការអនុវត្តនិតីវិធីនេះ ជាគោលការណ៍ពុំបានធ្វើឲ្យមានការខកខានដល់ការពិភាក្សាលើអត្ថបទដែលបានចុះក្នុងរបៀបវារៈនោះទេ។ មានន័យថាព្រឹទ្ធសភាដំណើរការ ការពិភាក្សលើអត្ថបទអាទិភាពនេះជាធម្មតា ដូចជាការ ពិភាក្សាដែលឥតមានការអនុម័តញ្ញត្តិបញ្ជូនទៅគណៈកម្មការដែរ។

រីឯការពិភាក្សាលើអត្ថបទដែលចុះក្នុងរបៀបវារៈ ធម្មតាត្រូវស្របតាមបទប្បញ្ញត្តិនៃប្រការ ២១ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាជាអ្នករៀបចំរបៀបវារៈនៃពេលប្រជុំនីមួយៗ។ មុនពេលប្រជុំនីមួយៗប្រធានអានរបៀបវារៈសម្រាប់ពេលប្រជុំបន្តទៅទៀត។

តាមអត្ថន័យនៃប្រការ២១នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាខាងលើ ការកំណត់ពេលវេលានៃការពិភាក្សាលើរបាយការណ៍ថ្មីរបស់គណៈកម្មការជំនាញ ជាសមត្ថកិច្ចផ្តាច់មុខរបស់គណៈកម្មាធិការអចិន្ត្រៃយ៍នៃព្រឹទ្ធសភាហើយរយៈពេលនេះមានការប្រែប្រួលពុំទៀងទាត់ អាស្រ័យទៅតាមការត្រួតពិនិត្យបន្ថែមរបស់គណៈកម្មកាជំនាញនីមួយៗ។

ព្រឹទ្ធសភាបើកការប្រជុំពិភាក្សាសារជាថ្មីពីការព្យួរមួយរយៈរដ្ឋសភា ត្រូវស្តាប់ការរាយការណ៍ជាថ្មីម្តងទៀត រួចហើយទើបចាប់ផ្តើមជជែកពិភាក្សាលើមាត្រាមួយម្តងៗដែលមានចែងក្នុងប្រការ ៣១ ចំណុចពីរតួចនៅក្នុងបទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភា។

### ២.៣.២.២ ដំណាក់កាលនៃការពិនិត្យលំអិត

ការពិភាក្សាមួយមាត្រាម្តងៗ រឺ មួយជំពូកម្តងៗ ដូចមានចែងក្នុងប្រការ ៣១។ ដំណាក់កាលនេះភាគច្រើនត្រូវចាប់ផ្តើមដោយការពិភាក្សាលើសំណើរកែប្រែដែលអនុវត្តតាមមធ្យោបាយនៃការធ្វើវិសោធនកម្ម។ ពាក្យសុំធ្វើវិសោធនកម្មនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរជូនទៅគណៈកម្មការជំនាញក៏បានរឺជូនទៅព្រឹទ្ធសភាក្នុងពេលប្រជុំពេញអង្គក៏បាន (ប្រការ២៨នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា)។ពាក្យសុំធ្វើវិសោធនកម្មត្រូវភ្ជាប់មកជាមួយនូវសេចក្តីថ្លែងហេតុសង្ខេបមួយច្បាប់ដែលប្រាប់ពីឆន្ទៈនិងហេតុផលរបស់អ្នកស្នើសុំ ជាពិសេសត្រូវទាក់ទងយ៉ាងច្បាស់លាស់ទៅនឹងការ កែប្រែ។

ពាក្យសុំធ្វើវិសោធនកម្មត្រូវដាក់ជូនអង្គសភាពិនិត្យពិចារណាថាតើយល់ព្រម រឺ មិនយល់ព្រមយកពាក្យសុំនោះមកពិភាក្សា ( ប្រការ ២៩នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា)។

ចំពោះវិសោធនកម្មដែលមានលក្ខណៈ និង ទ្រង់ទ្រាយធំជាអាទិ៍វិសោធនកម្មដែលប៉ះពាល់ដល់ខ្លឹមសារទាំងមូល រឺ អត្ថន័យជាសារវន្តរបស់សេចក្តីព្រាងរឺស្នើច្បាប់ ប្រធានព្រឹទ្ធសភារឺប្រធានអង្គប្រជុំប្រកាសចាត់តាំងគណៈកម្មាការពិសេស(ប្រការ ១២នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា)។

ថ្វីត្បិតតែព្រឹទ្ធសភាទទួលពាក្យ សុំធ្វើវិសោធនកម្មក្នុងសម័យប្រជុំពេញអង្គក៏ដោយ ក៏អង្គសភា មិនអាចធ្វើការអនុម័តលើវិសោធនកម្មក្នុងថ្ងៃដែលទទួលពាក្យសុំនោះបានដែរលើកលែងតែជាការប្រញាប់(ប្រការ៣០នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា)។ តែតាមការអនុវត្តជាក់ស្តែងត្រូវបានដាក់តំកល់ទុកក្នុងរយៈពេលមួយដែលប្រែប្រួលទៅតាមការងាររបស់គណៈកម្មការជំនាញបានន័យ ថាវាយូរ រឺឆាប់អាស្រ័យលើរយៈ ពេលនៃការពិនិត្យរបស់គណៈកម្មការ ។

ការពិភាក្សាលំអិតត្រូវបានស្តែងឡើងក្រោមលក្ខណៈពីរបែបនេះបើផ្អែកតាមប្រការ៣១ ចំនុចពីរ ពោលគឺការអនុម័តមួយជំពូកម្តងៗ រឺ មួយមាត្រាម្តងៗ ។

ការពិភាក្សាមួយមាត្រាម្តងៗត្រូវចូលរួមដោយបទអន្តរាគមន៍របស់គណៈកម្មការជំនាញដែលត្រូវបានប្តឹងដល់អង្គសេចក្តីរឺដោយបទអន្តរាគមន៍ដែលមានលក្ខណៈជាយោបល់ និងព្រមជាមួយគ្នានេះដែរ ការពិភាក្សានេះត្រូវចាប់ផ្តើមម្តងមួយមាត្រាៗ តាមលំដាប់លេខរៀងជាបន្តបន្ទាប់(ដូចបានរៀបរាប់ក្នុងបទអន្តរាគមន៍)។ ប៉ុន្តែបើក្នុងការប្រជុំការពិភាក្សាបានក្លាយជាការជជែកមួយដែលបង្កឲ្យចលាចលច្របូកច្របល់បាត់សណ្តាប់ធ្នាប់ហើយប្រធានហាមឃាត់ពុំស្តាប់ នោះប្រធានអាចផ្អាកការប្រជុំដោយក្រោកដើរចេញពីសាលប្រជុំតែម្តង ( ប្រការ ៥៨ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ) ។

ការពិភាក្សាមួយជំពូកម្តងៗ ក្រោយពីមានការស្នើសុំរបស់គណៈកម្មការជំនាញជូនទៅគណៈកម្មការអចិន្ត្រៃយ៍ព្រឹទ្ធសភាអោយដាក់នីតិវិធីនៃការពិភាក្សាអនុម័តមួយជំពូកម្តងៗជូនព្រឹទ្ធសភា ធ្វើការពិចារណាអង្គសភាទាំងមូលធ្វើការអនុម័តដោយសំលេងភាគច្រើននៃសមាជិកព្រឹទ្ធសភាទាំងមូល ថាតើគួរអនុម័តសេចក្តីព្រាងច្បាប់ រឺ សេចក្តីស្នើច្បាប់តាមមួយមាត្រាម្តងៗ រឺ មួយជំពូកម្តងៗ។ នីតិវិធីនេះប្រើបានចំពោះតែសេចក្តីណាដែលមានលក្ខណៈងាយយល់តែប៉ុណ្ណោះផ្ទុយទៅវិញបើ សេចក្តីស្នើ រឺ សេចក្តីព្រាងណាដែលមានភាពស្មុគស្មាញជាអាទិ៍ដូចជាច្បាប់ថវិកាអង្គសភាត្រូវធ្វើការពិភាក្សាមួយជំពូកម្តងៗ ដោយពិនិត្យលើគ្រប់មាត្រាទាំងអស់បានន័យថាគេត្រូវអនុវត្តនីតិវីធីនៃការអនុម័តមួយមាត្រាម្តងៗ។ ការពិភាក្សាម្តងមួយជំពូក រឺមួយមាត្រាម្តងៗ ជានិច្ចកាលតែងត្រូវបានចាប់ផ្តើមដោយការពិនិត្យលើវិសោធនកម្ម ដែលអនុម័តត្រូវធ្វើតាមនីតិវីធីធម្មតា និងដោយមតិភាគច្រើនរបស់សមាជិកព្រឹទ្ធសភា (ប្រការ ៣១ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា)។

វិសោធនកម្មៈ ការលើកយកវិសោធនកម្មមកពិនិត្យមានសារប្រយោជន៍ចាំបាច់ណាស់សំរាប់ដំណើរការនៃការជជែកពិភាក្សា ព្រោះថាការអនុម័តសំណើរសុំធ្វើវិសោធនកម្មណាមួយបណ្តាលឲ្យមានការលុបចោលដោយស្វ័យប្រវត្តិនូវពាក្យសុំធ្វើវិសោធនកម្មដទៃទៀត ដែលមានលក្ខណៈស្រដៀងគ្នានោះបានន័យថា អង្គសភាពុំលើកយកពាក្យសុំធ្វើវិសោធនកម្មផ្សេងទៀត ដែលនិយាយពីបញ្ហាតែមួយជាមួយនឹងវិសោធនកម្ម ដែលព្រឹទ្ធសភាបានអនុម័តរួចហើយ។ គោលការណ៍ជា

មូលដ្ឋាននៃការដាក់បញ្ចូលវិសោធនកម្មច្រើនទៅក្នុងមាត្រាតែមួយតំរូវឲ្យអង្គសភាធ្វើការពិចារណាទៅលើវិសោធនកម្មដែលមានលក្ខណ:ទូទៅជាមុនសិន រួចទើបពិចារណាលើករណីដោយឡែកណាមួយ ជាអាទ៏ការលុបចោលមាត្រាណាមួយត្រូវយកមកពិភាក្សាមុនការលុប វាក្យខណ្ឌ័ហើយការលុបវាក្យខណ្ឌ័នេះត្រូវធ្វើការលុបឃ្លានៅក្នុងវាក្យខណ្ឌ័នោះ។ ក្នុងការអនុវត្តជាក់ស្តែងវិសោធន_កម្មកែទៅលើមាត្រាមួយ តែស្នើឡើងដោយអ្នកតំណាងរាស្ត្រច្រើនរូបអាច នឹងត្រូវដាក់អោយជជែកពិភាក្សាក្នុងពេលតែមួយបាន ហើយដែលក្នុងពេលនោះអ្នកសុំវិសោធនកម្ម អាចលើកយកទឡ្ហីករណ៍ផ្សេងៗមកពន្យល់ បកស្រាយសំដៅការពារសំណើររបស់ខ្លួនបាន ។

ការកែប្រែ រឺ ការកែតំរូវវិសោធនកម្ម : ការកែប្រែលើវិសោធនកម្មលើសេចក្តីព្រាង រឺ សេចក្តីស្នើច្បាប់ពុំប្លែកពីការសុំធ្វើវិសោធនកម្មទេ ប៉ុន្តែការកែប្រែនេះធ្វើឲ្យនីតិវិធីក្នុងការពិនិត្យ និងអនុម័តកាន់តែសាំញ៉ាំស្មុគស្មាញខ្លាំងឡើងមួយកំរិតទៀតព្រោះវាតំរូវឲ្យវិសោធនកម្មលើសេចក្តីព្រាង រឺ សេចក្តីស្នើច្បាប់ ត្រូវបានអង្គសភាយកមកពិភាក្សាជាមុន រួចហើយយកសំណើរសុំកែប្រែ រឺ កែតំរូវលើវិសោធនកម្មមកពិចារណាជាបន្ទាប់នៅក្នុងលក្ខខ័ណ្ឌដដែលដូចគ្នា ចំពោះវិសោធនកម្ម ដែរ។ ក្នុងករណីនេះតំរូវឲ្យអ្នកសុំកែប្រែចង្អុលបង្ហាញឲ្យច្បាស់ថាតើខ្លួនចង់ឲ្យសភាអនុម័តលើផ្នែក ណា រឺ ចំនុចណាមួយនៃវិសោធនកម្មនោះ ពោលគឺវាអាចជាវាក្យខ័ណ្ឌទីមួយអាចជាឃ្លា រឺ ជាពាក្យមួយ រឺ ពីរម៉ាត់ ។ក្នុងការអនុវត្តលិខិតកែតំរូវច្រើនត្រូវបានអនុវត្តដោយរាជរដ្ឋាភិបាល ហើយដែលលិខិតនោះត្រូវបានដាក់ជូនគណ:កម្មធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា រឺ គណកម្មការជំនាញ រឺ ការកែតំរូវលើចំនុចតូចៗដូចជាពាក្យ រឺ ផ្លាស់ប្រយោគភាគច្រើន ច្រើនតែអ្នកតំណាងរាស្ត្រជាអ្នកធ្វើដោយផ្ទាល់មាត់ ។

មាត្រាបន្ថែម ក្រៅពីការសុំធ្វើវិសោធនកម្មលើសេចក្តីព្រាង រឺ សេចក្តីស្នើច្បាប់ គេសង្កេតឃើញមានការសុំបញ្ចូលមាត្រាថ្មីបន្ថែមលើសេចក្តីនោះ។មាត្រាបន្ថែមមានន័យផ្សេងពីវិសោធនកម្មដោយហេតុថា វាពុំមានកម្មវត្ថុកែប្រែសេចក្តីព្រាង រឺ សេចក្តីស្នើច្បាប់ទេ តែវាត្រូវបានគេស្នើឡើងក្នុងគោលបំណងបំពេញបន្ថែមនូវភាពខ្វះចន្លោះនៃសេចក្តីទាំងពីរសំដៅធ្វើឲ្យអត្ថបទទាំងនេះមានលក្ខណ:ពេញលេញ។ ការស្នើសុំដាក់បន្ថែមនូវមាត្រាថ្មីៗបានផ្តល់ឲ្យអ្នកសុំនូវសិទ្ធិក្នុងការបញ្ចេញយោបល់ដូចគ្នានឹងសិទ្ធិរបស់អ្នកធ្វើសេចក្តីព្រាង រឺ សេចក្តីស្នើច្បាប់ដែរ ។ ក្រោយពីការពិនិត្យ និងអនុម័តចប់សព្វគ្រប់លើមាត្រានីមួយៗ រឺ លើជំពូកនីមួយៗ ព្រមទាំងវិសោធនកម្មក៏ ដូចជាលើមាត្រាបន្ថែមរួចមក អង្គសភាទាំងមូលអាចពិនិត្យកែប្រែចំណងជើងរឺ ឈ្មោះមាតិកានៃ អត្ថបទច្បាប់បានបើសិនការអនុម័តលើវិសោធនកម្មនានាធ្វើឲ្យប៉ះពាល់ដល់ចំនងជើងនៃអត្ថបទនោះ ។

- **ដំណាក់កាលជជែកពិភាក្សាលំអិត**

ដំណាក់កាលជជែកពិភាក្សាលំអិត ជាដំណាក់កាលមួយ ឈានដល់ការជជែកពិភាក្សាមួយមាត្រាម្តងៗ រឺមួយជំពូកម្តងៗដូចដែលមានចែងក្នុង (ប្រការ៣១ថ្មីនៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា)គឺជាការចាប់ផ្តើមនៃដំណាក់កាលមួយដែលក្នុងពេលនោះព្រឹទ្ធសភាធ្វើការជជែក និងពិនិត្យដោយហ្មត់ចត់បំផុតទៅលើអត្ថបទនៃសេចក្តីព្រាងច្បាប់ រឺសេចក្តីស្នើច្បាប់ដែលគណ:កម្មការអចិន្ត្រៃយ៍នៃ

ព្រឹទ្ធសភាបានដាក់ជូនក្នុងខណៈពេលនោះ ការជជែកពិភាក្សាដែលធ្វើឡើងដោយមានយោបល់ច្រើនផ្សេងៗគ្នា ទៅជាការដោះដូរទស្សនៈទៅវិញទៅមកដែលមានលក្ខណៈបច្ចេកទេសផងនិងប្រកបដោយសុក្រិតភាពផង។ ក្នុងការជជែកពិភាក្សាវាគ្មិនត្រូវនិយាយឆ្លាស់គ្នាអ្នកគាំទ្រនិយាយម្តងរួចអ្នកជំទាស់ និយាយម្តងយោងតាម(ប្រការ៥៩នៃបទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភា) ហើយវាគ្មិនដែលបានការអនុញ្ញាតពីប្រធានដើម្បីឡើងបញ្ចេញមតិរបស់ខ្លួនដោយគ្រាន់តែឡើង នៅនឹងអសនៈរបស់ខ្លួនផ្ទាល់ ដោយពុំចាំបាច់ឡើងលើវេទិកាទេ ។

យោងតាម(ប្រការ៥៥ថ្មីនៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា) តាមគោលការណ៍រយៈពេលនិយាយសម្រាប់អ្នកតំណាងរាស្ត្រក្នុងក្រុមនីមួយៗត្រូវបានកំណត់ ហើយត្រូវនិយាយតែប្រធានបទដែលកំពុងពិភាក្សា។បើអ្នកនិយាយក្រៅពីប្រធានបទ ប្រធានត្រូវរំលឹកឲ្យធ្វើតាមរបៀបខាងលើនេះ វិញ។ បើតំណាងរាស្ត្រក្នុងក្រុមនោះនៅចចេសនិយាយក្រៅប្រធានបទដដែល ប្រធានអង្គប្រជុំអាចបញ្ឈប់វាគ្មិននោះកុំឲ្យនិយាយបន្តទៅទៀត ។

អ្នកតំណាងរាស្ត្រ មានសិទ្ធិក្នុងការកែប្រែលើខ្លឹមសារនូវផ្នែកខ្លះ រឺទាំងមូលក្នុងមាត្រាណាមួយ រឺជំពូកណាមួយ ដោយលើកពីបច្ចេកទេស និងមូលហេតុដែលខ្លួនសុំធ្វើការកែប្រែនោះដាក់ជូនអង្គសភាពិនិត្យថាតើគួរយតាមការស្នើសុំការកែប្រែនោះរឺក៏បដិសេធចោល ពេលនោះប្រធានអង្គប្រជុំអនុញ្ញាតឲ្យតំណាងរដ្ឋាភិបាល រឺប្រធានគណៈកម្មការជំនាញឡើងឆ្លើយតបថាគួរយកតាមការស្នើសុំកែប្រែ រឺបដិសេធចោល ។ ការសម្រេចយល់ព្រម រឺក៏បដិសេធនូវចំណុចដែលតំណាងរាស្ត្រស្នើសុំកែប្រែនោះ គឺអាស្រ័យទៅតាមតំណាងរាជរដ្ឋាភិបាល និងប្រធានគណៈកម្មការជំនាញ ។

## ២.៣.៣ការពិភាក្សា និងការអនុម័តក្នុងសម័យប្រជុំពេញអង្គ

ការប្រព្រឹត្តទៅជាធម្មតានៃការជជែកពិភាក្សាក្នុងសម័យប្រជុំពេញអង្គ ជាការជជែកពិភាក្សាលម្អិតត្រូវបានស្តែងឡើងនៅក្រោមលក្ខណៈពីរបែបដោយយោងតាម បានចែងថា អង្គសភាពិភាក្សានឹងអនុម័តលើមាត្រាមួយម្តងៗក៏បាន ប្រធានគណកម្មការជំនាញធ្វើការសម្រេចថា តើគួរដាក់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះ។ ហើយការជជែកពិភាក្សាទៅលើមាត្រា ឬជំពូកមានលក្ខណៈដូចខាងក្រោម៖

- ការជជែកពិភាក្សាមួយមាត្រាម្តងៗ ការពិភាក្សាបែបនេះ គឺដោយការស្នើសុំរបស់ប្រធានគណៈកម្មការជំនាញដោយមានការយល់ព្រមពីអង្គសភា ការជជែកពិភាក្សានេះត្រូវចាប់ផ្តើមមួយមាត្រាម្តងៗតាមលំដាប់លេខរៀងបន្តបន្ទាប់។

អ្នកតំណាងរាស្ត្រគ្រប់រូប ដែលចង់ចូលរួមបញ្ចេញយោបល់ អាចធ្វើបទអន្តរាគមន៍បានបន្ទាប់ពីបានទទួលការអនុញ្ញាតពីប្រធានអង្គប្រជុំជាមុនសិន។ (បើតាមប្រការ៥៥ថ្មី នៃបទបញ្ជាផ្ទៃក្នុងរដ្ឋសភា) ចែងថាតំណាងរាស្ត្រក្នុងក្រុមនីមួយៗ ត្រូវសុំតាមរយៈតំណាងក្រុមរបស់ខ្លួន ហើយ

ទទួលសេចក្តីអនុញ្ញាតពីប្រធានព្រឹទ្ធសភាជាមុនសិនទើបអាចនិយាយបាន។ ហើយដែលការសុំនិយាយនេះអាចធ្វើបានរហូតដល់វិនាទីចុងក្រោយនៃការប្រជុំ។

បទបញ្ជាផ្ទៃក្នុងរដ្ឋសភាកំណត់រយៈពេល និងបែបបទនៃការនិយាយចំពោះអ្នកតំណាងរាស្ត្រដែលសុំនិយាយ និងអ្នកតំណាងរាស្ត្រដែលគ្រាន់តែសុំឡើងឆ្លើយតប និងការកំណត់អំពីវាគ្មិនដែលត្រូវនិយាយទៀតសោតត្រូវគោរពតាម (ប្រការ៥៥ថ្មី បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា) បានចែងថា តាមគោលការណ៍ពេលនិយាយសម្រាប់តំណាងរាស្ត្រក្នុងក្រុមនីមួយៗត្រូវមានកំណត់ ហើយត្រូវនិយាយតែពីប្រធានបទដែលកំពុងជជែកពិភាក្សា។ បើនិយាយក្រៅប្រធានបទ ប្រធានត្រូវរំលឹកឲ្យធ្វើតាមរបៀបខាងលើនេះវិញ។ បើតំណាងរាស្ត្រក្នុងក្រុមនោះ នៅចចេសនិយាយក្រៅប្រធានបទដដែល ប្រធានអង្គប្រជុំអាចបញ្ឈប់វាគ្មិននោះកុំឲ្យនិយាយបន្តទៅទៀត។

ដោយឡែកប្រសិនបើនៅក្នុងអង្គប្រជុំ ការជជែកពិភាក្សាបានក្លាយជាការជជែកដែលបង្កឲ្យចលាចល ច្របូកច្របល់ ឥតសណ្តាប់ធ្នាប់ ហើយប្រធានហាមឃាត់ពុំស្តាប់ នោះប្រធានអាចផ្អាកការប្រជុំដោយក្រោកដើរចេញពីសាលប្រជុំតែម្តង។ ការបិទការប្រជុំបែបនេះកម្រកើតមាន ណាស់នៅព្រឹទ្ធសភាចាប់តាំងពីចាប់បដិសន្ធិក្នុងនីតិកាលទីមួយរហូតដល់បច្ចុប្បន្ន។ ប្រសិនបើប្រធានអង្គប្រជុំ ពិនិត្យឃើញអស់វាគ្មិនដែលចង់ធ្វើបទអន្តរាគមន៍ ហើយប្រធានអង្គប្រជុំនឹងលើក មាត្រាដែលធ្វើការពិនិត្យពិភាក្សាល្អិតល្អន់ ហើយសុំអង្គសភាធ្វើការអនុម័តដោយលើកដៃ ដោយ យកតាមសម្លេងភាគច្រើនដាច់ខាត នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល លើកលែងតែច្បាប់ ធម្មនុញ្ញ ដែលត្រូវយកតាមសម្លេងភាគច្រើនពីរភាគបី។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានមួយ រូបដឹកនាំការប្រជុំ។ ក្នុងវិស័យពិនិត្យច្បាប់ រដ្ឋសភាប្រជុំជាសាធារណៈ។

- ការជជែកពិភាក្សាមួយជំពូកម្តងៗ ក្រោយពីមានការស្នើសុំរបស់គណៈកម្មការជំនាញជូនទៅគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ឲ្យដាក់នីតិវិធីនៃការពិភាក្សា និងអនុម័តមួយជំពូកម្តងៗ ជូនព្រឹទ្ធសភាទាំងមូលធ្វើការអនុម័តដោយលើកដៃយកតាមសម្លេងភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូលថាតើគួរពិភាក្សា និងអនុម័តលើសេចក្តីព្រាងច្បាប់ ឬស្នើច្បាប់តាមមួយមាត្រាម្តងៗ ឬមួយជំពូកម្តងៗ។ នីតិវិធីនេះប្រើបានចំពោះតែសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ណាដែលមានលក្ខណៈងាយស្រួល យល់តែប៉ុណ្ណោះ។ ផ្ទុយទៅវិញ បើសេចក្តីព្រាងច្បាប់ ឬស្នើច្បាប់ណាដែលមានលក្ខណស្មុគស្មាញជាអាទិ៍ដូចជាច្បាប់ថវិកា អង្គសភាត្រូវធ្វើការពិភាក្សា និងអនុម័តមួយជំពូកម្តងៗ ដោយពិនិត្យលើគ្រប់មាត្រាទាំងអស់ដែលមាននៅក្នុងជំពូកនីមួយៗ។

ការជជែកពិភាក្សាមួយជំពូកម្តងៗ ព្រឹទ្ធសភាពុំបានធ្វើការពិនិត្យល្អិតល្អិន់ទៅលើគ្រប់មាត្រានោះទេ ពោលគឺពិនិត្យលើតែមាត្រាណា ដែលត្រូវបានអ្នកតំណាងរាស្ត្រស្នើឡើង និងជាពិសេសគឺពិនិត្យពិចារណាលើជំពូកទាំងមូលតែម្តង។ បន្ទាប់ពីព្រឹទ្ធសភា ធ្វើការពិភាក្សាជំពូកណាមួយចប់

ហើយ ព្រឹទ្ធសភាត្រូវធ្វើការអនុម័តលើជំពូកនោះតែម្តង រួចទើបចាប់ផ្តើមពិនិត្យពិភាក្សាលើជំពូកបន្តបន្ទាប់ ដោយអនុម័តមួយម្តងៗ តាមនីតិវិធីដដែលដូចខាងលើ។



**លក្ខខណ្ឌនៃការប្រជុំ**

ព្រឹទ្ធសភាអាចប្រជុំបាន លុះត្រាតែមានសមាជិកចំនួនយ៉ាងតិចស្មើនឹងប្រាំពីរភាគដប់នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូលបានចូលរួម។ ហើយការអនុម័ត ត្រូវធ្វើឡើងតាមលក្ខខណ្ឌដូចខាងក្រោម៖

១-ចំពោះសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ធម្មតា

បើការអនុម័តលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់គោលការណ៍ត្រូវយកតាមសម្លេងភាគច្រើនដាច់ខាតនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

២-ចំពោះច្បាប់ធម្មនុញ្ញ ឬបទបញ្ជាផ្ទៃក្នុងនៃព្រឹទ្ធសភា និងរដ្ឋសភាត្រូវយកតាមសម្លេងពីរភាគបីនៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល។

ការជជែកពិភាក្សា និងអនុម័តលើសេចក្តីព្រាងច្បាប់ ឬស្នើច្បាប់ត្រូវធ្វើតាមលំដាប់លំដោយដូចតទៅ៖

- ជាបឋមត្រូវជជែកពិភាក្សា និងអនុម័តលើខ្លឹមសារទាំងមូល គឺបញ្ចេញមតិថា តើគួរទទួលពិចារណារឺទេ? ។ តាមប្រការនេះសរបញ្ជាក់អោយឃើញថា រាល់ការពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់ ឬស្នើច្បាប់អង្គសភាត្រូវពិភាក្សា និងអនុម័តលើខ្លឹមសារទាំងមូលនៃសេចក្តីព្រាងច្បាប់ ឬស្នើច្បាប់នោះជាមុនសិន ទើបឈានដល់ការជជែកពិភាក្សា និងអនុម័តលើមាត្រាមួយម្តងៗ ឬលើជំពូកមួយម្តងៗក៏បាន។
- បន្ទាប់មកជជែកពិភាក្សា និងអនុម័តមួយមាត្រាម្តងៗ ឬមួយជំពូកម្តងៗ បន្ទាប់ពីអង្គសភាធ្វើការជជែកពិភាក្សា និងអនុម័តលើខ្លឹមសារទាំងមូលរួចហើយ អង្គសភានឹងឈានដល់ការពិភាក្សាសង្ខេបបាន ដោយពិភាក្សាតែមាត្រា ឬជំពូកណាដែលមានសំណើរធ្វើវិសោធនកម្មជាលាយលក្ខណ៍អក្សរ ដូចមានចែងក្នុងប្រការទាំងឡាយខាងលើនេះ។ ក្នុងករណីដែលនឹងត្រូវប្រើនីតិវិធីណាមួយខាងលើនេះគណៈកម្មាធិការអចិន្ត្រៃយ៍ ត្រូវជូនព័ត៌មានដល់អ្នកតំណាងរាស្ត្រជាមុន ។ យោងតាមប្រការនេះបញ្ជាក់ឲ្យឃើញថា ការពិភាក្សា និងអនុម័តមួយមាត្រាម្តងៗ ឬមួយជំពូកម្តងៗ គឺអាស្រ័យទៅដោយគណៈ_ កម្មាធិការអចិន្ត្រៃយ៍ជូនព័ត៌មានដល់សមាជិកសភាជាមុន។ ដូច្នេះនៅពេលដែលជជែក ពិភាក្សា និងអនុម័តលើខ្លឹមសារទាំងមូលរួចហើយ ប្រធានអង្គប្រជុំអនុញ្ញាតឲ្យប្រធានគណៈកម្មការជំនាញឡើងអានខ្លឹមសារនៃអត្ថបទសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ជូនអង្គសភាជ្រាបជាមុនដើម្បីដាក់អត្ថបទនេះឲ្យអង្គប្រជុំធ្វើការជជែកពិភាក្សា និងអនុម័តរហូតដល់អស់មាត្រា ឬជំពូកនៃសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់។ នីតិវិធីប្រជុំ

ជជែកពិភាក្សា និងអនុម័តនេះតម្រូវឲ្យមានកូរ៉ុមប្រាំពីរភាគដប់ នៃចំនួនសមាជិករដ្ឋសភាទាំងមូល ដោយយោងតាម ហើយការអនុម័តត្រូវយកតាមមតិភាគច្រើន ដាច់ខាតនៃសមាជិកព្រឹទ្ធសភាទាំងមូល។

ចំណែកការអនុម័តខាងលើគឺធ្វើឡើងតាមការលើកដៃ។ ចំពោះការអនុម័តដោយលើកដៃ លេខាអង្គប្រជុំទាំងឡាយជាអ្នករាប់ចំនួនសមាជិកដែលគាំទ្រ និងមិនគាំទ្រ រួចហើយលេខាអង្គប្រជុំឡើងជម្រាបជូនប្រធានអង្គប្រជុំ និងអង្គប្រជុំព្រឹទ្ធសភាឲ្យបានដឹងពីលទ្ធផល។



- ការអនុម័តលើខ្លឹមសាររួម បន្ទាប់ពីការជជែកពិភាក្សា និងអនុម័តខាងលើរួចមកអង្គសភានឹងបន្តអនុម័តលើខ្លឹមសាររួមនៃសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ ដើម្បីបញ្ចប់ការជជែកពិភាក្សា និងអនុម័តក្នុងសម័យប្រជុំពេញអង្គរបស់ព្រឹទ្ធសភា ហើយនីតិវិធីអនុម័តគឺធ្វើតាមនីតិវិធីដូចខាងលើ។ សេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ទាំងឡាយដែលព្រឹទ្ធសភាអនុម័តរួចហើយ ត្រូវបញ្ជូនទៅរដ្ឋសភាដើម្បីធ្វើការពិនិត្យ និងពិភាក្សាបន្ត។

## ២.៤ ការបង្វិលទៅបង្វិលមករវាងសភាទាំងពីរ

ច្បាប់នឹងចូលជាធរមាន លុះត្រាតែការពិនិត្រជាបន្តបន្ទាប់ដោយសភាទាំងពីរ (រដ្ឋសភានិងព្រឹទ្ធសភា) ត្រូវបានចប់សព្វគ្រប់។ ក្រោយពីការបង្វិលទៅបង្វិលមកចប់សព្វគ្រប់ ជាធម្មតាដំណាក់កាលនៃការអនុវត្តនីតិវិធី នីតិបញ្ញត្តិក៏ត្រូវបានបិទព្រមគ្នាដែរ ប្រសិនបើគ្មានការអនុវត្តនីតិវិធីពិសេសណាមួយដែលនាំឲ្យមានការពិភាក្សាជាថ្មីមុននឹងការប្រកាសឲ្យប្រើ (ចូលជាធរមាន) នោះទេ។ បើក្នុងករណីពិសេសណាមួយដែលនាំឲ្យមានការពិភាក្សានោះ មានលក្ខណៈដូចខាងក្រោម៖

### ១-ការបញ្ជូនទៅបញ្ជូនមករវាងសភាទាំងពីរ

រដ្ឋសភា និងព្រឹទ្ធសភាក្នុងការអនុម័តលើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់តម្រូវឲ្យមានការអនុម័តក្នុងន័យមួយដូចគ្នាទាំងរដ្ឋសភាក៏ដូចព្រឹទ្ធសភា ឬបើសិនជាមានករណីខ្វែងយោបល់គ្នាការអនុម័តលើអត្ថបទ សេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ នោះតម្រូវឲ្យរដ្ឋសភាធ្វើការសំរេចចិត្តផ្ទុយទៅនឹងយោបល់របស់ព្រឹទ្ធសភា។

តាមមតិរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ការបញ្ជូនទៅបញ្ជូនមករវាងរដ្ឋសភា និងព្រឹទ្ធសភាអាចធ្វើបានច្រើនដង តែត្រូវគោរពកំរិតរយៈពេលដែលមានដូចខាងក្រោម៖

- មួយខែ ៖ ចំពោះសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ធម្មតា
- ដប់ថ្ងៃ ៖ ចំពោះសេចក្ដីព្រាងច្បាប់ថវិកា និងហិរញ្ញវត្ថុ
- បួនថ្ងៃ ៖ ចំពោះសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ដែលទុកជាការប្រញាប់។

### ២-ការព្រមព្រៀងរវាងសភាទាំងពីរ

រាល់សេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់ទាំងឡាយ ត្រូវបានពិនិត្យជជែកពិភាក្សាជាបន្តបន្ទាប់ដោយរដ្ឋសភា និងព្រឹទ្ធសភាដើម្បីធ្វើការអនុម័តលើសេចក្ដីព្រាងច្បាប់ ឬសេចក្ដីស្នើច្បាប់នោះ។

សិទ្ធិក្នុងការអនុម័តនៅក្នុងដំណាក់កាលនៃការបញ្ជូនទៅបញ្ជូនមក ជានិច្ចកាលច្រើនតែជាសិទ្ធិក្នុងការពិនិត្យ និងជាយថាហេតុកែប្រែអត្ថបទច្បាប់ដែលអនុម័តដោយរដ្ឋសភា។ ប៉ុន្តែការបញ្ជូនរបៀបនេះនឹងអាចបញ្ចប់ ប្រសិនបើព្រឹទ្ធសភាព្រមអនុម័តដោយគ្មានការកែប្រែលើអត្ថបទច្បាប់ដែលអនុម័តដោយរដ្ឋសភាលើកដំបូង។

**៣-ដែននៃការបញ្ជូនទៅបញ្ជូនមករវាងសភាទាំងពីរ**

ការបញ្ជូនទៅបញ្ជូនមករវាងសភាទាំងពីរត្រូវបានបញ្ចប់ លុះត្រាណាព្រឹទ្ធសភាអនុម័តយល់ព្រមតាមការសំរេចរបស់រដ្ឋសភាដោយគ្មានការកែប្រែលើអត្ថបទសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលរដ្ឋសភាធ្វើការអនុម័តលើកដំបូង។

ដូច្នេះ ដែននៃការបញ្ជូនទៅបញ្ជូនមករវាងសភាទាំងពីរត្រូវបញ្ចប់ កាលណាសភាទាំងពីរស្របគ្នា។ មានន័យថា គ្រប់មាត្រា ឬគ្រប់ជំពូកនៃសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ទាំងឡាយណាដែលត្រូវបានសភាទាំងពីរយល់ស្របហើយនោះ វានឹងលែងក្លាយជាកម្មវត្ថុ នៃការបញ្ជូនទៅបញ្ជូនមកដើម្បីដាក់បញ្ចូលនៅក្នុងការពិភាក្សាលើកក្រោយឡើយ។ តាមទំលាប់ដែលត្រូវសភាទាំងពីរអនុម័តនៅពេលដែលសភាណាមួយបានពិចារណាហើយ ត្រូវធ្វើរបាយការណ៍ដើម្បីបញ្ជាក់ជូនសភាមួយទៀតថា តើមាត្រា ឬវាក្យខណ្ឌណាខ្លះដែលខ្លួនសុំកែប្រែ ហើយមាត្រា ឬវាក្យខណ្ឌណាខ្លះដែលខ្លួនយល់ស្រប។ គួរបញ្ជាក់ផងដែរថា ការបញ្ជូនទៅបញ្ជូនមករវាងសភាទាំងពីរត្រូវបានគេអនុវត្តតែក្នុងករណីដែលព្រឹទ្ធសភាសុំកែប្រែ លើសេចក្តីព្រាងច្បាប់មួយផ្នែក ឬទាំងស្រុងដែលរដ្ឋសភាអនុម័តយល់ព្រមរួច ហើយសិទ្ធិនៃការកែប្រែនេះ ជូនកាលវាជាមូលហេតុដែលនាំឲ្យមានការខ្វែងយោបល់រវាងសភាទាំងពីរ ។

- **ការខ្វែងយោបល់រវាងសភាទាំងពីរ**

បើមានការខ្វែងយោបល់ រវាងរដ្ឋសភា និងព្រឹទ្ធសភាក្នុងការជជែកពិភាក្សា និងអនុម័តលើអត្ថបទសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់គឺរដ្ឋសភាជាអ្នកមានសិទ្ធិសំរេចចុងក្រោយ។

## ២.៤.១សំណើរកែសំរួលរបស់ព្រឹទ្ធសភា

ករណីព្រឹទ្ធសភាសុំកែសំរួល ព្រឹទ្ធសភាមានសិទ្ធិកែសំរួលលើអត្ថបទលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ទាំងឡាយណាដែលរដ្ឋសភាបានអនុម័តយល់ព្រមជាលើកដំបូង។ ការស្នើសុំកែសំរួលនេះត្រូវបញ្ជូនទៅរដ្ឋសភាដើម្បីធ្វើការជជែកពិភាក្សាជាលើកទីពីរភ្លាម។ ក្នុងពេលពិភាក្សាជាលើកទីពីរនេះ រដ្ឋសភាត្រូវពិនិត្យ និងសំរេចតែត្រង់ចំណុចណានៃសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលព្រឹទ្ធសភាស្នើសុំកែសំរួល ដោយទុកជាបានការខ្លះ ឬបដិសេធចោលទាំងស្រុង។ ក្នុងការពិនិត្យពិភាក្សាជាលើកទីពីរនេះ ត្រូវធ្វើតាមនីតិវិធីនៃការជជែកពិភាក្សាលើកទីមួយដែរ ប៉ុន្តែអ្វីដែលប្លែកនោះ គឺការអនុម័តត្រូវធ្វើតាមវិធីបោះឆ្នោតចំហ និងយកតាមមតិភាគច្រើនដាច់ខាត[៥៨] ។

ក្នុងការពិនិត្យពិភាក្សាសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់លើកទីពីរនេះ រដ្ឋសភានេះអាចបោះឆ្នោតអនុម័តយល់ព្រម លើការស្នើសុំកែសំរួលរបស់ព្រឹទ្ធសភា កាលបើខ្លួនយល់ឃើញថា

[៥៨] មាត្រា១៣៣ថ្មី វាក្យខណ្ឌ៧ រដ្ឋធម្មនុញ្ញ

សេចក្តីកែសំរួលនោះសមរម្យ និងមានប្រយោជន៍ទៅលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះ។ ក្នុងករណីនេះធ្វើឲ្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលព្រឹទ្ធសភាសុំកែសំរួល ហើយបើរដ្ឋសភាយល់ព្រមបោះឆ្នោតអនុម័តយល់ព្រមហើយនោះ នឹងត្រូវយកប្រកាសឲ្យប្រើ។

ក្នុងករណីខាងលើ បើរដ្ឋសភាមិនយល់ស្រប តាមសំណើរសុំកែសំរួលរបស់ព្រឹទ្ធសភា រដ្ឋសភាត្រូវបញ្ជូនសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលខ្លួនអនុម័តលើកដំបូងជូនទៅព្រឹទ្ធសភាវិញ។ ការបញ្ជូនទៅបញ្ជូនមក ដែលធ្វើឡើងដោយគោរពតាមលក្ខណ៍ និងរយៈពេលដែលបានកំណត់ក្នុង[៥៩] ។ ការធ្វើរបៀបនេះក្នុងគោលបំណងស្វែងរកការយល់ព្រមរួមគ្នាមួយ។

បើការការបញ្ជូនទៅបញ្ជូនមកខាងលើនេះ នៅតែមិនមានការព្រមព្រៀងទេនោះដោយផ្អែកលើ (មាត្រា១១៣ថ្មី) បានចែងថា បើព្រឹទ្ធសភាសុំឲ្យកែសំរួលសេចក្តីព្រាងច្បាប់ រឺស្នើច្បាប់នោះរដ្ឋសភាត្រូវយកមកពិចារណាភ្លាមជាលើកទី២។ រដ្ឋសភាត្រូវពិនិត្យ និងសំរេចតែត្រង់បទបញ្ញត្តិ រឺចំនុចណាដែលព្រឹទ្ធសភាសុំឲ្យកែសំរួល ដោយបដិសេធចោលទាំងមូល ឬទុកជាបានការខ្លះ។

ការបញ្ជូនទៅបញ្ជូនមករវាងព្រឹទ្ធសភា និងរដ្ឋសភាត្រូវធ្វើតែក្នុងរយៈពេលមួយថ្ងៃ។ រយៈពេលនេះត្រូវបន្ថយត្រឹមដប់ថ្ងៃ បើត្រូវពិនិត្យសំរេចពីថវិកាជាតិ និងហិរញ្ញវត្ថុហើយយកត្រឹមតែ២ថ្ងៃបើជាការប្រញាប់។ បើរដ្ឋសភាទុកឲ្យហួសរយៈពេលកំនត់ ឬពន្យាពេលដែលកំនត់ទុក សំរាប់ពិនិត្យនោះ រយៈពេលជាគោលការណ៍សំរាប់រដ្ឋសភា និងព្រឹទ្ធសភាត្រូវបន្ថែមឲ្យស្មើគ្នាដែរ។ បើព្រឹទ្ធសភាបដិសេធសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះជាអសាបង់ រដ្ឋសភាមិនអាចនឹងយកមកពិចារណាជាលើកទីពីរបានមុនរយៈពេលមួយខែ។ រយៈពេលនេះត្រូវបន្ថយមកត្រឹមដប់ប្រាំថ្ងៃបើពិនិត្យពីថវិកាជាតិនិងហិរញ្ញវត្ថុហើយយកត្រឹមតែបួនថ្ងៃបើជាការប្រញាប់។

## ២.៤.២ ការពិនិត្យជាលើកទីពីររបស់ព្រឹទ្ធសភា

ក្នុងការពិនិត្យសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ជាលើកទីពីរនេះរដ្ឋសភាត្រូវអនុម័តដោយវិធីបោះឆ្នោតចំហនិងយកតាមមតិភាគច្រើនដាច់ខាត។ រាល់បទប្បញ្ញត្តិខានលើសបញ្ជាក់ឲ្យឃើញថា រាល់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ណាដែលបានធ្វើឡើងដោយគោរពតាមបទប្បញ្ញត្តិទាំងនេះហើយនោះនឹងត្រូវបានយកទៅប្រកាសឲ្យប្រើ។

ករណីព្រឹទ្ធសភាបដិសេធជាអសារបង់ ៖ បើព្រឹទ្ធសភាបដិសេធសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះជាអសារបង់ រដ្ឋសភាមិនអាចនឹងយកមកពិចារណាជាលើកទីពីរមុនរយៈពេលមួយខែទេ។ រយៈពេលនេះត្រូវបន្ថយមកត្រឹមដប់ប្រាំថ្ងៃបើពិនិត្យពីថវិកាជាតិនិងហិរញ្ញវត្ថុ ហើយមកត្រឹមបួនថ្ងៃបើជាការប្រញាប់[៦០] ។ ទោះបីជាព្រឹទ្ធសភាមានសិទ្ធិបដិសេធសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលរដ្ឋសភាអនុម័តលើកដំបូងក៏ដោយ ក៏រដ្ឋសភានៅតែធ្វើការជជែកពិភាក្សា និងអនុម័តលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលព្រឹទ្ធសភាបានបដិសេធជាអសារបង់ហើយក៏ដោយ។ ប៉ុន្តែការធ្វើរបៀបនេះត្រូវធ្វើឡើងតាមការកំណត់រយៈពេលដែលមានចែងក្នុង (មាត្រា

[៥៩] មាត្រា១១៣ថ្មី វាក្យខណ្ឌ៤នៃរដ្ឋ ធម្មនុញ្ញ

[៦០] មាត្រា១១៣ថ្មីរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា

១១៣ថ្មី រដ្ឋធម្មនុញ្ញ) ។ ហើយការអនុម័តនេះរដ្ឋសភាត្រូវបោះឆ្នោតជាចំហ និងយកតាមសម្លេងភាគច្រើនដាច់ខាត។ ការធ្វើរបៀបនេះនៅព្រះរាជាណាចក្រកម្ពុជាមិនសូវកើតមានទេ។

សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ដែលរដ្ឋសភាបានធ្វើការអនុម័តជាលើកទីពីរដោយបានគោរពទៅតាមនីតិវិធីដូចខាងលើត្រូវបានយកទៅប្រកាសឲ្យប្រើ។

ក្នុងន័យនេះ រាល់អត្ថបទច្បាប់ទាំងឡាយ ដែលរដ្ឋសភាបានអនុម័តជាលើកដំបូងដែលមិនទាន់ចូលជាធរមានត្រូវបានគេយកទៅតម្កល់នៅព្រឹទ្ធសភា ដើម្បីឲ្យព្រឹទ្ធសភាធ្វើការពិនិត្យ។ ហើយការតម្កល់នេះមានលំនាំដូចការតម្កល់សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នៅរដ្ឋសភាដែរ។ យោងតាម (មាត្រា១១៣ថ្មី វាក្យខណ្ឌ១រដ្ឋធម្មនុញ្ញ) បានចែងថាព្រឹទ្ធសភាពិនិត្យហើយឲ្យយោបល់ក្នុងរយៈពេលមួយខែយ៉ាងយូរលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ ដែលរដ្ឋសភាបានអនុម័តយល់ព្រមលើកដំបូងរួចហើយ។ តាមបទប្បញ្ញត្តិនៃមាត្រាខាងលើមានន័យថា ព្រឹទ្ធសភាមិនធ្វើការពិនិត្យពិភាក្សា និងអនុម័តលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ទាំងឡាយណាដែលរដ្ឋសភាពុំទាន់អនុម័តយល់ព្រមលើកដំបូងនោះទេ។

ក្រោយពីបានទទួលសេចក្តីព្រាងច្បាប់ឬសេចក្តីស្នើច្បាប់ដែលរដ្ឋសភាអនុម័តយល់ព្រមលើកដំបូងរួចហើយ ត្រូវបញ្ជូនមកគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា។ សេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះត្រូវធ្វើជាលាយលក្ខណ៍អក្សរហើយចែកជូនសមាជិកព្រឹទ្ធសភាទាំងអស់ ដោយភ្ជាប់សេចក្តីថ្លែងហេតុមកជាមួយផង។ គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាបញ្ជូនសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នោះទៅគណៈកម្មាធិការជំនាញពិនិត្យ។ កាលបើពិនិត្យរួចហើយ ប្រធានគណៈកម្មការនោះត្រូវនាំយកយោបល់របស់គណៈកម្មការមកជម្រាបជូនព្រឹទ្ធសភា[៦១]។ ហើយនីតិវិធីនៃការពិនិត្យជជែកពិភាក្សា និងអនុម័តលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់គឺមានលំនាំដូចគ្នាទៅនឹងការពិនិត្យជជែកពិភាក្សារបស់រដ្ឋសភាដែរ។ ម៉្យាងវិញទៀត ដើម្បីឲ្យការបករជុំរបស់ព្រឹទ្ធសភាដំណើរការទៅបានលុះត្រាតែមានកូរ៉ុមប្រាំពីរភាគដប់នៃសមាជិកព្រឹទ្ធសភាទាំងមូល[៦២] ហើយការអនុម័តយល់ព្រមលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ត្រូវយកតាមសម្លេងដូចដែលបានកំណត់សម្រាប់រដ្ឋសភាដែរ ពោលគឺយកាមសម្លេងភាគច្រើនដាច់ខាតលើកលែងតែច្បាប់ធម្មនុញ្ញ និងបទបញ្ជាផ្ទៃក្នុងរដ្ឋសភា និងបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភាដែលត្រូវយកតាមសម្លេងពីរភាគបី។ ជាទូទៅបន្ទាប់ពីព្រឹទ្ធសភាជជែកពិភាក្សា និងអនុម័តរួចហើយព្រឹទ្ធសភាត្រូវបញ្ជូនសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់នេះទៅរដ្ឋសភាវិញ ដោយគោរពទៅតាមដែនកំណត់នៃការបញ្ជូនទៅបញ្ជូនមក។

## ២.៥.ក្រុមប្រឹក្សាធម្មនុញ្ញ

ក្រុមប្រឹក្សាធម្មនុញ្ញមានសមាជិក៩រូប ដែលត្រូវទទួលអណត្តិ៩ឆ្នាំ។ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញចំនួនមួយភាគបីត្រូវផ្លាស់ថ្មីក្នុងរយៈពេលបីឆ្នាំម្តង។ សមាជិកបីរូបត្រូវតែងតាំងដោយព្រះមហាក្សត្របីរូបត្រូវជ្រើសតាំងដោយរដ្ឋសភា ហើយបីរូបទៀតត្រូវតែងតាំងដោយឧត្តមក្រុមប្រឹក្សា

---

[៦១] ប្រការ២៣នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា

[៦២] ប្រការ ៩៩នៃបទបញ្ជាផ្ទៃក្នុង ព្រឹទ្ធសភា

នៃអង្គចៅក្រម។ ប្រធានត្រូវបានជ្រើសតាំងដោយសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ។ ប្រធានមានសម្លេងឧត្តមានុភាព។

មុខងាររបស់សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មានវិសមភាពនឹងមុខងារសមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា សមាជិករាជរដ្ឋាភិបាល ចៅក្រមក្នុងតំណែងកាន់កាប់តំណែងណាមួយក្នុងមុខងារសាធារណៈ ប្រធាន ឬអនុប្រធាន គណបក្សនយោបាយ ប្រធាន ឬអនុប្រធានសហជីព។ ក្រុមប្រឹក្សាធម្មនុញ្ញ មានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យសព្វគ្រប់ហើយ។ ការអនុម័តទាំងឡាយរបស់រដ្ឋសភាដែលផ្ទុយនឹងគោលការណ៍រក្សាការពារឯករាជ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ហើយដែលនាំអោយឲ្យប៉ះពាល់ដល់ឯកភាពនយោបាយ ឬការគ្រប់គ្រងរដ្ឋបាលរបស់ ប្រទេសជាតិនឹងត្រូវចាត់ទុកជាអសារសូន្យ។ ក្រុមប្រឹក្សាធម្មនុញ្ញជាអង្គការតែមួយតែមួយគត់ដែលមានសមត្ថ_កិច្ចសម្រេចពីមោឃភាពនេះ។

### **២.៥.១ការត្រួតពិនិត្យជាអាទិភាល**

បទបញ្ញាផ្ទៃក្នុងរដ្ឋសភា ព្រឹទ្ធសភា និងច្បាប់រៀបចំអង្គការទាំងឡាយត្រូវតែបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យមុន និងប្រកាសឲ្យប្រើ។ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសំរេចនូវក្នុងរយៈពេលសាមសិបថ្ងៃយ៉ាងយូរ ថាតើច្បាប់បទបញ្ញាផ្ទៃក្នុងរដ្ឋសភា ព្រឹទ្ធសភា និងច្បាប់រៀបចំអង្គការខាងលើស្រប ឬមិនស្របនឹងរដ្ឋធម្មនុញ្ញ[៦៣]។

អ្នកមានសិទ្ធបញ្ជូនច្បាប់ ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាពិនិត្យចប់សព្វគ្រប់ទៅឲ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យមុន និង ច្បាប់នោះត្រូវប្រកាសឲ្យប្រើរួមមាន ៖

- ព្រះមហាក្សត្រ
- ប្រធានព្រឹទ្ធសភា
- ប្រធានរដ្ឋសភា
- នាយករដ្ឋមន្ត្រី
- សមាជិករដ្ឋសភាចំនួន មួយភាគដប់
- សមាជិកព្រឹទ្ធសភា ចំនួនមួយភាគបួន។

ពាក់ព័ន្ធនឹងបទបញ្ញាផ្ទៃក្នុងសភាទាំងពីរ ក្រោយពីបានទទួលការអនុម័តយល់ព្រមពីរដ្ឋសភា និងព្រឹទ្ធសភារួចមក ប្រធាននៃស្ថាប័នជាអ្នកស្នើសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញធ្វើការពិនិត្យពីធម្មនុញ្ញភាពនៃច្បាប់នេះ។

### **២.៥.២.ការត្រួតពិនិត្យជាបច្ឆាភាល**

ក្រោយពីច្បាប់ទាំងឡាយណា ត្រូវបានប្រកាសឲ្យប្រើរួចមកព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភា ចំនួនមួយភាគបួន សមាជិករដ្ឋសភាចំនួន

[៦៣] មាត្រា ១៤០ ថ្មី វាក្យខណ្ឌ២ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រ កម្ពុជា

មួយភាគដប់ ឬតុលាការអាចសុំឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់។

ប្រជារាស្ត្រ មានសិទ្ធិប្តឹងអំពីធម្មនុញ្ញភាពនៃច្បាប់បាន តាមរយៈតំណាង ឬប្រធានរដ្ឋសភា ឬសមាជិកព្រឹទ្ធសភា ឬប្រធានព្រឹទ្ធសភា[៦៤]។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ បទបញ្ញត្តិក្នុងមាត្រាណាដែលក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថា មិនស្របនឹងរដ្ឋធម្មនុញ្ញនោះមិនអាចយកទៅប្រកាសឲ្យប្រើ ឬយកទៅអនុវត្តបានឡើយ។

ក្នុងករណីដែលក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យឃើញថា ចំណុចមួយណា ឬមាត្រាណាមួយនៃសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ផ្ទុយទៅនឹងរដ្ឋធម្មនុញ្ញ បើជាសេចក្តីព្រាងច្បាប់ត្រូវបញ្ជូន ទៅរាជរដ្ឋាភិបាលដើម្បីធ្វើការពិនិត្យកែប្រែម្តងទៀត ដើម្បីឲ្យសមស្របទៅនឹងរដ្ឋធម្មនុញ្ញ ហើយបើជាសេចក្តីលើច្បាប់ត្រូវបញ្ជូនទៅឲ្យរដ្ឋសភា ដើម្បីធ្វើការពិនិត្យកែប្រែឡើងវិញ ដើម្បីឲ្យសមស្របនឹងរដ្ឋធម្មនុញ្ញ។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចបិទផ្លូវតវ៉ា[៦៥]។

[៦៤] មាត្រា១៤១ថ្មី នៃរដ្ឋធម្មនុញ្ញ

[៦៥] មាត្រា ១៤២ថ្មីនៃរដ្ឋធម្មនុញ្ញ

# សេចក្តីសន្និដ្ឋាន

តាមរយៈការពិពណ៌នាបកស្រាយខាងលើនេះរួចមក យើងសង្កេតឃើញថា នីតិវិធីធ្វើច្បាប់ ក៏ដូចជានីតិវិធីក្នុងការពិនិត្យ និងអនុម័តច្បាប់ នៅព្រះរាជាណាចក្រកម្ពុជាបានប្រព្រឹត្តទៅដោយមានលក្ខណៈរលូនជាងមុន ក៏ដូចជាដើម្បីពង្រឹងនូវប្រសិទ្ធិភាពច្បាប់ និងការអនុវត្តច្បាប់ ជាពិសេស ដើម្បីឲ្យប្រទេសយើងក្លាយទៅជានីតិរដ្ឋ។ ថ្វីត្បិតតែច្បាប់ទាំងនោះពុំទាន់មានលក្ខណៈពេញលេញគ្រប់ជ្រុងជ្រោយដូចអរិយប្រទេសផ្សេងទៀតក៏ដោយ ក៏ស្ថាប័ននេះបានអនុម័តច្បាប់ជាច្រើនដែលមានលក្ខណៈស្របទៅនឹងស្ថានភាពនយោបាយជាក់ស្តែងនៃសង្គមខ្មែរយើងបច្ចុប្បន្ន។

ទន្ទឹមនឹងការខិតខំប្រឹងប្រែង តាក់តែង រៀបចំ ពិនិត្យ និង អនុម័តលើអត្ថបទច្បាប់យ៉ាងណាក៏ដោយ ក៏ច្បាប់ទាំងនោះហាក់ដូចជាពុំមានភាពច្បាស់លាស់ ដូចជា ការមិនកំនត់ពេលវេលានៃការពិនិត្យរបស់គណៈកម្មការជំនាញដែលជាមូលហេតុនាំឲ្យមានការយឺតយ៉ាវ ក្នុងការតាក់តែងច្បាប់ និង ចំនុចមួយទៀត គឺទាក់ទងនឹងនីតិវិធីនៃការបង្វិលទៅមករវាងស្ថាប័ននីតិបញ្ញត្តិទាំងពីរ គឺនៅពេលដែលព្រឹទ្ធសភាបដិសេធសេចក្តីព្រាង ឬ សេចក្តីស្នើច្បាប់ ក៏ដូចជា ជំពូក ឬមាត្រាណាមួយហើយក៏ដោយ ក៏រដ្ឋសភានៅតែប្រកាន់ជំហររបស់ខ្លួនពីដំបូង។ ជាពិសេសទៅទៀត រាល់អត្ថបទច្បាប់ដែលបានអនុម័តសំរេច ហើយនឹងត្រូវប្រកាសអោយប្រើ នោះរដ្ឋសភាមានសិទ្ធិសំរេចចុងក្រោយគេបង្អស់ ទោះបីជាខ្លួន (រដ្ឋសភា) មិនព្រមតាមសំណើររបស់ព្រឹទ្ធសភាក៏ដោយ។ ហើយការសំរេចនេះ ធ្វើឡើងដោយគ្មានការសម្របសម្រួលជាមួយព្រឹទ្ធសភាជាមុនឡើយ។

ដូច្នេះ យើងឃើញថា ការបង្កើតស្ថាប័នកំពូលមួយនេះ (ព្រឹទ្ធសភា) ក្លាយទៅជាឥត មានខ្លឹមសារ និងឥតប្រយោជន៍។ ហើយការដែលបង្កើតព្រឹទ្ធសភាឡើងនេះ គឺគ្រាន់តែល្អមើលតែប៉ុណ្ណោះ ព្រោះថាយោបល់ជំទាស់ ឬការសុំកែប្រែរបស់ខ្លួនមានតម្លៃត្រឹមតែជាយោបល់ពិគ្រោះដែលរដ្ឋសភាពិចារណាក៏បាន មិនពិចារណាក៏បាន។

សរុបសេចក្តីមក ដោយសារមានការខ្វះចន្លោះនៃនីតិវិធីទាំងអស់នេះហើយ គួរតែស្ថាប័នទាំងពីរនេះ (រដ្ឋសភា និងព្រឹទ្ធសភា) ធ្វើការកែលំអនូវនីតិវិធីនៃការពិនិត្យរបស់គណៈកម្មការជំនាញតាមរយៈការកំនត់ពេលវេលាអប្បបរមា និង អតិបរិមា។ លើសពីនេះទៅទៀត ស្ថាប័នទាំងពីរគួរបង្កើតនូវយន្តការថ្មីណាមួយ ដែលលើកកំពស់តួនាទីភារកិច្ចរបស់ព្រឹទ្ធសភាអោយមានសិទ្ធិប្រហាក់ប្រហែលជាមួយនឹងរដ្ឋសភាដែរ ពោលគឺពុំគួរទុកលទ្ធភាពធំធេងពេកអោយរដ្ឋសភាក្នុងការអនុម័តសំរេចចុងក្រោយតែម្នាក់ឯងទេ ព្រោះថា ស្ថាប័នទាំងពីរនេះមានអំណាចខាងនីតិបញ្ញត្តិដូចតែគ្នា។

## ឯកសារយោង

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- បទបញ្ជាផ្ទៃក្នុងរដ្ឋសភា ឆ្នាំ ១៩៩៣
- បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ឆ្នាំ ១៩៩៩
- សេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ លេខ០៤៩ /០០៤/២០០២ កបធ ចុះថ្ងៃទី១៩ខែកញ្ញា ២០០២
- ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- សេចក្តីផ្តើមនីតិ ចងក្រងដោយ សាស្ត្រាចារ្យ **ហៀង សាន** និងអនុបណ្ឌិត **ប៉េន ឆុន**